សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics


# សារណាបញ្ចប់ការសិក្សា

# សមត្ថកិច្ចអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


ស្រាវជ្រាវដោយ
និស្សិតឈ្មោះ លោក **សំ រិទ្ធីសិទ្ធិ**

ណែនាំដោយសាស្ត្រាចារ្យជំនួយ
បណ្ឌិត **ឡុង សារ៉ាពេជ្រ**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ២៤

ឆ្នាំចូលរៀន ២០២០
ឆ្នាំសរសេរសារណា ២០២៤

## **សេចក្តីថ្លែងអំណរគុណ**

ខ្ញុំបាទ ឈ្មោះ **សំ រិទ្ធីសិទ្ធិ** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី ២៤ ក្រុម **L4A7** ក្នុងឆ្នាំសិក្សា ២០២០~២០២៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។

### **ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ**

លោកឪពុកឈ្មោះ **សំ រិទ្ធី**, អ្នកម្ដាយឈ្មោះ **អ៊ុង សុភាព** ។ កូនសូមអនុញ្ញាតសម្ដែងនូវការរំលឹកដឹងគុណចំពោះលោកអ្នកមានគុណដ៏ធំធេងលើសលប់ដែលមិនអាចកាត់ថ្លៃបានរបស់លោកឪពុក និងអ្នកម្ដាយដែលបានផ្ដល់នូវកំណើតហើយខិតខំថ្នាក់ថ្នមចិញ្ចឹមបីបាច់ ថែរក្សាកូនតាំងពីតូចរហូតដល់ធំដឹងក្ដី និងព្រមទាំងបានផ្គត់ផ្គង់ទៅលើការសិក្សាទាំងសម្ភារៈសម្លៀកបំពាក់ និងថវិកា សម្រាប់ចំណាយទៅលើការសិក្សា តាំងពីថ្នាក់បឋមសិក្សា អនុវិទ្យាល័យ វិទ្យាល័យ រហូតដល់បានរៀនចប់ថ្នាក់មហាវិទ្យាល័យថែមទៀតផង។ តាំងពីកូនកើតដឹងក្ដី រហូតមកដល់ពេលនេះ គឺកូនតែងតែរស់នៅក្រោមការផ្គត់ផ្គង់របស់ឪពុកម្ដាយនៅឡើយទេ មិនទាន់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការរស់នៅដោយពឹងផ្អែកទៅលើខ្លួនឯងទាំងស្រុងនោះទេ។ បន្ថែមលើសពីនេះទៅទៀត គឺលោកមានគុណទាំងពីរ គឺតែងតែ អប់រំទូន្មាន ប្រៀនប្រដៅបានផ្ដល់នូវដំបូន្មានល្អៗ គឺបានជម្រុញលើកទឹកចិត្តកូនគ្រប់ពេលវេលា និងជួយថែរក្សាការពារកូនៗគ្រប់គ្នា ដោយអស់ពីកម្លាំងកាយចិត្តរបស់លោកអ្នកមានគុណទាំងទ្វេ ដើម្បីចង់ឱ្យកូនក្លាយទៅជាមនុស្សដែលមានចំណេះ និងជំនាញជ្រៅជ្រះ មានសមត្ថភាពខ្ពស់ប្រកបទៅដោយ គុណធម៌ និងមានសុជីវធម៌ប្រពៃថ្លៃថ្លា។ ជាការពិតណាស់កូនៗពិតជាមិនអាចបំភ្លេចនូវគុណតម្លៃដ៏ខ្ពង់ខ្ពស់ និងថ្លៃថ្លា ដែលអ្នកមានគុណទាំងពីរបានផ្ដល់ចំពោះកូនបានឡើយ។

**ឯកឧត្តម លុយ ចណ្ណា** សាកលវិទ្យាធិការ នៃសាកលវិទ្យាភូមិន្ទនីតិសាស្ត្រ និងវិទ្យាសេដ្ឋកិច្ច ព្រមទាំងសាកលវិទ្យាធិការរង ព្រឹទ្ធបុរស លោក លោកស្រី សាស្ត្រាចារ្យ ដែលបានខិតខំប្រឹងប្រែងជួយបង្ហាត់បង្រៀនអស់ពីសមត្ថភាព ទាំងកម្លាំងកាយចិត្ត និងជួយពង្រឹងគុណភាពក៏ដូចជាការដឹកនាំ ក្នុងស្ថាប័ន ក្នុងកម្មវិធីសិក្សាទៅដល់និស្សិតលើគ្រប់ជំនាញទាំងអស់ នៅក្នុងសាកលវិទ្យាល័យ ប្រកបទៅដោយប្រសិទ្ធភាពខ្ពស់បំផុត និងទទួលបានពុទ្ធិមួយឱ្យពិតប្រាកដ សម្រាប់បន្តវេនក៏ដូចជាសសរទ្រូងដល់ប្រទេសជាតិឱ្យមានការអភិវឌ្ឍទៅមុខ។

**លោកសាស្ត្រាចារ្យជំនួយ បណ្ឌិត ឡុង សារ៉ាពេជ្រ** ដែលជាសាស្ត្រាចារ្យណែនាំក្នុងការសរសេរសារណាបញ្ចប់ការសិក្សាបរិញ្ញាបត្រផ្នែកច្បាប់នេះ។ ប្រសិនបើគ្មានវត្តមានលោកគ្រូសាស្ត្រាចារ្យណែនាំ ក្នុងការជួយជ្រោមជ្រែង ផ្ដល់ជាមតិយោបល់ និងជួយតម្រង់ទិសទេនោះ ក៏ខ្ញុំបាទមិនអាចដំណើរការក្នុងការសរសេរសារណានេះទៅមុខទៀតបាននោះទេ។ ដូច្នេះ លោកគ្រូសាស្ត្រចារ្យណែនាំ គឺពិតជាដើរតួនាទីដ៏សំខាន់ នៅក្នុងការជួយត្រួសត្រាយផ្លូវ និងវិធីសាស្ត្រល្អៗមួយចំនួន ដែលអាចឱ្យខ្ញុំបាទយល់កាន់តែស៊ីជម្រៅទៅលើប្រធាន

បទមួយនេះ ជាពិសេសបានបំផុសគំនិតទៅដល់ក្រុមយើងខ្ញុំកាន់តែច្រើនក្នុងការសរសេរ ទើបបានធ្វើឱ្យការតាក់តែងសរសេរបញ្ចប់សារណាមួយនេះ កាន់តែមានភាពរលូនរហូតដល់ទទួលបានជោគជ័យ។

**សិស្សច្បង និងមិត្តនិស្សិតរួមជំនាន់** ដែលបានជួយជ្រោមជ្រែង ក៏ដូចជាបានជួយលើកទឹកចិត្ត មិនថាក្នុងម៉ោងសិក្សា ឬក្រៅម៉ោងសិក្សា ហើយថែមទាំងចេះសហការគ្នាក្នុងគ្រាលំបាក និងមានទំនាក់ទំនងល្អចំពោះគ្នាទៅវិញទៅមក។ លើសពីនេះ រៀមច្បងក៏បាន ធ្វើការចែករំលែកអំពីបទពិសោធន៍ល្អៗ ដែលគាត់ធ្លាប់បានឆ្លងកាត់ ហើយក៏បានផ្តល់ជា គំនិត មតិយោបល់ល្អៗ នៅក្នុងដំណើរការសរសេរសារណានេះឱ្យកាន់តែច្បាស់លាស់បន្ថែមទៀត។

ជាចុងបញ្ចប់ យើងខ្ញុំបាទសូមអនុញ្ញាត លំអោនកាយគោរព និងលើកហត្ថាទាំងទ្វេប្រណម ដោយចេញពីដួងចិត្ត សូមថ្លែងអំណរគុណទៅដល់អ្នកទាំងអស់គ្នា ដែលបានរៀបរាប់ខាងនូវលើនេះ សូមឱ្យមានសុខភាពល្អបរិបូរណ៍ មានរាងកាយមាំមួន ហើយសូមឱ្យទទួលបានជោគជ័យក្នុងការប្រកបរបរការងាររកស៊ី ធ្វើអាជីវកម្មផ្សេងៗ ព្រមទាំងសូមឱ្យជួបតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លាងឃ្លាតឡើយ។

## **អារម្ភកថា**

ជាកិច្ចចាប់ផ្ដើម បន្ទាប់ពីបានឆ្លងកាត់ការសិក្សាទៅលើជំនាញផ្នែកច្បាប់រយៈពេលកន្លងមកនេះ ដែលសិក្សានៅសាកលវិទ្យាល័យភូមិនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្រុមយើងខ្ញុំ បានមានចំណាប់អារម្មណ៍ទៅលើប្រធានបទមួយដែលនិយាយអំពី៖ **សមត្ថកិច្ចអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា** ដែលជាប្រធានបទដ៏មានសារសំខាន់ខ្លាំងណាស់ សម្រាប់អ្នកសិក្សាលើជំនាញច្បាប់ផ្ទាល់ និងសម្រាប់និស្សិតនៅជំនាន់ក្រោយៗ ដែលមានបំណងចង់សិក្សាស្វែងយល់បន្ថែមទៅលើប្រធានបទមួយនេះ ។

សារណានេះគឺកើតចេញពីកិច្ចខិតខំប្រឹងប្រែងក្នុងការសិក្សាស្រាវជ្រាវនៃក្រុមរបស់យើងខ្ញុំដែលបានខិតខំសម្រិតសម្រាំង ស្រាវជ្រាវដោយចំណាយអស់រយៈពេលបីខែក្នុងការចងក្រងសៀវភៅសារណានេះ។ បន្ថែមពីនេះ ទៅទៀតសារណានេះអាចមានភាពរលូនទៅបានក៏ដោយសារមានការសហការចូលរួមផ្តល់ជាមតិយោបល់ ពីអ្នកជំនាញផ្នែកច្បាប់ជាពិសេសនោះគឺក៏មានការចូលរួមពីលោកគ្រូសាស្ត្រចារ្យណែនាំផងដែរ។ កត្តាទាំងនេះហើយ ដែលធ្វើឱ្យខ្ញុំបាទ មានកម្លាំងចិត្ត និងមានយុត្តិសាស្ត្រនៅក្នុងការសរសេររហូតដល់ទទួលបានជោគជ័យ។ កម្រងសារណានេះ គឺគ្រាន់តែជាផ្នែកមួយនៃការពណ៌នា អំពីសមត្ថកិច្ចអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា តែប៉ុណ្ណោះទេ។

ជាកិច្ចបន្ទាប់ខ្ញុំបាទ សូមថ្លែងអំណរគុណយ៉ាងក្រៃលែងចំពោះលោកគ្រូ **ឡុង សារ៉ាពេជ្រ** សាស្ត្រាចារ្យណែនាំ ក៏ជាសាស្ត្រាចារ្យជំនួយនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលជាសាស្ត្រាចារ្យលើជំនាញផ្នែកនីតិ ក្នុងការយកចិត្តទុកដាក់បង្ហាត់បង្រៀន ពន្យល់ណែនាំ និងជួយជម្រុញលើកទឹកចិត្តរហូតដល់ក្រុមយើងខ្ញុំ បានសរសេរសៀវភៅសារណានេះឡើងបានដោយជោគជ័យ។

ចំពោះការសរសេរសារណាមួយនេះ ខ្ញុំបាទក៏នៅមានការខ្វះចន្លោះ ហើយមិនទាន់បានសរសេរក្បោះក្បាយនិងគ្រប់ជ្រុងជ្រោយនៅឡើយនោះទេ។ ហេតុដូច្នេះហើយ ខ្ញុំបាទសូមមេត្តាអធ្យាស្រ័យ និងសូមអភ័យទោសពីប្រិយមិត្តអ្នកអានទាំងអស់ នូវរាល់កំហុសឆ្គងទាំងឡាយ និងសូមទទួលស្វាគមន៍នូវរាល់មតិរិះគន់ក្នុងន័យស្ថាបនា ពីសំណាក់អ្នកអានគ្រប់រូប មន្ត្រីរាជការគ្រប់ស្ថាប័នទាំងអស់ ដើម្បីជួយក្នុងការកែលម្អចំពោះស្នាដៃមួយនេះឱ្យកាន់តែមានអត្ថន័យស៊ីជម្រៅជាងនេះបន្ថែមទៀត។

ជាចុងបញ្ចប់ ខ្ញុំបាទសូមគោរពជូនពរចំពោះលោកគ្រូ សាស្ត្រចារ្យណែនាំ ក៏ដូចជាប្រិយមិត្តអ្នកអានសិស្សនិស្សិត មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ បុគ្គលិកគ្រប់ស្ថាប័ន សូមឱ្យជួបប្រទះតែភាពសុខសាន្ត សេចក្ដីចម្រុងចម្រើននិងទទួលបានជោគជ័យក្នុងការប្រកបរាល់ភារកិច្ចការងារទាំងអស់។

# មាតិកា

ទំព័រ

**ពាក្យគន្លឹះ** ........................................................ iii

**សេចក្ដីផ្ដើម** ........................................................ ១

**ជំពូកទី១ ទិដ្ឋភាពស្ថាប័នរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**១.១. ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក្នុងរយៈកាល** ............ ៧

**១.១.១ រចនាសម្ព័ន្ធនៃប្រព័ន្ធតុលាការអង្គជំនុំជម្រះវិសាមញ្ញ** ........................ ៨

១.១.១.១ ផ្នែកតុលាការនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ........................ ៨

១.១.១.២. សមាសភាពអង្គជំនុំជម្រះវិសាមញ្ញ ........................ ៩

**១.២ តួនាទីតាមការិយាល័យនៅក្នុងអង្គជំនុំជម្រះ** ........................ ៩

**១.២.១ ការិយាល័យសហចៅក្រមស៊ើបអង្កេត** ........................ ១០

**១.២.២. ការិយាល័យសហព្រះរាជអាជ្ញា** ........................ ១១

**១.២.៣. អង្គភាពគាំពារជនរងគ្រោះ** ........................ ១២

**១.២.៤. សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី** ........................ ១៣

**១.២.៥ ការិយាល័យរដ្ឋបាល** ........................ ១៣

**ជំពូកទី២ លក្ខណៈដោយឡែករបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**២.១ ការប្រៀបធៀបអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានិង តុលាការព្រហ្មទណ្ឌអន្តរជាតិ** ICC ........................ ១៦

**២.១.១ ភាពដូចគ្នារវាងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងតុលាការព្រហ្មទណ្ឌអន្តរជាតិផ្សេងទៀត** ........................ ១៦

២.១.១.១. កំណត់បទល្មើស និង ភាពគ្មានអាជ្ញាយុកាលនៃបទល្មើស ........................ ១៧

២.១.១.២. ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ........................ ១៧

២.១.១.៣. ឧក្រិដ្ឋកម្មប្រឆាំមនុស្សជាតិ ........................ ១៨

២.១.១.៤. ឧក្រិដ្ឋកម្មសង្គ្រាម ........................ ២០

**២.១.២.ភាពខុសគ្នារវាងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា** (ECCC) **និងតុលាការព្រហ្មទណ្ឌអន្តរជាតិ** (ICC) ........................ ២១

២.១.២.២.ស្វ័យភាពនៃអង្គជំនុំជម្រះវិសាមញ្ញនិងគោលការណ៍នៃការបំពេញបន្ថែមរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ........................ ២២

២.១.២.៣.ការដាក់ដែនកំណត់ចំពោះជនដែលអាចត្រូវបានចោទប្រកាន់ដោយអង្គជំនុំជម្រះវិសាមញ្ញ ..... ២៤
**២.២. ការបើកឱ្យមានវត្តមានដល់ ជនរងគ្រោះ និង លក្ខណៈចូលខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី** ..... ២៥
**២.២.១. វត្តមានរបស់ដើមបណ្តឹងរដ្ឋប្បវេណី** ..... ២៥
**២.២.២. លក្ខណៈ នៃការចូលរបស់ដើមបណ្តឹងរដ្ឋប្បវេណី និង តំណាងដើម បណ្តឹងរដ្ឋប្បវេណី** ..... ២៥
២.២.២.១. លក្ខណៈ នៃការចូលរបស់ដើមបណ្តឹងរដ្ឋប្បវេណី ..... ២៦
២.២.២.២. តំណាងដើមបណ្តឹងរដ្ឋប្បវេណី ..... ២៦
**២.៣. យុត្តាធិការក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា** ..... ២៧
**២.៣.១. ដែនយុត្តាធិការលើពេលវេលារបស់តុលាការត្រូវបានកំណត់ត្រឹមៈ** ..... ២៧
**២.៣.២. ដែនយុត្តាធិការលើបុគ្គលៈ** ..... ២៧
**២.៣.៣. ដែនយុត្តាធិការតាមបទចោទៈ** ..... ២៧

**ជំពូកទី៣**

**សេចក្តីសម្រេច និង លទ្ធផលសម្រេចរបស់ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**៣.១ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា** ..... ២៩
**៣.១.១ សំណុំរឿង ០០១** ..... ២៩
**៣.១.២ សំណុំរឿង ០០២** ..... ៣១
**៣.១.៣ សំណុំរឿង ០០៣** ..... ៣៥
**៣.១.៤ សំណុំរឿង ០០៤** ..... ៣៧
**៣.២. សំណងជនរងគ្រោះ និង ការរក្សាទុកឯកសារសំខាន់ៗក្រោយពីអង្គជំនុំជម្រះ** ..... ៤២
**៣.២.១. សំណងជនរងគ្រោះ** ..... ៤២
**៣.២.២. ការរក្សាទុកឯកសារសំខាន់ៗក្រោយពីអង្គជំនុំជម្រះ** ..... ៤៣
**សេចក្តីសន្និដ្ឋាន** ..... ៤៦

# ពាក្យគន្លឹះ

❖ តុលាការមានសមត្ថកិច្ច ៖ ជាតុលាការដែលទទួលបានដោយស្របច្បាប់នូវពាក្យបណ្ដឹង វិនិច្ឆ័យសេចក្ដីរឿងក្ដី ហើយចេញសាលក្រម ឬ សាលដីការបាន។

❖ យុត្តាធិការ ៖ ជាអំណាចដែលរដ្ឋមាន ក្នុងការចែងនិងដាក់ទោសអំពើល្មើសអនុវត្តច្បាប់និង វិនិច្ឆ័យសេចក្ដីលើអំពើល្មើស។ យុត្តាធិការមានក្នុងស្រុក ឬមានសម្រាប់សកម្មភាពល្មើសក្រៅប្រទេស (Extraterritorial jurisdiction)។ រដ្ឋ កំណត់យុត្តាធិការក្នុងច្បាប់ដោយផ្អែកលើគោលការណ៍ចំនួន ៤៖ ១. ដែនដីដែលសំដៅលើទី កន្លែងដែលអំពើល្មើសកើតមាន ដែលចែកជាពីរ គឺធាតុផ្សំនៃបទល្មើសបានកើតមានឡើង (Subjective territoriality) និងទីកន្លែងដែលផលវិបាកនៃបទល្មើសកើតមានឡើង (Objective territoriality)។ ២. បុគ្គលមានសញ្ជាតិរបស់ខ្លួនដែលប្រព្រឹត្តដែលអាចកើតមាននៅក្រៅដែនដី (Active nationality) ឬ ជនរងគ្រោះនៃអំពើជាប្រជាជននៃរដ្ឋនោះ (Passive nationality)។ ៣. គោលការណ៍ ការពារប្រយោជន៍ (Protective principle រដ្ឋមានសមត្ថកិច្ចលើបទល្មើសប្រព្រឹត្តនៅទីណាដោយជនបរទេស ដែលប៉ះពាល់ដល់សន្តិសុខ ឬអធិបតេយ្យភាពរបស់រដ្ឋ និងទី ៤. គោលការណ៍សកល (Universality theory) បង្កើតជាយុត្តាធិការ លើបទឧក្រិដ្ឋកម្មធ្ងន់ធ្ងរក្រោមច្បាប់អន្តរជាតិ ដូច ជាប្រល័យពូជសាសន៍ (Genocide)។

❖ យុត្តាធិការតុលាការ ជា សិទ្ធិអំណាចរបស់តុលាការ ក្នុងការអនុវត្តច្បាប់ និង កាត់ក្ដីក្នុងដែនយុត្តាធិការ។

❖ ឧក្រិដ្ឋកម្មអន្តជាតិ៖ ពាក្យ "ឧក្រិដ្ឋកម្មអន្តរជាតិ" គឺជាពាក្យសមូហភាពសម្រាប់ការរំលោភយ៉ាងធ្ងន់ធ្ងរបំផុតនៃច្បាប់អន្តរជាតិ៖ អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការធ្វើទារុណកម្ម និងការបាត់ខ្លួនដោយបង្ខំ។

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការសិក្សាស្រាវជ្រាវ

ការសម្លាប់រង្គាលគឺជាព្រឹត្តការណ៍ដែលកើតមានឡើងនៅជុំវិញពិភពលោក មិនថាស្ថិតនៅប្រទេស ក្នុងអឺរ៉ុប អាហ្វ្រិក ឬផ្នែកអាស៊ីក្តី។ តុលាការ ad hoc[1] និងមានលក្ខណៈជាតុលាការកូនកាត់[2] មានមុខងារ ដោះស្រាយបញ្ហា និងផ្តន្ទាទោសឧក្រិដ្ឋជនដែលប្រព្រឹត្តបទល្មើសប្រល័យពូជសាសន៍ ប្រឆាំងមនុស្សជាតិ ក៏ដូចជាឧក្រិដ្ឋកម្មនានាដែលប៉ះពាល់ដល់សង្គមជាតិ និងសន្តិសុខសង្គម។ តុលាការកូនកាត់នេះផងដែរ បានបង្កើតឡើងតាមបណ្តាប្រទេសមួយចំនួននៅលើពិភពលោក ដើម្បីដោះស្រាយនិងកាត់ទោសលើឧក្រិដ្ឋ ជនដែលប្រព្រឹត្តបទល្មើសទាំងនោះ។ តុលាការទាំងនោះមានដូចជា Special Panels and Serious Crimes Unit in East-Timor ដែលបង្កើតឡើងដោយ United Nations Transitional Administration in East Timor (UNTAET) ក្នុងឆ្នាំ២០០០ ដើម្បីដោះស្រាយបទល្មើសព្រហ្មទណ្ឌធ្ងន់ធ្ងរ នៅក្នុងប្រទេសទីម័រ (East Timor) ខាងកើតក្នុងឆ្នាំ១៩៩៩។ តុលាការកូនកាត់ផ្សេងៗមានដូចជា Special Court for Sierra Leone ដើម្បីដាក់ទោសឧក្រិដ្ឋជនដែលប្រព្រឹត្តបទល្មើសប្រឆាំងមនុស្សជាតិក្រោយថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៦, Regulation 64 Panels in the Courts of Kosovo សម្រាប់កាត់ទោសលើឧក្រិដ្ឋជនលើបទល្មើសសង្គ្រាមឆ្នាំ ១៩៩៩ និង Extraordinary African Chambers លើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ឧក្រិដ្ឋកម្មប្រឆាំង មនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងទារុណកម្មធ្ងន់ធ្ងរ នៅក្នុងកំឡុងឆ្នាំ១៩៨២ ដល់ឆ្នាំ១៩៩០។ ការប្រព្រឹត្ត ទៅយ៉ាងរលូននេះ ទើបបណ្តាលឱ្យមានការបង្កើតតុលាការកូនកាត់នៅប្រទេសកម្ពុជានេះ។ គួរបញ្ជាក់ផងដែរថា របបកម្ពុជាប្រជាធិបតេយ្យ ឬរបបខ្មែរក្រហមបានចូលគ្រប់គ្រងប្រទេសកម្ពុជាចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ ក្នុងរយៈពេល ៣ឆ្នាំ ៨ខែ និង ២០ថ្ងៃ។ របបនេះបានធ្វើឱ្យប្រជាជនកម្ពុជាទាំងអស់ទទួលរងទុក្ខវេទនា អត់ឃ្លាន បែកបាក់គ្រួសារ រហូតឈានដល់ការបាត់បង់ជីវិត ថែមទៀតផង ដែលប្រជាជនចំនួនប្រមាណជាង ១លាន ៧សែននាក់ ត្រូវបានបាត់បង់ជីវិតយ៉ាងអយុត្តិធម៌។ ម្យ៉ាងទៀត របបនេះក៏បានធ្វើកម្ពុជាធ្លាក់ចុះដុនដាបយ៉ាងខ្លាំង ព្រោះថារាល់ហេដ្ឋារចនាសម្ព័ន្ធនានានៅក្នុង ប្រទេសត្រូវបានបំផ្លិចបំផ្លាញគ្មានសេសសល់បន្តិចសោះឡើយ។

ករណីនេះ បានបន្សល់ទុកនូវភាពឈឺចាប់ក្នុងសង្គមកម្ពុជាដែលមិនធ្លាប់មានពីមុនមក។ ក្រោយពីមានការបង្រួបបង្រួមជាតិឡើងវិញ និងមានប្រជាជនជាច្រើនបានទាមទារយុត្តិធម៌ ទើបសហនាយករដ្ឋមន្ត្រី របស់កម្ពុជា

---

[1] តុលាការ អាដហុក ជាតុលាការដែលបង្កើតឡើងដោយមានរយៈពេលមួយក្នុងការចាំបាច់ឱ្យមាន បន្ទាប់ពីអត់ភារកិច្ចតុលាការនេះនឹងត្រូវរំសាយ ឬបញ្ចប់កិច្ចទៅវិញ ខុសពីតុលាការអចិន្ត្រៃយ៍ ឧ. តុលាកាព្រហ្មទណ្ឌអន្តរជាតិ Internation Criminal Court (ICC) ។

[2] តុលាការកូនកាត់ ជាតុលាការដែលសំដៅលើ តុលាការដែលមានលក្ខណៈជាថ្នាក់ជាតិផង និងអន្តរជាតិផង ជារួមមានការប្រើប្រាស់ច្បាប់ជាតិ និងច្បាប់អន្តរជាតិក្នុងការដំណើរការនីតិវិធីកាត់ក្តី។

បានស្នើសុំទៅអង្គការសហប្រជាជាតិ ឱ្យបង្កើតសាលាក្តីមួយ ដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហមជាលទ្ធផល អង្គការសហប្រជាជាតិក៏បានបញ្ជូនក្រុមអ្នកជំនាញមកកាន់កម្ពុជាដើម្បីសិក្សាអំពីលទ្ធ ភាពបង្កើតតុលាការលក្ខណៈអន្តរជាតិ និងបានផ្តល់អនុសាសន៍ឱ្យមានការបង្កើត តុលាការព្រហ្មទណ្ឌ អន្តរជាតិ ដែលស្រដៀងគ្នានឹងតុលាការដែលបានបង្កើតនៅអតីតយូហ្គោស្លាវី និងរ៉ាន់ដា។ ប៉ុន្តែសំណើនេះ មានលក្ខណៈចំរូងចម្រាស់ ហើយនាំឱ្យមានការចរចារអស់រយៈពេលជាច្រើនឆ្នាំ។ នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៦ យើងឃើញមាន អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែល ហៅកាត់ថា "អ.វ.ត.ក" ឬភាគច្រើនដែលគេស្គាល់ថា សាលាក្តីខ្មែរក្រហម ឬសាលាក្តីកូនកាត់នេះលេចរូបរាង ឡើងនៅលើផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌពោធិសែនជ័យ រាជធានីភ្នំពេញ។ ហើយបច្ចុប្បន្ននេះ អ.វ.ត.ក បានបំលែងរូបរាងថ្មី នឹងទៅជាមជ្ឈមណ្ឌលធនធាន ដែលមានទីតាំងនៅក្នុងបរិវេណការិយាល័យថ្មីរបស់អ.វ.ត.ក. អគារលេខ៤០ មហាវិថីសហព័ន្ធរុស្សី (ផ្លូវ១១០) សង្កាត់មិត្តភាព ខណ្ឌ៧មករា ភ្នំពេញ។

## ២. ចំណោទបញ្ហានៃការដោះស្រាយ

ចំពោះហេតុផលដ៏សំខាន់នៃការស្រាវជ្រាវនេះ បានផ្តោតទៅលើចំណោទបញ្ហាស្រាវជ្រាវសំខាន់ៗដូចខាងក្រោម៖

១. តើតុលាការអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវបានបង្កើតឡើងដោយរបៀបណាដោយមានលំនាំគតិយុត្តយ៉ាងដូចម្តេច?

២. តើរចនាសម្ព័ន្ធនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានលក្ខណៈដូចម្តេចខ្លះ?

៣. តើលក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញាក្នុងតុលាការកម្ពុជាក្នុងការកាត់ក្តីមានអ្វីខ្លះ? ហើយមូលហេតុអ្វីបានជាមិនជ្រើសយកតុលាការព្រហ្មទណ្ឌអន្តរជាតិកាត់ទោសឧក្រិដ្ឋជនទាំងនោះ?

៤. តើយុត្តាធិការក្នុងការអនុវត្តរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាប្រព្រឹត្តឡើងយ៉ាងដូចម្តេច?

៥. តើអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានជំនុំជម្រះលើសំណុំរឿងចំនួនប៉ុន្មាន?

## ៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការស្រាវជ្រាវនេះគឺដើម្បីឆ្លើយតបនឹង ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅក្នុងបរិបទនៅសម័យនោះ និងឆ្លើយតនឹងគោលបំណងរបស់អង្គជំនុំជម្រះ។ គោលបំណងបន្ទាប់នោះគឺ យើងខ្ញុំ បានធ្វើការសរសេរបកស្រាយ និងការចងក្រងជាសៀវភៅសារណានេះ ដើម្បីជាប្រយោជន៍នៅក្នុងការស្វែងយល់ ពីលំហូរនៃដំណើរការនីតិវិធីរឿងក្តីព្រហ្មទណ្ឌបែបឧក្រិដ្ឋកម្មធ្ងន់ធ្ងរបំផុតពោល ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដែលអនុវត្តនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ នៅក្នុងនោះផងដែរ ការ

បង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នេះក្នុងគោលបំណងឱ្យមានការដោះស្រាយរឿងក្តីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ នៅក្នុងដែនដីទឹកដីកម្ពុជា ក៏ដូចជាស្វែងយល់ពីសមត្ថកិច្ចរបស់អង្គជំនុំជម្រះវិសាមញ្ញនេះដែលបានប្រព្រឹត្ត ទៅកន្លងមកបន្ថែមពីនេះ ដើម្បីសិក្សាពីច្បាប់ដែលត្រូវអនុវត្តជាច្បាប់ជាតិ និងអន្តរជាតិក្នុងការរក្សា តម្លាភាព និងសុចរិតភាព ហើយអាចមានទំនុកចិត្តពីសំណាក់សាធារណជននៅទូទាំងប្រទេសដែលបានជួបផ្ទាល់ ឬមិនផ្ទាល់ក្នុងប្រតិការណ៍ប្រល័យពូជសាសន៍កន្លងមក។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

គោលគំនិតនៃប្រធានបទនេះ គឺនឹងធ្វើការសិក្សាស្រាវជ្រាវកម្រិត ពីសមត្ថកិច្ចអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នាសង្គមកម្ពុជាក្នុងពេលបច្ចុប្បន្ន ដែលស្របនឹងបទដ្ឋានគតិយុត្តជាធរមាននៃព្រះរាជាណាចក្រកម្ពុជា និងទាក់ទងនឹងសញ្ញាណនៃច្បាប់ជាតិ នឹងអន្តរជាតិក្នុងការអនុវត្តក៏ដូចជា តួនាទី ភារកិច្ច នៅក្នុងដំណាក់កាលនីមួយៗនៃកិច្ចនីតិវិធី, អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល របស់តួអង្គសំខាន់ក្នុងអង្គជំនុំជម្រះវិសាមញ្ញ។

## ៥. សារៈសំខាន់នៃប្រធានបទ

ចំពោះកម្រងសារណាសម្រាប់បញ្ចប់ថ្នាក់បរិញ្ញាបត្រនេះ គឺពិតជាមានសារៈសំខាន់ និងមានការលំបាកជាច្រើន ពីព្រោះ ខ្ញុំបាទបានចំណាយពេលវេលារយៈពេល ៦ (ប្រាំមួយ)ខែ នៅក្នុងការស្រាវជ្រាវ និងធ្វើការចងក្រង ព្រមទាំងបានចំណាយកម្លាំងចិត្ត និងការតស៊ូអំណត់ អត់ធ្មត់ ដោយសេចក្តីព្យាយាមផងដែរ។ សារណាមួយនេះ ក៏អាចក្លាយទៅជាស្ពាន ដែលមានសារៈសំខាន់បំផុតសម្រាប់ និស្សិតច្បាប់ និងអ្នកសិក្សាស្រាវជ្រាវដែលមានបំណងចង់សិក្សាស្វែងយល់អំពី សមត្ថកិច្ចរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលនឹងធ្វើការបកស្រាយ ដោយផ្សារភ្ជាប់ជាមួយនឹង ច្បាប់ជាតិ និងច្បាប់អន្តរជាតិ ដែលច្បាប់ជាតិមានដូចជា ក្រមនីតិវិធីព្រហ្មទណ្ឌ, ក្រមព្រហ្មទណ្ឌ, រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់ផ្សេងៗដែលជាប់ពាក់ព័ន្ធជាច្រើន ទៀតផង។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

វិធីសាស្ត្រនៃការស្រាវជ្រាវ សម្រាប់យើងខ្ញុំ បានប្រើប្រាស់នូវរាល់គ្រប់មធ្យោបាយ ទាំងទិដ្ឋភាពទម្រង់ ទិដ្ឋភាពខ្លឹមសារ និងវិធីសាស្ត្រផ្សេងៗ ជាច្រើនដែលបានខិតខំប្រឹងប្រែងក្នុងការប្រមូលនូវឯកសារច្បាប់ផ្សេងៗដែលមានពាក់ព័ន្ធទៅនឹងប្រធានបទសារណាមួយនេះ។ ចំពោះឯកសារទាំងអស់នោះគឺមានប្រភពមកពីសៀវភៅច្បាប់មានច្បាប់ជាតិ និងច្បាប់អន្តរជាតិ,ការស្រាវជ្រាវតាមប្រព័ន្ធបច្ចេកវិទ្យាដែលមានតាមប្រព័ន្ធអនឡាញក៏ដូចជាសៀវភៅទ្រឹស្តីច្បាប់ផ្សេងៗព្រមទាំងមានការចូលរួមកែសម្រួលពីលោកគ្រូសាស្ត្រាចារ្យណែនាំសិស្សច្បង និងមិត្តរួមថ្នាក់ផងដែរ។ បន្ថែមពីនេះទៀតក៏បានចូលសិក្សាស្រាវជ្រាវនៅបណ្ណាល័យ

ដើម្បីជាប្រយោជន៍ក្នុងការស្វែងយល់ឱ្យកាន់តែច្បាស់ពីប្រធានបទសារណានេះក៏ដូចជាការបំពេញបន្ថែមទិដ្ឋភាពជាក់ស្តែង និង ការអនុវត្តសាលក្រមនៅក្នុងអ.វ.ត.ក ទៀតផង។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីឆ្លើយតបឱ្យកាន់តែស៊ីជម្រៅ និងក្បោះក្បាយនូវចំណោទបញ្ហាខាងលើនេះ ខ្ញុំបាទនឹងធ្វើការបែងចែក និងពន្យល់បកស្រាយដូចខាងក្រោមនេះ។

នៅក្នុងសារណាដែលសរសេរអំពីប្រធានបទ៖ **សមត្ថកិច្ចអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា** ខ្ញុំបាទបានបែងចែកជា បី ជំពូកគឺ៖

**ជំពូកទី១៖ ទិដ្ឋភាពស្ថាប័នរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

- ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញាក្នុងតុលាការកម្ពុជាក្នុងរយៈកាល
- រចនាសម្ព័ន្ធក្នុងតុលាការ

**ជំពូកទី២៖ លក្ខណៈដោយឡែករបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

- ប្រៀបធៀបអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានិងតុលាការព្រហ្មទណ្ឌអន្តរជាតិ ICC
- យុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ជំពូកទី៣៖ សេចក្តីសម្រេច និងលទ្ធផលសម្រេចរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

- សំណុំរឿងសំខាន់ៗ និងមេដឹកនាំកំពូលដែលត្រូវកាត់ទោស
- សំណងទៅឱ្យជនរងគ្រោះ និង ការរក្សាទុកឯកសារជាប្រវត្តិសាស្ត្រ

# ជំពូកទី១
# និដ្ឋភាពស្ថាប័នរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

# ជំពូកទី១

# និដ្ឋភាពស្ថាប័នរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬហៅកាត់ថា អ.វ.ត.ក ជាគំរូតុលាការកូនកាត់ដែលត្រូវបានគេមើលឃើញថាជាមធ្យោបាយមួយដើម្បីផ្តល់ឱកាសឱ្យមានការចូលរួមនិងការពាក់ព័ន្ធយ៉ាងពេញទំហឹងពីសំណាក់ប្រជាជននិងមន្ត្រីកម្ពុជាទូទាំងប្រទេស នៅក្នុងដំណើរការកាត់ក្តីនេះ ហើយទន្ទឹមនឹងនេះ ធានាឱ្យបានតាមបទដ្ឋានអន្តរជាតិ។ សាលាក្តីនេះប្រព្រឹត្តទៅនៅប្រទេសកម្ពុជាហើយដំណើរការកាត់ក្តីត្រូវធ្វើឡើងភាគច្រើនជាភាសាខ្មែរនិងបើកចំហឱ្យមានការចូលរួមពីប្រជាជនកម្ពុជា និងត្រូវបានផ្សព្វផ្សាយតាមវិទ្យុទូរទស្សន៍និងសារព័ត៌មានក្នុងស្រុក។[3] អ.វ.ត.ក ក៏ត្រូវបានបង្កើតឡើងក្នុង គោលបំណងរកយុត្តិធម៌ជូនប្រជាពលរដ្ឋខ្មែរដែលបានទទួលរងទុក្ខវេទនានិងឈានដល់ការស្លាប់បាត់បង់ជីវិត ព្រមទាំងស្វែងរកយុត្តិធម៌ជូនរងគ្រោះដែលទទួលនូវទណ្ឌកម្ម ភាពអត់ស្រេកឃ្លាននាសម័យនោះប្រជាជនកម្ពុជាប្រមាណ ១,៧ លាននាក់ បានបាត់បង់ជីវិតដោយសារការ បង្អត់អាហារ ទារុណកម្ម ការសម្លាប់ និងការបង្ខំឱ្យធ្វើការហួសកម្លាំង ក្នុងរយៈពេល ៣ឆ្នាំ ៨ខែ ២០ថ្ងៃនៃរបបនោះ។ របបខ្មែរក្រហមបានឡើងកាន់អំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ហើយត្រូវទម្លាក់ពីអំណាច នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។[4] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលមានសមត្ថកិច្ចក្នុងការជំនុំជម្រះបទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តក្នុងកំឡុងរបប កម្ពុជាប្រជាធិបតេយ្យ និងតុលាការព្រហ្មទណ្ឌអន្តរជាតិ (International Criminal Court ) ICC មានការខុសគ្នាយ៉ាងខ្លាំង។ អង្គជំនុំជម្រះវិសាមញ្ញកម្ពុជា ត្រូវបានបង្កើតឡើងក្នុងគោលបំណងបញ្ចប់នូវនិទណ្ឌភាពនៃជនដែលបានប្រព្រឹត្តបទឧក្រិដ្ឋអន្តរជាតិនៅក្នុងអតីតកាល ចំណែកឯតុលាការព្រហ្មទណ្ឌអន្តរជាតិវិញមានគោលបំណងក្នុងការផ្តន្ទាទោសនូវរាល់បទឧក្រិដ្ឋអន្តរជាតិ ដែលត្រូវបានប្រព្រឹត្តក្រោយពីការចូលជាធរមាននៃលក្ខន្តិកៈទីក្រុងរ៉ូម។[5] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ត្រូវបានបង្កើតឡើងក្នុងគោលបំណងវិនិច្ឆ័យទោសមេដឹក នាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរលើច្បាប់ព្រហ្មទណ្ឌកម្ពុជាការរំលោភទៅ

---

[3] គេហទំព័រអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា,ហេតុអ្វីបានជាតុលាការប្រភេទនេះត្រូវបានយកមកប្រើសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា?https://www.eccc.gov.kh/km/faq/hetuqvii-paanjaa-tulaakaar-prbhed-neh-truuvpaan-ykmk-proe-smraap-qnggjmnumjmrh-visaamnyny-knung

[4] ផេង ពង្សរ៉ាស៊ី, ដេវីដ ឆេនដល័រ, គ្រីស្តូហ្វ័រ ឌៀរីង និង សុភ័ក្រ្ត ភាណា, សៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩) បោះពុម្ពលើកទី២ មជ្ឈមណ្ឌលឯកសារកម្ពុជា ២០២០, ទំព័រ១។

[5] របាយការតុលាការព្រហ្មទណ្ឌអន្តរជាតិ, FIDH, https://fidh.org/IMG/pdf/Rapport_FIDH_en_khmer.pdf.,ទំព័រ ៤៣។

លើច្បាប់មនុស្សធម៌អន្តរជាតិនិងទម្លាប់អន្តរជាតិព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាទទួលស្គាល់ហើយបានប្រព្រឹត្តក្នុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩។[6]

នៅឆ្នាំ ១៩៩៧ រាជរដ្ឋាភិបាលកម្ពុជាបានសំណូមពរឱ្យអង្គការសហប្រជាជាតិជួយឧបត្ថម្ភបង្កើតសាលាជម្រះក្ដីដើម្បី កាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម។ នៅឆ្នាំ២០០១ រដ្ឋសភាជាតិកម្ពុជា បានអនុម័តច្បាប់ស្ដីពីការបង្កើតតុលាការក្នុងស្រុកមួយ មានឈ្មោះថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការ កម្ពុជា (តុលាការកូនកាត់) នៅឆ្នាំ២០០៣ អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា បានឈានដល់កិច្ចព្រមព្រៀងទាក់ទងនឹងការកាត់ក្ដីនៅក្រោម ច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ និងអំពីនីតិវិធីដែលសហគមន៍អន្តរជាតិ អាចជួយនិងចូលរួមក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ អង្គជំនុំជម្រះវិសាមញ្ញនេះ នឹងក្លាយជាតុលាការកម្ពុជាដែលត្រូវបានបង្កើតឡើងក្រោមច្បាប់កម្ពុជា ដោយមានការចូលរួមនិងជំនួយពីអង្គការសហប្រជាជាតិ។[7] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាស្ថិតនៅក្នុងប្រព័ន្ធតុលាការកម្ពុជា ប៉ុន្តែ ត្រូវគោរពតាម កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់ក្ដីនៅក្រោម ច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ កិច្ចព្រមព្រៀងនេះបង្កើតឡើងក្នុងគោលបំណងកំណត់អំពីកិច្ចសហប្រតិបត្តិការរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាដើម្បីកាត់សេចក្ដីមេដឹកនាំជាន់ខ្ពស់កម្ពុជា ប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួល ខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភ ទៅលើច្បាប់មនុស្សធម៌អន្តរជាតិនិងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ហើយបានប្រព្រឹត្តក្នុងថ្ងៃ ១៧ មេសា ១៩៧៥ ដល់ថ្ងៃ ០៦ មករា ១៩៧៩ និង ផ្ដល់មូលដ្ឋានគតិយុត្តិគោលការណ៍ និងបែបបទសម្រាប់កិច្ចសហ ប្រតិបត្តិការនេះ។ កិច្ចព្រមព្រៀងនេះត្រូវអនុវត្តក្នុងប្រទេសកម្ពុជាតាមរយៈច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញនៅពេលអនុម័ត និងធ្វើវិសោធនកម្មរួច៉ ហើយត្រូវអនុវត្តតាមអនុសញ្ញា ទីក្រុងវីយែន ស្ដីពីច្បាប់នៃសន្ធិសញ្ញា ជាពិសេសមាត្រា២៦ និង ២៧។[8] ទោះជាយ៉ាងនេះក្ដី តុលាការនេះមានលក្ខណៈពិសេសជាតុលាការ "កូនកាត់"។

---

[6] មាត្រា ១, ច្បាប់ស្ដីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ,លេខ នស/រកម/០៨០១/១២, ០៨ ខែតុលា ឆ្នាំ ២០០៤។

[7] សៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩), ទំព័រ៧៦។

[8] មាត្រា ២, កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់ក្ដីនៅក្រោម ច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ។

ច្បាប់ដែលយកមកអនុវត្តមានទាំងច្បាប់ជាតិនិងច្បាប់អន្តរជាតិនឹងត្រូវយកមកប្រើប្រាស់ក្នុងអង្គជំនុំជម្រះវិសាមញ្ញនេះសម្រាប់ធ្វើការវិនិច្ឆ័យកាត់ទោសមេដឹកនាំកំពូល និង ស្វែងរកយុត្តិធម៌ជូនជនរងគ្រោះ។[9]

## ១.១. ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក្នុងរយៈកាល

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) គឺជាតុលាការពិសេសមួយរបស់កម្ពុជាដែលទទួលបានការគាំទ្រពីមជ្ឈដ្ឋានអន្តរជាតិតាមរយៈអង្គការសហប្រជាជាតិ (UNAKRT)[10] តុលាការនេះត្រូវបានគេស្គាល់ថាជាតុលាការខ្មែរក្រហម ឬអង្គជំនុំជម្រះកម្ពុជា។[11] នៅខែមិថុនា ឆ្នាំ១៩៩៧ សហនាយករដ្ឋមន្ត្រី គឺ **សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ** និង **សម្តេច ហ៊ុន សែន** បានផ្ញើសារលិខិតមួយជូនលោក កូហ្វីអាណាន់ ដែលពេលនោះជាអគ្គលេខាធិការអង្គការសហប្រជាជាតិស្នើសុំជំនួយពីអង្គការសហប្រជាជាតិ ក្នុងដំណើរការជំនុំជម្រះក្តីឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ សហនាយករដ្ឋមន្ត្រីបានស្នើសុំជំនួយឧបត្ថម្ភខាងលើដោយយល់ឃើញថាវិស័យតុលាការនៅកម្ពុជានៅមានកង្វះខាតធនធាន រួមមានផ្នែកច្បាប់ទាំងជាតិ និង អន្តរជាតិ និងជាពិសេសគឺយុត្តាធិការកាត់ក្តីនេះត្រូវមានការទទួលស្គាល់ទូទាំងថ្នាក់ជាតិ និងលើឆាកអន្តរជាតិ ដោយសារឧក្រិដ្ឋកម្មដែលកើតឡើងមានទំហំធំធេង មិនអាចយកច្បាប់ក្នុងស្រុកមកធ្វើការកាត់ក្តីទាំងស្រុងនោះទេ។ មួយវិញទៀតប្រទេសកម្ពុជា ក៏ជាសមាជិករបស់អង្គការសហប្រជាជាតិផងដែរ ដូចនេះការសុំជំនួយ និងការផ្តល់ជំនួយជាការជ្រើសល្អក្នុងការបង្កើតុលាការកូនកាត់ ខ្មាតអន្តរជាតិ។ អង្គការសហប្រជាជាតិបានផ្តល់ជំនួយបច្ចេកទេសដល់ អ.វ.ត.ក តាមរយៈការជួយរៀបចំនិងជ្រើសរើសចៅក្រម និងបុគ្គលិកអន្តរជាតិ តាមរយៈជំនួយអង្គការសហប្រជាជាតិសម្រាប់សាលាក្តីខ្មែរក្រហម។[12]

តុលាការនេះមានឈ្មោះថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (អង្គជំនុំជម្រះវិសាមញ្ញ ឬ អ.វ.ត.ក) ។ រាជរដ្ឋាភិបាលកម្ពុជាបានទទូចសុំថាដើម្បីជាផលប្រយោជន៍ដល់ប្រជាជនកម្ពុជាទាំងអស់តុលាការជម្រះក្តីត្រូវប្រព្រឹត្តទៅនៅក្នុងប្រទេសកម្ពុជាដោយប្រើប្រាស់មន្ត្រីនិងចៅក្រមកម្ពុជាគួបផ្សំជាមួយមន្ត្រីនិងចៅក្រមអន្តរជាតិ។ កម្ពុជាបានអញ្ជើញ

---

[9] គេហទំព័រអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, https://www.eccc.gov.kh/km/faq/toe-qnggjmnumjmrh-visaamnyny-knung-tulaakaar-kmbujaa-jaa-tulaakaar-kmbujaa-ryyjaa-tulaakaar

[10] គេហទំព័រ អង្គការសហប្រជាជាតិ និងតុលាការខ្មែរក្រហម, https://www.unakrt-online.org

[11] គេហទំព័រអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, ការណែនាំអំពី អ.វ.ត.ក, https://www.eccc.gov.kh/km/kaarnnaenaamqmbii-qvtk

[12] គេហទំព័រអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា,ហេតុអ្វីបានជាអង្គការសហប្រជាជាតិចូលរួមក្នុងដំណើរការនេះ?, https://www.eccc.gov.kh/km/faq/hetuqviipaanjaaqnggkaarshprjaajaaticuulruamknungtmnnoerkaarneh

សហគមន៍អន្តរជាតិឱ្យចូលរួមសហការក្នុងការកាត់សេចក្តីនេះដើម្បីធានាឱ្យមានយុត្តិធម៌ជាលក្ខណៈអន្តរជាតិ ព្រោះកម្ពុជាយល់ឃើញថាខ្លួននៅទន់ខ្សោយផ្នែកតុលាការ និងចរិតលក្ខណៈអន្តរជាតិនៃឧក្រិដ្ឋកម្ម ។

ចុងបញ្ចប់កិច្ចព្រមព្រៀងមួយជាមួយអង្គការសហប្រជាជាតិត្រូវបានចុះហត្ថលេខានៅខែមិថុនា ឆ្នាំ២០០៣ ដែលចែងអំពីថាតើសហគមន៍អន្តរជាតិនឹងជួយឧបត្ថម្ភនិងសហការរបៀបដូចម្តេចនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញនេះ។ តុលាការថ្មីហើយពិសេសនេះ ត្រូវបានបង្កើតឡើងដោយរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិ ប៉ុន្តែតុលាការនេះគឺជាតុលាការឯករាជ្យម្ចាស់ការមិនចំណុះរាជរដ្ឋាភិបាលឬអង្គការសហប្រជាជាតិទេ។ តុលាការនេះគឺជាតុលាការកម្ពុជាដែលមានការចូលរួមពីសហគមន៍អន្តរជាតិដែលនឹងអនុវត្តទៅតាមស្តង់ដារអន្តរជាតិ។ តុលាការនេះនឹងផ្តល់ជាគំរូថ្មីមួយសម្រាប់ដំណើរការកាត់ក្តីនៅកម្ពុជា[13] ពិសេសនោះភាសាការងារដែលប្រើប្រាស់ជាផ្លូវការនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺជាភាសាខ្មែរ ភាសាអង់គ្លេស និង ភាសាបារាំង។[14]

### ១.១.១ រចនាសម្ព័ន្ធនៃប្រព័ន្ធតុលាការអង្គជំនុំជម្រះវិសាមញ្ញ

#### ១.១.១.១ ផ្នែកតុលាការនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ

អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងរចនាសម្ព័ន្ធតុលាការដែលមានស្រាប់ពោលគឺសាលាដំបូង និងតុលាការកំពូលដើម្បីជំនុំជម្រះមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយ ដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់កម្ពុជាដែលពាក់ព័ន្ធនឹងអំពើឧក្រិដ្ឋការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិនិងទម្លាប់អន្តរជាតិ និងការរំលោភទៅលើអនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាទទួល ស្គាល់ហើយដែលបានប្រព្រឹត្តិក្នុងអំឡុងថ្ងៃ ១៧ មេសា ១៩៧៥ ដល់ថ្ងៃ ៦ មករា ១៩៧៩។ មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះអំពើឧក្រិដ្ឋខាងលើនេះហៅថា"ជនសង្ស័យ"។[15]

- **អង្គបុរេជំនុំជម្រះ**

អង្គបុរេជំនុំជម្រះ មានភារកិច្ចជំនុំជម្រះក្តីពាក់ព័ន្ធនឹងសំណើរសុំ និងបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចណាមួយរបស់សហចៅក្រមស៊ើបអង្កេត ក្នុងអំឡុងពេលដែលសំណុំរឿងកំពុងស្ថិតក្នុងដំណាក់កាលស៊ើបអង្កេត។ អង្គបុរេជំនុំជម្រះមានចៅក្រមជាតិចំនួនបីរូប និងចៅក្រមអន្តរជាតិពីររូបហើយរាល់ការសម្រេចចិត្តត្រូវតែមានការអនុម័តពីចៅក្រមយ៉ាងតិចបួនរូប។[16]

---

[13] គេហទំព័រអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, ការណែនាំអំពី អ.វ.ត.ក, https://www.eccc.gov.kh/km/kaarnnaenaamqmbii-qvtk

[14] មាត្រា៤៥ ថ្មី, ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

[15] មាត្រា ២ថ្មី , ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

[16] គេហទំព័រអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, ផ្នែកតុលាការ,កថាខណ្ឌទី១, https://www.eccc.gov.kh/km/node/12087

❖ **អង្គជំនុំជម្រះសាលាដំបូង**

សេចក្ដីសន្និដ្ឋានលើដំណើរការស៊ើបអង្កេតសំណុំរឿងមួយ ប្រសិនបើសំណុំរឿងត្រូវបានបញ្ជូនទៅជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង នឹងបើកសវនាការជំនុំជម្រះក្ដី។ អង្គជំនុំជម្រះសាលាដំបូងនឹងសម្រេចថាតើជនជាប់ចោទមានទោសឬមិនមានទោស ដោយផ្អែកទៅលើសក្ខីកម្មរបស់សាក្សី ភស្តុតាង និងអំណះអំណាងរបស់ភាគីនីមួយៗនៅក្នុងតុលាការ។ អង្គជំនុំជម្រះសាលាដំបូងមានចៅក្រមជាតិបីរូប និងចៅក្រមអន្តរជាតិពីររូបហើយការចេញសាលក្រមត្រូវតែមានការអនុម័តពីចៅក្រមយ៉ាងតិចបួនរូប។[17]

❖ **អង្គជំនុំជម្រះតុលាការកំពូល**

អង្គជំនុំជម្រះតុលាការកំពូលនឹងជំនុំជម្រះក្ដីលើ បណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រម ឬសេចក្ដីសម្រេចចិត្តដែលចេញដោយអង្គជំនុំជម្រះសាលាដំបូង។ មានចៅក្រមជាតិបួនរូបនិងចៅក្រមអន្តរជាតិបីរូបនៅអង្គជំនុំជម្រះតុលាការកំពូលហើយរាល់ការសម្រេចចិត្តនៅក្នុងអង្គជំនុំជម្រះតុលាការកំពូលត្រូវតែមានការអនុម័តពីចៅក្រមយ៉ាងតិចប្រាំរូប។[18]

**១.១.១.២. សមាសភាពអង្គជំនុំជម្រះវិសាមញ្ញ**

សាលាដំបូងជាអង្គជំនុំជម្រះវិសាមញ្ញដោយចៅក្រមវិជ្ជាជីវៈប្រាំរូបដែលរួមមានចៅក្រមខ្មែរបីរូប មួយរូបធ្វើជាប្រធាន និងមានចៅក្រមបរទេសពីររូប និងមានក្រឡាបញ្ជីមួយរូប ឬច្រើនរូប តាមការចាត់តាំងរបស់ប្រធានចូលរួមព្រមទាំងមានសហព្រះរាជអាជ្ញាដែលត្រូវដាក់ពាក្យប្ដឹងនៅចំពោះមុខសាលាដំបូងនេះ។[19]

តុលាការកំពូលដែលជាកន្លែងទទួលពាក្យបណ្ដឹងឧទ្ធរណ៍ផងនិងសម្រេចសេចក្ដីចុងក្រោយផង ជាអង្គជំនុំជម្រះវិសាមញ្ញដោយចៅក្រមប្រាំពីររូប ដែលរួមមានចៅក្រមខ្មែរបួនរូបដែលមួយរូបធ្វើជាប្រធាន និងចៅក្រមបរទេសបីរូប និងមានក្រឡាបញ្ជីមួយរូប ឬច្រើនរូបតាមការចាត់តាំងរបស់ប្រធានចូលរួមព្រមទាំង មានសហព្រះរាជអាជ្ញាដែលត្រូវដាក់ពាក្យប្ដឹងនៅចំពោះមុខតុលាការកំពូលនេះ ។[20]

## ១.២ តួនាទីតាមការិយាល័យនៅក្នុងអង្គជំនុំជម្រះ

ជាការពិតណាស់នៅក្នុងសាប័នតុលាការ មិនអាចខ្វះតួអង្គសំខាន់ៗ តាមតួនាទីឡើយ មិនថាតុលាការជាតិ ឬតុលាការអន្តរជាតិនោះទេ។ អ្វីដែលពិសេសនៅចំណុចតុលាការកូនកាត់នេះ បានមានបែងចែកការិយាល័យទទួលបន្ទុកការងារ ទៅតាមផ្នែកសំខាន់ៗដែល។

[17] ផ្នែកតុលាការ,កថាខណ្ឌទី២, https://www.eccc.gov.kh/km/node/12087

[18] ផ្នែកតុលាការ,កថាខណ្ឌទី៣, https://www.eccc.gov.kh/km/node/12087

[19] មាត្រា ៩ថ្មី ,កថាខណ្ឌទី១, ច្បាប់ស្ដីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

[20] មាត្រា ៩ថ្មី ,កថាខណ្ឌទី២, ច្បាប់ស្ដីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

ពិសេសក្នុងនោះ ចៅក្រម និងព្រះរាជអាជ្ញាទាំងអស់ សុទ្ធតែឆ្លងកាត់ការជ្រើសរើស និង មានការតែងតាំងដោយព្រះរាជក្រឹត។[21]

### ១.២.១ ការិយាល័យសហចៅក្រមស៊ើបអង្កេត

ការស៊ើបអង្កេតនៅចំពោះមុខ អ.វ.ត.ក រួមមានពីរដំណាក់កាលៈ

- **ការស៊ើបអង្កេតបឋមដោយសហព្រះរាជអាជ្ញា**

តាមការផ្តួចផ្តើមដោយខ្លួនឯង ឬដោយមានសំណើពីភាគីណាមួយសហព្រះរាជអាជ្ញានឹងធ្វើការស៊ើបអង្កេតបឋម ដើម្បីសម្រេចថាតើមានភ័ស្តុតាងដែលបង្ហាញថា បទឧក្រិដ្ឋនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក អាចត្រូវបានប្រព្រឹត្ត ឬយ៉ាងណា និងដើម្បីកំណត់អត្តសញ្ញាណអ្នកដែលអាចជាជនសង្ស័យ និងសាក្សី។ ប្រសិនបើសហព្រះរាជអាជ្ញាមានសំអាងហេតុដែលអាចជឿបានថាបទឧក្រិដ្ឋដែលស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក ត្រូវបានប្រព្រឹត្តនោះសហព្រះរាជអាជ្ញានឹងបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ទៅសហចៅក្រមស៊ើបអង្កេត ដោយរៀបរាប់នូវអង្គហេតុបទល្មើសដែលត្រូវបានចោទប្រកាន់ច្បាប់ជាធរមាន និងឈ្មោះបុគ្គលដែលត្រូវបានស៊ើបអង្កេត ប្រសិនបើដឹងពីបុគ្គលនោះរួចហើយ។ សហព្រះរាជអាជ្ញាក៏ដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ដែរប្រសិនបើមានលេចឡើងនូវអង្គហេតុថ្មីដែលតម្រូវឱ្យកែសម្រួល ឬបន្ថែមទៅលើការចោទប្រកាន់ពីមុនៗ។

- **ការស៊ើបអង្កេតដោយសហចៅក្រមស៊ើបអង្កេត**

សហចៅក្រមស៊ើបអង្កេតស៊ើបអង្កេតទៅលើអង្គហេតុនានាដែលមានរៀបរាប់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។ សហចៅក្រមស៊ើបអង្កេតមិនត្រូវស៊ើបអង្កេតទៅលើអង្គហេតុថ្មីទេលើកលែងតែក្នុងករណីពួកគាត់បានទទួលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទាក់ទិននឹងបញ្ហានោះពីសហព្រះរាជអាជ្ញាជាមុនសិន។ សហចៅក្រមស៊ើបអង្កេតមានសិទ្ធិអំណាចក្នុងការចោទប្រកាន់បុគ្គលណាម្នាក់បានប្រសិនបើមានភ័ស្តុតាងច្បាស់លាស់ និងស្របគ្នាដែលបង្ហាញថាបុគ្គលនោះអាចទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះការប្រព្រឹត្តិបទឧក្រិដ្ឋដែលបានលើកឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។ ក្នុងអំឡុងពេលស៊ើបអង្កេតសហព្រះរាជអាជ្ញាជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណីអាចស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតពិចារណាក្នុងការចេញដីកាបង្គាប់ជាក់លាក់ឬបើកកិច្ចស៊ើបសួរដែលសហចៅក្រមស៊ើបអង្កេតយល់ថាជាការចាំបាច់សម្រាប់ដំណើរការស៊ើបអង្កេត។[22]

---

[21] ព្រះរាជក្រឹតស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកត/០៧០៤/១២៤, ១៥ ខែកក្កដា ឆ្នាំ២០០៤។

[22] សហចៅក្រមស៊ើបអង្កេតរួមមានៈ ចៅក្រម យូ ប៊ុនឡេង (កម្ពុជា) ជាសហចៅក្រមស៊ើបអង្កេតជាតិ និង ចៅក្រម Michael Bohlander (អាល្លឺម៉ង់) ជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិ។

សំណុំរឿងចំនួនពីរដែលស្ថិតក្រោមការស៊ើបអង្កេតដែលគេហៅជាទូទៅថាជាសំណុំរឿង ០០៣ សំណុំរឿង ០០៤ សំណុំរឿង ០០៤/០១ និង សំណុំរឿង ០០៤/០២ ដែលពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មសង្គ្រាមឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងបទប្រល័យពូជសាសន៍រួមទាំងបទឧក្រិដ្ឋនានាតាមច្បាប់កម្ពុជាផង។[23]

### ១.២.២. ការិយាល័យសហព្រះរាជអាជ្ញា

ការិយាល័យសហព្រះរាជអាជ្ញា (ក.ស.ព) គឺជាការិយាលយ័ឯករាជ្យមួយនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(អ.វ.ត.ក)។ ក.ស.ព អនុវត្តកាតព្វកិច្ចរបស់ខ្លួនដោយគ្មានការជ្រៀតជ្រែកពីរដ្ឋាភិបាល ឬស្ថាប័នណាមួយឡើយ។ តួនាទីរបស់ ក.ស.ព គឺដើម្បីចោទប្រកាន់មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ។ ក.ស.ព បើកការស៊ើបអង្កេតបឋម ធ្វើការចោទប្រកាន់ ចាត់ការលើបណ្តឹងរបស់ជនរងគ្រោះចូលរួមនៅក្នុងកិច្ចស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេតដំណាក់កាលអង្គ បុរេជំនុំជម្រះ អង្គជំនុំជំនុំជម្រះសាលាដំបូង និងតុលាការកំពូល។ ក.ស.ព មានសហប្រធានដឹកនាំដោយសហព្រះរាជអាជ្ញាកម្ពុជាមួយរូប និងសហព្រះរាជអាជ្ញាអន្តរជាតិមួយរូប និងមានបុគ្គលិកជាតិនិងអន្តរជាតិមួយចំនួនរួមទាំងកម្មសិក្សាការីផង។

កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា (ដែលបានបង្កើត អ.វ.ត.ក) យល់ព្រមឱ្យមានព្រះរាជអាជ្ញាខ្មែរមួយរូបនិងព្រះរាជអាជ្ញាអន្តរជាតិមួយរូបដែលបំពេញតួនាទីជាសហព្រះរាជអាជ្ញា។ សហព្រះរាជអាជ្ញាកម្ពុជាត្រូវបានជ្រើសតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមកម្ពុជាហើយសហព្រះរាជអាជ្ញាអន្តរជាតិត្រូវបានជ្រើសតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមកម្ពុជា ក្រោយពីការជ្រើសរើសឱ្យឈរឈ្មោះដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ។[24]

ការប្រកាន់ភ្ជាប់នូវតុលាការកូនកាត់និងគោរពតាមកំណត់ការចូលរួមដោយ ត្រូវមានចៅក្រមជម្រះក្តីខ្មែរ និងបរទេស ចៅក្រមស៊ើបអង្កេតខ្មែរ និងបរទេស ឬ ព្រះរាជអាជ្ញាខ្មែរ និងបរទេស។ នៅក្នុងករណីគ្មានចៅក្រមជម្រះក្តី ចៅក្រមស៊ើបអង្កេត ឬព្រះរាជអាជ្ញាបរទេស៖ ដើម្បីធានាការអនុវត្តច្បាប់នេះបានទាន់ពេលវេលា និងមិនរអាក់រអួល ក្នុងករណីដែលចៅក្រមជម្រះក្តី ឬចៅក្រមស៊ើបអង្កេត ឬព្រះរាជអាជ្ញាបរទេសណាមួយមិនបានចូលរួម ឬបដិសេធមិនចូលរួមក្នុងអង្គជំនុំជម្រះវិសាមញ្ញ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជ្រើសតាំងចៅក្រមជម្រះក្តី ឬចៅក្រមស៊ើបអង្កេត ឬព្រះរាជអាជ្ញាផ្សេង ទៀតឱ្យបំពេញកន្លែងទំនេរក្នុងចំណោមបញ្ជី

[23] គេហទំព័រអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា,ការិយាល័យសហចៅក្រមស៊ើបអង្កេត,https://www.eccc.gov.kh/km/organs/kaariyaalyshcaukrmsoepqngket

[24] គេហទំព័រអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា,ការិយាល័យសហព្រះរាជអាជ្ញា,https://www.eccc.gov.kh/km/organs/kaariyaalyshbrhraajqaajnyaa

បេក្ខជនបរទេសដែលមានចែងក្នុងមាត្រា១១ ថ្មី, ១៨ ថ្មី និងមាត្រា២៦ នៃច្បាប់នេះ។ ក្នុងករណីដែលឈ្មោះក្នុងបញ្ជីត្រូវបានប្រើអស់ ហើយលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ពុំបានផ្តល់បញ្ជីឈ្មោះបេក្ខជនថ្មីបន្ថែម ឬក្នុងករណីដែលអង្គការសហប្រជាជាតិដកការគាំទ្រពីអង្គជំនុំជម្រះវិសាមញ្ញ កន្លែងទំនេរទាំងនោះត្រូវបំពេញបន្ថែម ដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ពីបណ្តាបេក្ខជនដែលបានស្នើឡើង ដោយរាជរដ្ឋាភិបាលនៃបណ្តារដ្ឋជាសមាជិកនៃអង្គការសហប្រជាជាតិទៀត។

ក្នុងចំណោមឥស្សរជនច្បាប់បរទេសដទៃ បន្ទាប់ពីអនុវត្តនីតិវិធីនេះហើយ បើនៅតែគ្មានចៅក្រមជម្រះក្តី ឬចៅក្រមស៊ើបអង្កេត ឬព្រះរាជអាជ្ញាចូលរួមក្នុងការងាររបស់អង្គជំនុំជម្រះវិសាមញ្ញ ហើយគ្មានបេក្ខជនបរទេសណាត្រូវបានជ្រើសរើសបរទេសឱ្យបំពេញតំណែងទំនេរនេះទេនៅពេលនោះ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមអាចជ្រើសតាំងចៅក្រមជម្រះក្តី ឬចៅក្រមស៊ើបអង្កេត ឬព្រះរាជអាជ្ញាខ្មែរជំនួស ។[25]

**១.២.៣. អង្គភាពគាំពារជនរងគ្រោះ**

ការបង្កើតថ្មីមួយក្នុងចំណោមការបង្កើតថ្មីៗជាច្រើនរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) គឺការទទួលស្គាល់កាន់តែខ្លាំងចំពោះជនរងគ្រោះនៅក្នុងដំណើរការនីតិវិធីរបស់ខ្លួន។ ជនរងគ្រោះនៃឧក្រិដ្ឋកម្មនានាដែលស្ថិតក្នុងយុត្តាធិការរបស់តុលាការនេះ ទទួលបានតួនាទីជាសារវ័ន្តនៅអ.វ.ត.ក។ ជនរងគ្រោះអាចដាក់ពាក្យបណ្តឹងទៅសហព្រះរាជអាជ្ញាដែលយកផលប្រយោជន៍របស់ជនរងគ្រោះទៅពិចារណានៅពេលដែលខ្លួនគិតថាត្រូវផ្តួចផ្តើមការចោទប្រកាន់ឬយ៉ាងណានោះ។ ជនរងគ្រោះក៏អាចចូលរួមក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណីផងដែរ។

ក្នុងតួនាទីនេះ ជនរងគ្រោះត្រូវបានទទួលស្គាល់ជាភាគីក្នុងដំណើរការនីតិវិធី និងត្រូវបានអនុញ្ញាតឲ្យទាមទារសំណងផ្លូវចិត្ត និងសមូហភាព។ ការទទួលស្គាល់បែបនេះឆ្លុះបញ្ចាំងនូវការប្តេជ្ញាចិត្តរបស់អ.វ.ត.ក ចំពោះអាណត្តិរបស់ខ្លួន ក្នុងការជួយដល់ប្រជាជនកម្ពុជាស្វែងរកយុត្តិធម៌ និងការផ្សះផ្សារជាតិ ដូចមានចែងក្នុងបុព្វកថានៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្ត ឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ។[26]

---

[25] មាត្រា ៤៦ថ្មី, ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

[26] គេហទំព័រអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, អង្គភាពគាំពារជនរងគ្រោះ ,https://www.eccc.gov.kh/km/organs/qnggbhaabgaambaarjnrnggrooh

### ១.២.៤. សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី

ផ្នែកសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបានបង្កើតឡើងដោយអនុលោមតាមវិធាន ១២ និងវិធាន ១២ ស្ទួន នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក.។ វាមានភាពស្វយ័តទាក់ទងនឹងបញ្ហាសំខាន់ៗដែលទាក់ទងនឹងដើមបណ្ដឹងរដ្ឋប្បវេណី។

សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីម្នាក់និងជនជាតិខ្មែរម្នាក់ ហើយពួកគេត្រូវបានគាំទ្រដោយមន្ត្រីច្បាប់និងអ្នកគ្រប់គ្រងសំណុំរឿង។ ពួកគេត្រូវធ្វើសកម្មភាពរួមគ្នាក្នុងគ្រប់ករណីទាំងអស់លុះត្រាតែពួកគេបានសម្រេចចិត្តរួមគ្នាប្រគល់សិទ្ធិដល់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីដើម្បីដោះស្រាយបញ្ហាណាមួយ។

សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីត្រូវធានាឱ្យមានការរៀបចំឱ្យមានប្រសិទ្ធិភាពតំណាងតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្នុងដំណាក់កាលជំនុំជម្រះនិងដំណាក់កាលជំនុំជម្រះ។ ពួកគេមានការទទួលខុសត្រូវខ្ពស់ចំពោះតុលាការសម្រាប់ការតស៊ូមតិទូទៅយុទ្ធសាស្ត្រនិងការបង្ហាញនៅក្នុងតុលាការនៃផលប្រយោជន៍របស់ក្រុមដើមបណ្ដឹងរដ្ឋប្បវេណីរួមគ្នាក្នុងដំណាក់កាលជំនុំជម្រះនិងលើសពីនេះ។ សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបំពេញភារកិច្ចរបស់ខ្លួនដោយការពិគ្រោះយោបល់យ៉ាងជិតស្និទ្ធជាមួយមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីដែលតំណាងឱ្យដើមបណ្ដឹងរដ្ឋប្បវេណីដែលបានទទួលស្គាល់។[27]

ភាពខុសគ្នារវាងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី និង មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមុនពេលមានសវនាការ ដើមបណ្ដឹងរដ្ឋប្បវេណីចូលរួមក្នុងដំណើរការតុលាការជាលក្ខណៈបុគ្គលហើយពួក គាត់មានសិទ្ធិទទួលបានមេធាវីធ្វើជាតំណាង។នៅពេលដែលសំណុំរឿងក្ដីឈានដល់ដំណាក់កាលសវនាការ ដើមបណ្ដឹងរដ្ឋប្បវេណីនឹងត្រូវរួមបញ្ចូលគ្នា ជាក្រុមៗហើយតំណាងដោយសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។ នៅក្នុងដំណាក់កាលនេះ មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីនឹងដើរតួនាទីជាភ្នាក់ងារសម្រាប់ភ្ជាប់ទំនាក់ទំនងរវាងដើមបណ្ដឹង រដ្ឋប្បវេណីម្នាក់ៗ និងផ្ដល់ជំនួយដល់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។[28]

### ១.២.៥ ការិយាល័យរដ្ឋបាល

ការិយាល័យរដ្ឋបាលមានតួនាទីជួយគាំទ្រនិងសម្របសម្រួលដល់កិច្ចដំណើរការតុលាការ តាមរយៈការផ្ដល់សេវាកម្មប្រកបដោយប្រសិទ្ធិភាព មានការសន្សំសំចៃ និងមានការសម្របសម្រួលល្អ។

---

[27] គេហទំព័រអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី, https://www.eccc.gov.kh/km/organs/shmedhaaviinaammukhtmnnaangtoempnntyngrttthppvennii
[28] សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។

ប្រធាននិង អនុប្រធានទាំងពីររូប[29] រួមគ្នាផ្តល់កិច្ចសម្របសម្រួលទូទៅ និងការណែនាំសម្រាប់ផ្នែកនិងអង្គភាពផ្សេងៗនៅក្រោមចំណុះការិយាល័យរដ្ឋបាលដើម្បីធានានូវការគាំទ្រពេញទំហឹងដល់ដំណើរការតុលាការ។ ប្រធាននិងអនុប្រធានទាំងពីររូបក៏ទទួលបន្ទុកផងដែរលើទំនាក់ទំនងជាមួយនឹងភាគីពាក់ព័ន្ធជាមួយកិច្ចព្រមព្រៀង និងសហគមន៍អ្នកផ្តល់ជំនួយ។ អ្នកទាំងពីរក៏មានការជួយជ្រោមជ្រែងពីមន្ត្រីច្បាប់របស់ខ្លួនដែលផ្តល់ការណែនាំអំពីក្របខណ្ឌច្បាប់ដែលអាចអនុវត្តបាន ព្រមទាំងធ្វើសេចក្តីព្រាងនិងពិនិត្យឡើងវិញរាល់ឯកសារផ្លូវការទាំងអស់។[30]

[29] ការិយាល័យរដ្ឋបាលស្ថិតនៅក្រោមការដឹកនាំរបស់ ឯកឧត្តម ក្រាញ់ តូនី ជាប្រធានស្តីទី និងលោក Knut Rosandhaug ជាអនុប្រធាន ។

[30] គេហទំព័រអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, ការិយាល័យរដ្ឋបាល, https://www.eccc.gov.kh/km/organs/kaariyaalyrttthpaal

# ជំពូកទី២
# លក្ខណៈដោយឡែករបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

# ជំពូកទី២

## លក្ខណៈដោយឡែករបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាស្ថិតនៅក្នុងប្រព័ន្ធតុលាការកម្ពុជា។ តុលាការនេះ មានលក្ខណៈពិសេសជាតុលាការ "កូនកាត់"។ បុគ្គលិកក្នុងតុលាការរួមមាន ចៅក្រម ព្រះរាជអាជ្ញា និងមេធាវីការពារក្ដី ទាំងជាតិ និងអន្តរជាតិ។ ទោះជាយ៉ាងណា មន្ត្រីភាគច្រើនបម្រើការនៅក្នុងតុលាការនេះគឺបុគ្គលិកកម្ពុជា។ ទាំងច្បាប់ជាតិ និងច្បាប់អន្តរជាតិនឹងត្រូវយកមកប្រើប្រាស់ក្នុងអង្គជំនុំជម្រះវិសាមញ្ញនេះ។[31] អ.វ.ត.ក ជាសាលាក្ដីមួយក្នុងចំណោម សាលាក្ដីកូនកាត់ប្រាំមួយ ដែលត្រូវបានបង្កើតឡើងរួមគ្នាដោយរដ្ឋាភិបាលប្រទេសសាមីនានា និងអង្គការសហប្រជាជាតិ ដើម្បីជំនុំជម្រះឧក្រិដ្ឋជនជាប់ចោទពីអំពើឃោរឃៅទ្រង់ទ្រាយធំនានា។ សាលាក្ដីទាំងនេះ ត្រូវបានបង្កើតឡើងនៅ ទីម័រខាងកើត កូសូវ៉ូ បូស្នី សៀរ៉ាឡេអូន និងនៅទីក្រុងឡាអេ សម្រាប់ឡេបាណន់ បន្ថែមទៅលើសាលាក្ដីពិសេសអន្តរជាតិពេញលេញចំនួនពីរ ដែលត្រូវបានបង្កើតឡើងសម្រាប់អតីតយូហ្គោស្លាវី និងរវ៉ាន់ដា។ សាលាក្ដីខ្មែរក្រហម ជាតុលាការទីមួយ ដែលត្រូវបានបង្កើតឡើងនៅក្នុងសមាគមប្រជាជាតិ អាស៊ីអាគ្នេយ៍ (ASEAN) សម្រាប់គោលបំណងនេះ និង បង្ហាញនូវការប្ដេជ្ញាដ៏ទូលំទូលាយរបស់រាជរដ្ឋាភិបាល កម្ពុជាចំពោះយុត្តិធម៌អន្តរជាតិ ដោយសារកម្ពុជាគឺជាប្រទេសតែមួយគត់នៅក្នុង ASEAN ដែលបានផ្ដល់សច្ចាប័ន ចំពោះលក្ខន្តិកៈទីក្រុងរ៉ូមស្ដីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ។[32] ចំណុចពិសេសទៀតនោះគឺ តុលាការព្រហ្មទណ្ឌអន្តរជាតិ និងតុលាការយុត្តិធម៌អន្តរជាតិមានក្នុងសម័យនោះប៉ុន្តែ តុលាការទាំងនោះ អាចបើកសវនាការនិងដោះស្រាយតែករណីដែលពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋ ដែលបានប្រព្រឹត្តនៅក្រោយពេលបង្កើតតុលាការនេះតែប៉ុណ្ណោះ។ រីឯតុលាការយុត្តិធម៌អន្តរជាតិជំនុំជម្រះក្ដីតែសំណុំរឿងរវាងរដ្ឋនិងរដ្ឋតែប៉ុណ្ណោះ។[33] ហេតុនេះហើយបានជាអតីតមេដឹកនាំខ្មែរក្រហមមិនត្រូវបានយកទៅជំនុំជម្រះក្នុងតុលាការឧក្រិដ្ឋកម្មអន្តរជាតិ (ICC) នៅទីក្រុងឡាអេ ឬក្នុងតុលាការយុត្តិធម៌អន្តរជាតិ (ICJ)។ ផ្ទុយទៅវិញអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អាចកាត់សេចក្ដីតែបុគ្គលណាដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មក្នុងរបបខ្មែរក្រហមតែប៉ុណ្ណោះ។ អ.វ.ត.ក មិនអាចកាត់ក្ដីប្រទេសឬ

[31] គេហទំព័រអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា,តើអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាជាតុលាការកម្ពុជាឬជាតុលាការអន្តរជាតិ?, https://www.eccc.gov.kh/km/about-eccc/faq

[32] គេហទំព័រអង្គការសហប្រជាជាតិសិទ្ធិមនុស្ស, https://cambodia.ohchr.org/kh/rule-of-law/promotion-eccc-legacy.

[33] គេហទំព័រអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, ហេតុអ្វីបានជាអតីតមេដឹកនាំខ្មែរក្រហមមិនត្រូវបានយកទៅជំនុំជម្រះក្នុងតុលាការឧក្រិដ្ឋកម្មអន្តរជាតិ (ICC) នៅទីក្រុងឡាអេ ឬក្នុងតុលាការយុត្តិធម៌អន្តរជាតិ(ICJ)?, https://www.eccc.gov.kh/km/about-eccc/faq

អង្គការណាដទៃទៀតបានឡើយ។[34] ច្បាប់នៃ អ.វ.ត.ក អនុញ្ញាតឱ្យមានការកាត់ទោសចំពោះឧក្រិដ្ឋកម្មដែលបានបង្កើតឡើងនៅក្នុងច្បាប់ ជាតិនិងអន្តរជាតិ រួមមាន ឧក្រិដ្ឋកម្មប្រឆាំងមនុស្ស ជាតិ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មសង្គ្រាម (ការបំពារបំពានយ៉ាង ធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ)[35]។

## ២.១ ការប្រៀបធៀបអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានិង តុលាការព្រហ្មទណ្ឌអន្តរជាតិ ICC

គ្រប់ក្នុងទិដ្ឋភាពច្បាប់ នៅពេលដែលច្បាប់មួយបានធ្វើកិច្ចព្រមព្រៀង ឬ បង្កើតថ្មីដែលយកគំរូតាមច្បាប់ដែលមានស្រាប់ និង ត្រាប់តាមនូវនីតិវិធី ឬយកនីតិវិធីមកប្រើប្រាស់ នោះពិតណាស់មិនមានភាពដូចគ្នាទាំសអស់នោះ ឡើយបន្ថែមពីនោះនិងមានភាពដូចគ្នា និងមិនដូចគ្នាជាមិនទាន់នោះទេ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ជាតុលាការកូនកាត់ និងក៏ជាតុលាការព្រហ្មទណ្ឌមានលក្ខណៈជាតិ និងអន្តរជាតិនៅក្នុងនោះ ហេតុនេះភាពដូចគ្នា និង មិនដូចគ្នាជាចំណុចពិសេស ឬភាពខ្លាំងមួយរបស់កម្ពុជាដែលមានយុត្តាធិការនៅក្នុងដែនដីខ្លួន។

### ២.១.១ ភាពដូចគ្នារវាងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងតុលាការព្រហ្មទណ្ឌអន្តរជាតិផ្សេងទៀត

ជាទូទៅនៅក្នុងប្រព័ន្ធតុលាការមួយដែលមានគោលបំណង តែមួយក្នុងការស្វែងរកការពិតនូវភាពពីបទល្មើសដែល ជាបទឧក្រិដ្ឋកម្មរួមមាន បទប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម។ តុលាការព្រហ្មទណ្ឌអន្តរជាតិនេះ មានបង្កើតសម្រាប់ការទោស ជនល្មើសដែលបានប្រព្រឹត្តកម្មធ្ងន់ធ្ងរបំផុត។ បន្ថែមពីនេះការលេចឡើងនូវ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលជាតុលាការថ្មីក្នុងប្រវត្តសាស្ត្រនោះដែលគ្រប់គ្នា បានដឹងលឺនូវ ការបង្កើតនេះ ជាសកលលោក ដែលកាត់ទោស ឧក្រិដ្ឋជន នាសម័យខ្មែរក្រហម។ ហេតុនេះយើងអាចសិក្សាបន្ថែមបាននូវយន្តការដោះស្រាយ និងការកាត់ទោសជនជាប់ចោទនៅក្នុងរឿងក្តីមានភាពដូចគ្នានិង ខុសគ្នាបែបណា រវាង អ.វ.ត.ក និង តុលាការព្រហ្មទណ្ឌអន្តរជាតិ ដើម្បីជាមូលដ្ឋានដឹងថាសមត្ថកិច្ចរបស់ អ.វ.ត.ក មានវិសាលភាពកំរិតណា បើប្រៀបទៅនឹងតុលាការព្រហ្មទណ្ឌអន្តរជាតិ។

---

[34] គេហទំព័រអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា,តើបណ្តាប្រទេសដែលធ្លាប់បានគាំទ្រ ឬក៏ជាប់ពាក់ព័ន្ធជាមួយកម្ពុជាប្រជាធិបតេយ្យ ឬក៏បណ្តាប្រទេសដែលប្រហែលជាបានប្រព្រឹត្តឧក្រិដ្ឋកម្មសង្គ្រាមនៅកម្ពុជា មុនឆ្នាំ១៩៧៥ នឹងត្រូវកាត់ទោសដែរឬទេ?, https://www.eccc.gov.kh/km/about-eccc/faq

[35] មាត្រា ៣ថ្មី ដល់មាត្រា ៨, ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

**២.១.១.១. កំណត់បទល្មើស និង ភាពគ្មានអាជ្ញាយុកាលនៃបទល្មើស**

ការកំណត់បទល្មើស នៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិ និង ក្នុង អ.វ.ត.ក មានលក្ខណៈដូចគ្នា ដោយមូលហេតុថា ការកំណត់បទល្មើសដោយច្បាប់ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ បានកែប្រែថ្ងៃទី២៧ ខែតុលា ឆ្នាំ ២០០៤ ចំលងស្ទើតែទាំងស្រុងតាមលក្ខន្តិកៈទីក្រុងរ៉ូម។[36] ការកំណត់បទល្មើសទាំងនោះរួមមានៈ

១. ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍

២.ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

៣. ឧក្រិដ្ឋកម្មសង្គ្រាម

**២.១.១.២. ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍**

មាត្រា ៤ នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញបានឱ្យនិយមន័យបទប្រល័យពូជសាសន៍ដូចតទៅៈ

« មាត្រា៤ អង្គជំនុំជម្រះវិសាមញ្ញមានសមត្ថកិច្ចជំនុំជម្រះរាល់ជនសង្ស័យថាបានប្រព្រឹត្តបទប្រល័យពូជសាសន៍ ដែលមានចែងក្នុងអនុសញ្ញាឆ្នាំ១៩៤៨ ស្តីពីការបង្ការ និងការផ្តន្ទាទោសបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ហើយដែល ឧក្រិដ្ឋកម្មនេះត្រូវបានប្រព្រឹត្តនៅក្នុងកំឡុងពីថ្ងៃទី១៧ មេសា ១៩៧៥ ដល់ថ្ងៃទី៦ មករា ១៩៧៩ ។

បទឧក្រិដ្ឋប្រល័យពូជសាសន៍ គឺជាបទល្មើសគ្មានអាជ្ញាយុកាល ហើយសំដៅលើអំពីណាមួយក្នុងចំណោមអំពើ ដែលរៀបរាប់ខាងក្រោមនេះ កាលបើអំពើនេះបានប្រព្រឹត្តក្នុងគោលបំណងបំផ្លាញទាំងមូល ឬមួយផ្នែកនៃក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនោះ

- ឃាតកម្មលើសមាជិកនៃក្រុម
- ការប៉ះពាល់យ៉ាងធ្ងន់ធ្ងរលើបូរណភាពខាងរូបកាយ ឬសតិ្តបញ្ញារបស់សមាជិកនៃក្រុម ។
- ការដាក់ឱ្យសមាជិកនៃក្រុមរស់នៅក្នុងលក្ខខ័ណ្ឌ ដែលនាំឱ្យមានវិនាសអន្តរាយទាំងស្រុង ឬ មួយផ្នែកនៃក្រុម។
- វិធានការណ៍សំដៅរារាំងកំណើតទារកនៅក្នុងក្រុម។
- ជម្លៀសដោយបង្ខំនូវកុមារពីក្រុមមួយទៅក្រុមមួយផ្សេងទៀត ។
- ម្យ៉ាងទៀត អំពើទាំងឡាយដូចរៀបរាប់ខាងក្រោមនេះ ក៏នឹងត្រូវផ្តន្ទាទោសដូចអំពើដែលបានរៀបរាប់ខាងលើដែរ
- ការប៉ុនប៉ងប្រព្រឹត្តអំពើប្រល័យពូជសាសន៍

[36] របាយការតុលាការព្រហ្មទណ្ឌអន្តរជាតិ, FIDH, ទំព័រ ៣៥។

– ការសមគំនិតក្នុងការប្រព្រឹត្តិអំពើប្រល័យពូជសាសន៍

– ការចូលរួមក្នុងការប្រព្រឹត្តិអំពើប្រល័យពូជសាសន៍ ។»[37]

ដូចនេះ និយមន័យនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដែលចែងក្នុងមាត្រា ៤ ចំលងស្ទើរតែទាំងស្រុងតាម មាត្រា ៦ នៃលក្ខន្តិកៈទីក្រុងរ៉ូម។ និយមន័យនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូមនេះ ក៏យកតាម និយមន័យ ដែលចែងក្នុងអនុសញ្ញាឆ្នាំ១៩៤៨ដែរ ។ មាត្រា៤ ខាងលើបានចែងអំពីការផ្តន្ទាទោសផងដែរចំពោះការប៉ុនប៉ង ការសមគំនិត និងសហចារីនៃបទ ប្រល័យពូជសាសន៍។

ក៏ប៉ុន្តែ ច្បាប់ចុះថ្ងៃទី១០ សីហា ២០០១ មានភាពចន្លោះប្រហោងជាងលក្ខន្តិកៈទីក្រុងរ៉ូម ដោយ មូលហេតុថា និយមន័យនៃការសមគំនិតដែលមានចែងក្នុងមាត្រា ២៩ នៃច្បាប់ខ្មែរមិនមានលក្ខណៈលំអិត ដូចមាត្រា ២៥ វាក្យខ័ណ្ឌទី៣ ចំនុច ខ. គនិង ង នៃលក្ខន្តិកៈទីក្រុងរ៉ូមនោះទេ។ ម្យ៉ាងវិញទៀត ច្បាប់ឆ្នាំ២០០១ មិនបានធ្វើការកំណត់ឱ្យបានច្បាស់លាស់អំពីការប៉ុនប៉ង ការឱ្យដៃ និងការ ប្រព្រឹត្តិបទល្មើសដោយជនល្មើសច្រើននាក់នោះទេ។ ផ្ទុយមកវិញ មាត្រា ២៥ នៃលក្ខន្តិកៈទីក្រុងរ៉ូមបានឱ្យនិយមន័យ យ៉ាងច្បាស់នូវរាល់សញ្ញាណខាងលើនេះ ក្នុងកថាខ័ណ្ឌទី៣ ចំនុច ក. ឃ និង ច។ ដូចគ្នានេះដែរ មាត្រា ៤ នៃច្បាប់ឆ្នាំ ២០០១ មិនបានចែងអំពីបទល្មើសញុះញង់ដោយផ្ទាល់ និងជាសាធារណៈឱ្យប្រព្រឹត្តបទប្រល័យពូជសាសន៍នោះទេ ដែលអំពើទាំងនេះត្រូវបានមាត្រា ២៥ វាក្យខ័ណ្ឌទី៣ ចំនុច ង កំណត់ថាជាបទល្មើសមួយដាច់ដោយឡែក ។[38]

### ២.១.១.៣. ឧក្រិដ្ឋកម្មប្រឆាំមនុស្សជាតិ

ច្បាប់ឆ្នាំ ២០០១ ចែងពីការផ្តន្ទាទោសចំពោះបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងមាត្រា ៥។

« មាត្រា៥ អង្គជំនុំជម្រះវិសាមញ្ញមានសមត្ថកិច្ចជំនុំជម្រះរាល់ជនសង្ស័យថាបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំង មនុស្សជាតិ ក្នុងកំឡុងពីថ្ងៃទី១៧ មេសា ១៩៧៥ ដល់ថ្ងៃទី៦ មករា ១៩៧៩ ។

បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ គឺជាបទល្មើសគ្មានអាជ្ញាយុកាល ហើយសំដៅលើអំពីណាមួយក្នុងចំណោមអំពើ ដែលរៀបរាប់ខាងក្រោមនេះ កាលបើអំពើនេះត្រូវបានប្រព្រឹត្តនៅក្នុងក្របខ័ណ្ឌនៃការវាយលុកជាទូទៅ ឬ ជាប្រព័ន្ធ សំដៅប្រឆាំងទៅលើប្រជាជនស៊ីវិលៈ

– ឃាតកម្ម

– ការសម្លាប់រង្គោល

– ការធ្វើឱ្យទៅជាទាសកម្ម

[37] មាត្រា ៤, ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

[38] របាយការតុលាការព្រហ្មទណ្ឌអន្តរជាតិ, FIDH, ទំព័រ ៣៥។

- ការនិរទេស ឬ ជម្លៀសប្រជាជនដោយការបង្ខំ
- ការដាក់ពន្ធនាគារ
- ការធ្វើទារុណកម្ម
- ការចាប់បង្ខំសេពសន្ធវៈ
- ការធ្វើទុក្ខបុកម្នេញលើក្រុម ឬសមូហភាពដោយមូលហេតុនយោបាយ ពូជអំបូរឬសាសនា
- គ្រប់អំពើអមនុស្សធម៌ផ្សេងទៀត។»[39]

មាត្រា ៥ នេះ ចំលងតាមផ្នែកមួយនៃមាត្រា ៧ កថាខ័ណ្ឌ១ នៃលក្ខន្តិកៈទីក្រុងរ៉ូម។ ម្យ៉ាងនិយមន័យនៃ មាត្រា៥ ដែលយកគំរូតាមលក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិនៃប្រទេសរ៉្វាន់ដា ដោយទាមទារថា ការវាយលុក ជាទូទៅប្រឆាំងនឹងប្រជាជនស៊ីវិលត្រូវតែធ្វើឡើង "ក្នុងហេតុផលជាតិសាសន៍នយោបាយ ជាតិ ពូជអំបូរ ឬសាសនា" ។ ចំណែកឯមាត្រា ៧ នៃលក្ខន្តិកៈទីក្រុងរ៉ូមវិញទាមទារឱ្យមានលក្ខខ័ណ្ឌបែបនេះតែក្នុងករណីអំពើធ្វើទុក្ខបុកម្នេញប៉ុណ្ណោះ (កថាខ័ណ្ឌ១ វាក្យខ័ណ្ឌ ជ) ។

ម្យ៉ាងទៀត កថាខ័ណ្ឌ២ នៃមាត្រា ៥ នៃច្បាប់ខ្មែរនេះ ចែងពីអំពើមួយចំនួន ដែលអាចចាត់ចូលថា ជាបទ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដូចជាការសម្លាប់រង្គោលការធ្វើឱ្យទៅជាទាសករការជម្លៀសដោយបង្ខំ ការធ្វើទុក្ខបុកម្នេញ និងរាល់អំពើអមនុស្សធម៌ផ្សេងទៀត បន្តែមិនបានបញ្ជាក់អំពីអត្ថន័យនៃពាក្យទាំងនេះ ទាំងនៅក្នុងមាត្រានេះ ទាំងនៅក្នុងមាត្រាផ្សេងទៀតនៃច្បាប់នេះ ។ លក្ខន្តិកៈទីក្រុងរ៉ូមចែងបានច្បាស់លាស់ និងលំអិតជាងចំពោះបញ្ហាទាំងនេះ។ ដូចជាការសម្លាប់រង្គោល ការធ្វើឱ្យទៅជាទាសករ ការជម្លៀសដោយបង្ខំ ការធ្វើទុក្ខបុកម្នេញត្រូវបានឱ្យនិយមន័យយ៉ាងច្បាស់នៅក្នុង មាត្រា ៧ កថាខ័ណ្ឌ២ វាក្យខ័ណ្ឌ ខ គ ឃ និង ឆ។ ចំពោះរាល់អំពើអមនុស្សជាតិផ្សេងទៀតត្រូវបានឱ្យនិយមន័យថា រាល់ អំពើទាំងឡាយណា ដែលមានចេតនាបង្កឱ្យមានការរងគ្រោះដ៏ធំធេង ឬ គ្រោះថ្នាក់ដ៏ធ្ងន់ធ្ងរដល់រូបកាយ ឬ ដល់សុខ ភាពខាងបញ្ញាស្មារតី ឬសុខភាពខាងរូបកាយ (មាត្រា ៧ កថាខ័ណ្ឌ១ ចំនុច ដ នៃលក្ខន្តិកៈទីក្រុងរ៉ូម) ។

ម្យ៉ាងទៀត ច្បាប់ឆ្នាំ២០០១ មិនបានឱ្យនិយមន័យការធ្វើទារុណកម្មដូចក្នុងមាត្រា៧ នៃលក្ខន្តិកៈទីក្រុងរ៉ូមនោះឡើយ ។ ដើម្បីកំណត់ បទល្មើសនេះ ច្បាប់ឆ្នាំ២០០១ បែរជាយោងទៅលើមាត្រា ៥០០ នៃច្បាប់ព្រហ្មទណ្ឌខ្មែរ ឆ្នាំ១៩៥៥ ទៅវិញ (មាត្រា ៣ នៃច្បាប់ឆ្នាំ២០០១)។ មាត្រា៥ នៃច្បាប់ឆ្នាំ២០០១ មិនបានចែងអំពីបណ្តាបទល្មើសមួយចំនួនដែលមានចែងក្នុងមាត្រា៧ នៃលក្ខន្តិកៈ ទីក្រុងរ៉ូម ដូចជាការបាត់ខ្លួនដោយបង្ខំ

[39] មាត្រា ៥, ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

បទល្មើសទាក់ទងនឹងផ្លូវភេទក្រៅពីការរំលោភ និងបទល្មើស អាប៉ាថេត ( Apartheid)[40] ជាដើម។ បទល្មើសទាំងនេះក៏មិនមានចែងក្នុងមាត្រាណាមួយផ្សេងទៀតនៃច្បាប់នេះដែរ ។[41]

### ២.១.១.៤. ឧក្រិដ្ឋកម្មសង្គ្រាម

ដោយយោងទៅតាមមាត្រា ៦ នៃច្បាប់ឆ្នាំ២០០១ បទឧក្រិដ្ឋកម្មសង្គ្រាមអាចត្រូវបានផ្តន្ទាទោសដោយអង្គជំនុំជម្រះវិសាមញ្ញ។ មាត្រានេះចែងថា:

មាត្រា៦ អង្គជំនុំជម្រះវិសាមញ្ញមានសមត្ថកិច្ចជំនុំជម្រះនូវរាល់ជនសង្ស័យថាបានប្រព្រឹត្ត ឬបញ្ជាឱ្យប្រព្រឹត្តអំពើរំលោភដ៏ធ្ងន់ធ្ងរប្រឆាំងនឹងបុគ្គល ឬ ទ្រព្យសម្បត្តិដែលការពារដោយអនុសញ្ញាក្រុងហ្សឺណែវចុះថ្ងៃទី១២ សីហា ឆ្នាំ១៩៤៩ ហើយដែលអំពើទាំងនេះត្រូវបានប្រព្រឹត្តឡើងក្នុងកំឡុងពីថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ មករា ឆ្នាំ១៩៧៩ ។ អំពើទាំងនោះរួមមានៈ

- ឃាតកម្ម
- ទារុណកម្ម ឬគ្រប់ប្រព្រឹត្តកម្មអមនុស្សធម៌
- អំពើបង្កដោយចេតនានូវការឈឺចាប់ ឬដែលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់បូរណភាពបុគ្គល ឬ ដល់សុខភាព
- ការបំផ្លាញ ឬការធ្វើឱ្យខូចខាតយ៉ាងធ្ងន់ធ្ងរដល់ទ្រព្យសម្បត្តិ ដោយគ្មានហេតុផលសមរម្យខាងយោធា និងប្រព្រឹត្តឡើងដោយខុសច្បាប់ និងតាមទំនើងចិត្ត
- អំពើបង្ខំឱ្យឈ្លើយសឹក ឬជនស៊ីវិលឱ្យបម្រើក្នុងកងកំលាំងប្រដាប់អាវុធរបស់រដ្ឋដែលជាសត្រូវ
- អំពើដកហូតសិទ្ធិរបស់ឈ្លើយសឹក ឬជនស៊ីវិលក្នុងការទទួលការវិនិច្ឆ័យដោយត្រឹមត្រូវ និងឥតលំអៀង
- ការជម្លៀស ការបញ្ជូន ឬការឃុំឃាំងដោយខុសច្បាប់
- ការចាប់ជនស៊ីវិលជាចំណាប់ខ្មាំង ។[42]

---

[40] Apartheid គឺជាពាក្យចោទប្រកាន់ ដែលបង្កប់នៅក្នុងប្រវត្តិសាស្ត្រ នយោបាយ និងអារម្មណ៍។ វាធ្វើអោយសមាគម និងការចងចាំពីការរើសអើង ការគៀបសង្កត់ និងភាពឃោរឃៅ។ នៃភាពអយុត្តិធម៌ ឯកសិទ្ធិ ការប្រកាន់ពូជសាសន៍ ការតស៊ូ និងការរំដោះនៅទីបំផុត។ ជាអត្ថន័យបង្កប់ ហើយអត្ថន័យទាំងនេះត្រូវបានសម្គាល់ដោយប្រវត្តិសាស្ត្រអាហ្វ្រិកខាងត្បូង។ ឧក្រិដ្ឋកម្មនៃការរើសអើងជាតិសាសន៍ត្រូវបានកំណត់ដោយលក្ខន្តិកៈទីក្រុងរ៉ូមឆ្នាំ 2002 នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិថាជាអំពើអមនុស្សធម៌នៃចរិតលក្ខណៈស្រដៀងទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផ្សេងទៀត "ប្រព្រឹត្តនៅក្នុងបរិបទនៃរបបគ្រប់គ្រងដោយស្ថាប័ននៃការគាបសង្កត់ និងការត្រួតត្រាជាប្រព័ន្ធដោយក្រុមជាតិសាសន៍មួយលើជាតិសាសន៍ដទៃទៀត។

[41] របាយការតុលាការព្រហ្មទណ្ឌអន្តរជាតិ, FIDH, ទំព័រ ៣៦។

[42] មាត្រា ៦, ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

មាត្រានេះចំលងតាមមាត្រា៨ កថាខ័ណ្ឌ១ នៃលក្ខន្តិកៈទីក្រុងរ៉ូម ក៏ប៉ុន្តែមិនបានចំលងតាមទាំងស្រុងនោះទេ។ តាមពិតមាត្រា ៨ កថាខ័ណ្ឌ២ វាក្យខ័ណ្ឌ ឃ នៃលក្ខន្តិកៈទីក្រុងរ៉ូមធ្វើការបញ្ចូលទំនៀមទំលាប់អន្តរជាតិ ទាក់ទងនឹងបទឧក្រិដ្ឋកម្មសង្គ្រាម។ មាត្រានេះចែងពីអំពើមួយចំនួន ដែលត្រូវបានកំណត់ថាជាឧក្រិដ្ឋកម្មសង្គ្រាមដែលការចែងបែបនេះមិនត្រូវបានធ្វើឡើងទេនៅក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ។[43]

## ២.១.២.ភាពខុសគ្នារវាងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ECCC) និងតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC)

សាលាក្តីកូនកាត់នេះ ពិតបានឆ្លុះបញ្ចាំងនូវ លក្ខណៈពិសេសរបស់ខ្លួន ទោះបីជាមានច្បាប់មួយចំនួនបានដកស្រង់ចេញពីលក្ខន្តិកៈទីក្រុងរ៉ូម ក៏ពិតមែន ប៉ុន្តែក៏មានភាពខុសគ្នា ក្នុងការអនុវត្ត និងបែងចែកយុត្តធិការបានយ៉ាងច្បាស់លាស់។ អ.វ.ត.ក រក្សាអត្តសញ្ញាណជាតុលាការនៅកម្ពុជា រួមទាំងគោរពទៅតាមកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់ក្តីនៅក្រោម ច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ។

### ២.១.២.១. ការដាក់បញ្ចូលក្នុងប្រព័ន្ធយុត្តិធម៌

សមត្ថកិច្ចរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងតុលាការព្រហ្មទណ្ឌអន្តរជាតិ ICC ត្រូវបានបែងចែកគ្នាដាច់ស្រឡះ ។ ពោលមានន័យថាប្រព័ន្ធយុត្តិធម៌ស្ថាប័នទាំង២ មានដែនយុត្តាធិការៀងៗខ្លួន។ ដោយ អ.វ.ត.ក ជាតុលាការកូនកាត់ ឬ Ad hoc ការបង្កើតឡើង មានពេលកំណត់បញ្ចប់ទៅវិញ។ ចំណែកឯ ICC តុលាការព្រហ្មទណ្ឌអន្តរជាតិ គឺជាយន្តការស្ថាប័នអន្តរជាតិ ដែលមានលក្ខណៈអចិន្ត្រៃយ៍ ។ កិច្ចការបង្កើតស្ថាប័នតុលាការមានលក្ខណៈអចិន្ត្រៃយ៍នេះ ត្រូវ បានជម្រុញ ពីសហគមន៍អន្តរជាតិ ដែលកន្លងមកបានប្រតិកម្មជាជាបន្តបន្ទាប់ចំពោះ ឧក្រិដ្ឋកម្ម ទ្រង់ទ្រាយ ធំនានា ឆ្លុះបញ្ចាំងតាមរយៈការបង្កើតឱ្យមានតុលាការពិសេសដើម្បីកាត់ទោសឧក្រិដ្ឋកម្មទាំងនោះ នៅ Yougoslavie (ICTY)[44], Rwanda (ICTR)[45], Sierra Leone (RSCSL)[46] និងចុងក្រោយនៅកម្ពុជា

---

[43] របាយការតុលាការព្រហ្មទណ្ឌអន្តរជាតិ, FIDH, https://fidh.org/IMG/pdf/Rapport_FIDH_en_khmer.pdf.,ទំព័រ ៣៨

[44] តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (ICTY) គឺជាតុលាការនៃច្បាប់របស់អង្គការសហប្រជាជាតិដែលទាក់ទងនឹងឧក្រិដ្ឋកម្មសង្គ្រាមដែលបានកើតឡើងក្នុងអំឡុងពេលជម្លោះនៅតំបន់បាល់កង់ក្នុងទសវត្សរ៍ឆ្នាំ 1990 ។

[45] តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេស Rwanda (ICTR) គឺជាតុលាការអន្តរជាតិដំបូងគេដែលត្រូវបានបង្កើតឡើងដើម្បីកាត់ទោសបុគ្គលដែលមានឋានៈខ្ពស់ចំពោះការរំលោភសិទ្ធិមនុស្សដ៏ធំនៅក្នុងទ្វីបអាហ្វ្រិក។ គោលបំណងនៃតុលាការនេះគឺដើម្បីកាត់ទោសអ្នកដែលទទួលខុសត្រូវចំពោះការប្រល័យពូជសាសន៍ Rwandan ឆ្នាំ 1994 ។

[46] តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូនត្រូវបានបង្កើតឡើងក្នុងឆ្នាំ 2002 ជាលទ្ធផលនៃសំណើទៅកាន់អង្គការសហប្រជាជាតិក្នុងឆ្នាំ 2000 ដោយរដ្ឋាភិបាលនៃប្រទេសសៀរ៉ាឡេអូនសម្រាប់ "តុលាការពិសេស" ដើម្បីដោះស្រាយឧក្រិដ្ឋកម្មធ្ងន់ធ្ងរប្រឆាំងនឹងជនស៊ីវិល និងកងកម្លាំងរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិដែលបានប្រព្រឹត្តក្នុងអំឡុងទសវត្សរ៍របស់ប្រទេសនេះ។ សង្គ្រាមស៊ីវិលរយៈពេលវែង (១៩៩១-២០០២) ។

គឺ អ.វ.ត.ក ។ តុលាការចុងក្រោយនេះ ជាប្រភេទ "កូនកាត់" (ដោយប្រើប្រាស់យន្តការច្បាប់សារធាតុ, ច្បាប់នីតិវិធី និងយន្តការស្ថាប័ន របស់កម្ពុជា និងរបស់ច្បាប់ អន្តរជាតិ) ដើម្បីកាត់ទោសរបបខ្មែរក្រហម បើទោះជាគេទទួលស្គាល់ថាជាការបង្កើត ដែលមានលក្ខណៈយឺត យ៉ាវក្តី។[47] បើទោះបីជាអង្គជំនុំជម្រះវិសាមញ្ញនេះមិនមានសមត្ថភាពក្នុងការអនុវត្តន៍នូវសមត្ថកិច្ចរបស់ខ្លួន គ្រប់បណ្តាលប្រទេសដូច ICC ក៏ដោយ ក៏មិនមានន័យថា ICC មានសមត្ថកិច្ចជំនុំជម្រះបទឧក្រិដ្ឋទាំងឡាយដែលស្ថិតក្នុងដែនយុត្តាធិការក្នុងប្រទេសកម្ពុជាបានដែរ ដោយធ្វើការកាត់ទោសឧក្រិដ្ឋជន ដែលជាមេដឹកនាំ កំពូលនាសម័យ ខ្មែរក្រហម មានតែអង្គជំនុំជម្រះវិសាមញ្ញនេះទេដែលមានអំណាចក្នុងការកាត់ក្តីតាមការចែងរបស់មាត្រា៧ នៃលក្ខន្តិកៈទីក្រុងរ៉ូម។[48] ដោយសារការលេចឡើងនូវតុលាការ អ.វ.ត.ក នេះ ICC មិនមានយុត្តាធិការនោះទេព្រោះ ខ្មែរក្រហមកើតមុនឆ្នាំ ២០០២ ហើយ ICC អាចអនុវត្តបានតែបទឧក្រិដ្ឋណាដែលកើតមានក្រោយឆ្នាំ ២០០២[49] តែប៉ុណ្ណោះ នេះជាមូលហេតុចម្បងមួយ។ ម្យ៉ាងវិញទៀត ICC មិនមានយុត្តាធិការលើក រឿងក្តីខ្មែរក្រហមនេះ ដោយសារ ឆន្ទៈ និង លទ្ធភាព ក្នុងការស្វែងរកភាពយុត្តិធម៌និង ការពិត ក្នុង អ.វ.ត.ក មានគ្រប់គ្រាន់ មិនចាំបាច់គោលការបំពេញបន្ថែម នោះទេ។ ផ្ទុយទៅវិញ ICC អាចអនុត្តតាមគោលការបំណេញបន្ថែមបានករណី ប្រទេសកម្ពុជាមិន មានឆន្ទៈ និង លទ្ធភាព នៅក្នុងរឿងក្តីខ្មែរក្រហមនោះទេ នឹងត្រូវការជំនួយពី សំណាក់ ICC ជួយ។[50]

### ២.១.២.២.ស្វ័យតាពនៃអង្គជំនុំជម្រះវិសាមញ្ញនិងគោលការណ៍នៃការបំពេញបន្ថែមរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ

អធិបតេយ្យភាពនៃអង្គជំនុំជម្រះវិសាមញ្ញ និងគោលការណ៍នៃការបំពេញបន្ថែមរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ។ អង្គជំនុំជម្រះវិសាមញ្ញ គឺជាស្ថាប័នតែមួយគត់ដែលមានសមត្ថកិច្ចជំនុំជម្រះបទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តក្នុងកំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ ស្របទៅតាម រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ជំពូកទី ១១ ថ្មី អំពីអំណាចតុលាការ គ្មានអង្គការណាមួយនៃអំណាចនីតិប្បញ្ញត្តិ ឬនីតិប្រតិបត្តិអាចទទួលអំណាចតុលាការអ្វីបានឡើយ។[51]

---

[47] ឡុង សារ៉ាពេជ្រ,ការដកខ្លួនរបស់ប្រទេសរុស្សី ចេញពីរដ្ឋហត្ថលេខីនៃលក្ខន្តិកៈទីក្រុងរ៉ូម, សមាគមសាលាត្រាជូ, ២០១៦, ទំព័រ ២។

[48] របាយការតុលាការព្រហ្មទណ្ឌអន្តរជាតិ, FIDH, ទំព័រ ៣៩

[49] ICC មានគោលបំណងបំពេញបន្ថែមជាជាងជំនួសតុលាការជាតិ។ វាអាចធ្វើសកម្មភាពបានលុះត្រាតែតុលាការជាតិត្រូវបានរកឃើញថាមិនអាច ឬមិនចង់កាត់ក្តី។ លើសពីនេះ វាគ្រាន់តែអនុវត្តយុត្តាធិការលើឧក្រិដ្ឋកម្មដែលបានកើតឡើងបន្ទាប់ពីលក្ខន្តិកៈរបស់ខ្លួនចូលជាធរមានក្នុងឆ្នាំ ២០០២។

[50] Claire Klobucista *and* Mariel Ferragamo, The Role of the ICC, Council on Foreign Relations, កែសម្រួលបន្ថែម, May 22, 2024 12:40 pm (EST)

[51] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ត្រូវបានប្រកាសឲ្យប្រើប្រាស់ជាផ្លូវការដោយព្រះរាជក្រម ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣, មាត្រា ១៣០ ថ្មី(មាត្រា ១១១ ចាស់)

អាជ្ញាយុកាលបទល្មើសមួយចំនួននៃនីតិរួមត្រូវបានពន្យារពេលរហូតដល់៣០ឆ្នាំ ដើម្បីបំពេញតាមតំរូវការនៃការជំនុំជម្រះខ្មែរក្រហម។ ក្នុងដំណើរការនៃការផ្តន្ទាទោសបទឧក្រិដ្ឋខាងលើនេះលក្ខន្តិកៈទីក្រុងរ៉ូមមានការចែងខុសពីនេះពោលគឺ គោរពតាមគោលការណ៍នៃការបំពេញបន្ថែម។ ដូចនេះក្នុងករណីទូទៅរដ្ឋជាអ្នកមានសមត្ថកិច្ចក្នុងការជំនុំជម្រះលើ រាល់បទឧក្រិដ្ឋដែលមានចែងក្នុងមាត្រា ៥ នៃលក្ខន្តិកៈទីក្រុងរ៉ូម ។ បុព្វកថាវាក្យខ័ណ្ឌ១០ នៃលក្ខន្តិកៈនេះចែងថា៖

"តុលាការព្រហ្មទណ្ឌអន្តរជាតិ (...) ត្រូវជាការបន្ថែមលើយុត្តាធិការព្រហ្មទណ្ឌជាតិ"

មាត្រា ១ ចែងថា៖

"តុលាការព្រហ្មទណ្ឌអន្តរជាតិ (...) ផ្លូវជាការបន្ថែមលើយុត្តាធិការព្រហ្មទណ្ឌជាតិ"

ដូច្នេះ មានតែក្នុងករណីដែលរដ្ឋពាក់ព័ន្ធមិនមានលទ្ធភាព ឬមិនមានឆន្ទៈក្នុងការជំនុំជម្រះរឿងនេះទេ ទើបតុលាការព្រហ្មទណ្ឌអន្តរជាតិមានសមត្ថកិច្ចដោយយោងទៅលើមាត្រា ១៧៖

១. យោងតាមកថាខ័ណ្ឌទី១០ នៃបុព្វកថា និងមាត្រា ១ តុលាការត្រូវកំណត់ថាករណីមួយមិនអាចទទួល យកបានទេបើ៖

(ក) ករណីនេះត្រូវបានស៊ើបអង្កេត ឬ នាំយកមកជំនុំជម្រះដោយរដ្ឋដែលមានយុត្តាធិការលើករណីនោះរួចហើយ លើកលែងតែរដ្ឋនោះគ្មានឆន្ទៈ ឬ គ្មានលទ្ធភាពអនុវត្តការស៊ើបអង្កេត ឬ ការនាំយកមកជំនុំជម្រះដោយពិតប្រាកដ ។

(ខ) ករណីនេះត្រូវបានស៊ើបអង្កេតដោយរដ្ឋ ដែលមានយុត្តាធិការលើករណីនោះហើយ ហើយរដ្ឋនោះបានសម្រេចមិននាំយកជនពាក់ព័ន្ធនោះមកជំនុំជម្រះទេ លើកលែងតែសេចក្តីសម្រេចនោះកើតចេញពីលទ្ធផលនៃភាពគ្មានឆន្ទៈ ឬ អលទ្ធភាពរបស់រដ្ឋនោះក្នុងការនាំយកមកជំនុំជម្រះដោយពិតប្រាកដ។

(គ) ជនពាក់ព័ន្ធត្រូវបានជំនុំជម្រះចំពោះអំពើដែលជាកម្មវត្ថុនៃពាក្យបណ្តឹងនោះរួចហើយ ហើយការជំនុំជម្រះដោយតុលាការមិនត្រូវបានអនុញ្ញាតឱ្យតាម កថាខ័ណ្ឌទី៣ នៃមាត្រា ២០ ទេ ។

(ឃ) ករណីនោះមិនធ្ងន់ធ្ងរគ្រប់គ្រាន់ល្មមសម្រាប់ធ្វើយុត្តិកម្មសកម្មភាពបន្តទៀតដោយតុលាការ ។"

តុលាការព្រហ្មទណ្ឌអន្តរជាតិមានសមត្ថកិច្ចតែក្នុងករណីដែលរដ្ឋមិនមានឆន្ទៈ ឬ មិនមានលទ្ធភាពក្នុងការស៊ើបអង្កេត និងជំនុំជម្រះឧក្រិដ្ឋជនតែប៉ុណ្ណោះ។ យោងតាមមាត្រា ១៧ កថាខ័ណ្ឌ២ នៃលក្ខន្តិកៈទីក្រុងរ៉ូមការគ្មានឆន្ទៈសំដៅលើស្តង់ដានៃនីតិអន្តរជាតិ ទាក់ទង ជាអាទិ៍ នឹងការធានាឱ្យមានការជំនុំជម្រះប្រកបដោយសមធម៌។ ការខ្វះខាតឆន្ទៈក្នុងការជំនុំជម្រះអាចកើតឡើងក្នុងករណីដែលមាននីតិវិធីក្នុងការជំនុំជម្រះយូរហួសហេតុឬខ្វះភាពឯករាជ្យនិងអព្យាក្រឹត្យ(វាក្យខ័ណ្ឌខ និង គ)។

អសមត្ថភាពត្រូវបានគេឱ្យនិយមន័យក្នុងលក្ខន្តិកៈទីក្រុងរ៉ូមថាកើតឡើងដោយសារការដួលរលំទាំងស្រុង ឬជាសារវ័ន្តនៃប្រព័ន្ធយុត្តិធម៌ជាតិ ឬមួយដោយសារកង្វះខាតនូវសមត្ថភាពក្នុងការចាត់ការតាមនីតិវិធីឱ្យបានពេញលេញក្នុងការជំនុំជម្រះបទឧក្រិដ្ឋដែលមានចែងក្នុងលក្ខន្តិកៈទីក្រុងរ៉ូម (មាត្រា១៧ កថាខ័ណ្ឌ៣) ។

ម្យ៉ាងវិញទៀត បើទោះបីជាឧក្រិដ្ឋជនណាមួយត្រូវបានកាត់ទោសដោយស្ថាប័នយុត្តាធិការជាតិចំពោះបទឧក្រិដ្ឋដែលមានចែងក្នុងមាត្រា ៥ នៃលក្ខន្តិកៈទីក្រុងរ៉ូមរួចហើយក៏ដោយក៏តុលាការព្រហ្មទណ្ឌអន្តរជាតិអាចសើរើយករឿងនេះមកជំនុំជម្រះឡើងវិញបានដែរប្រសិនបើតុលាការនេះរកឃើញថា ដំណើរការនៃនីតិវិធីធ្វើឡើងដោយតុលាការជាតិ មិនត្រូវបានធ្វើឡើងត្រឹមត្រូវតាមនីតិអន្តរជាតិ (មាត្រា ២០ កថាខ័ណ្ឌ៣) ។ [52]

ដោយឡែក អ.វ.ត.ក បានបង្កើតវិធានផ្ទៃក្នុងសម្រាប់ធ្វើការប្រើប្រាស់នៅក្នុងការអនុវត្តរបស់អង្គជំនុំជម្រះផងដែរ។ វិធានផ្ទៃក្នុងនៃ អ.វ.ត.ក នោះបានប្រើប្រាស់ក៏ដូចជាបានធ្វើវិសោធនកម្មចំនួនដប់ដងកន្លងមក។[53]

### ២.១.២.៣. ការដាក់ដែនកំណត់ចំពោះជនដែលអាចត្រូវបានចោទប្រកាន់ដោយអង្គជំនុំជម្រះវិសាមញ្ញ

អង្គជំនុំជម្រះអាចធ្វើការចោទប្រកាន់ និងជំនុំជម្រះតែចំពោះ "អតីតមេ ដឹកនាំ ជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយផ្សេងទៀតដែលមានការទទួលខុសត្រូវថ្នាក់ខ្ពស់ ក្នុងរបបនេះ" ប៉ុណ្ណោះ (មាត្រា២ថ្មី) ។ ការកំណត់បែបនេះត្រូវបានធ្វើឡើងក្នុងគោលបំណងជៀសវាងមិនឱ្យមានអស្ថេរភាពនយោបាយ ក្នុងប្រទេសកម្ពុជា។

ផ្ទុយទៅវិញ លក្ខន្តិកៈទីក្រុងរ៉ូមមិនមានចែងនូវដែនកំណត់ចំពោះជនដែលអាចត្រូវបានចោទប្រកាន់ និងជំនុំជម្រះដោយតុលាការព្រហ្មទណ្ឌអន្តរជាតិទេ លើកលែងតែចំពោះជនដែលមានអាយុក្រោម១៨ឆ្នាំ ក្នុងពេលដែលខ្លួន ប្រព្រឹត្តបទល្មើស (មាត្រា ២៦) ។ ក្រៅពីនេះ តុលាការព្រហ្មទណ្ឌអន្តរជាតិមានសមត្ថកិច្ចធ្វើការចោទប្រកាន់ និង ជំនុំជម្រះលើគ្រប់ជនទាំងឡាយណា ដែលបានប្រព្រឹត្តបទឧក្រិដ្ឋ ដែលជាសមត្ថកិច្ចរបស់តុលាការទោះបីជននោះជា ចារីផ្ទាល់ ឬ ជាសហចារី ជាជនសមគំនិត ឬ ក៏មានការប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋនេះក៏ដោយ (មាត្រា ២៥ នៃលក្ខនិកៈក្រុងរ៉ូម) ។ ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌនៃមេបញ្ជាការកងទ័ព ឬ ជនទាំងឡាយដែលអនុវត្តមុខងារជាបញ្ជាការ កងទ័ព ក៏អាចត្រូវបានចោទប្រកាន់ និងជំនុំជម្រះដោយតុលាការព្រហ្មទណ្ឌអន្តរជាតិដែរ (មាត្រា ២៨ នៃលក្ខន្តិកៈ ក្រុងរ៉ូម) ។[54]

---

[52] របាយការតុលាការព្រហ្មទណ្ឌអន្តរជាតិ, FIDH.,ទំព័រ ៤០។

[53] គេហទំព័រអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា,វិធានផ្ទៃក្នុង, https://www.eccc.gov.kh/km/document/legal/internal-rules

[54] របាយការតុលាការព្រហ្មទណ្ឌអន្តរជាតិ, FIDH,ទំព័រ ៤២។

## ២.២. ការបើកឱ្យមានវត្តមានដល់ ជនរងគ្រោះ និង លក្ខណៈចូលខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

អ.វ.ត.ក គឺជាតុលាការពិសេសមួយនៅក្នុងរចនាសម្ព័ន្ធនៃប្រព័ន្ធតុលា ការរបស់ប្រទេសកម្ពុជាដែលមានបុគ្គលិកជាអ្នកវិជ្ជាជីវៈជាតិនិងអន្តរជាតិ និងទទួលការឧបត្ថម្ភថវិការួមគ្នាពីរាជរដ្ឋាភិបាលកម្ពុជា និងប្រទេសជាសមាជិកនៃអង្គការសហប្រជាជាតិ។ ដោយសារលក្ខណៈដោយឡែកនៃរចនាសម្ព័ន្ធរបស់តុលាការ និងដោយមានការចូលរួមរបស់រដ្ឋាភិបាល និងបុគ្គលិកជាតិ និងអន្តរជាតិ ដូច្នេះហើយ អ.វ.ត.ក ត្រូវបានគេហៅជាញឹកញាប់ថា «សាលាក្តីកូនកាត់»។ អ្វីដែលមិនធ្លាប់មាននៅក្នុងប្រវត្តិសាស្រ្តនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ប៉ុន្តែសាលាក្តីខ្មែរក្រហមមាន នោះគឺការចូលរួមរបស់ជនរងគ្រោះជា «ភាគីមួយនៃ រឿងក្តី» នៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ នៅចំពោះមុខសាលាក្តីនេះ ដែលគេ ហៅពួកគាត់ថា «ដើមបណ្តឹងរដ្ឋប្បវេណី»។[55]

### ២.២.១. វត្តមានរបស់ដើមបណ្តឹងរដ្ឋប្បវេណី

អ.វ.ត.ក ស្តីពីនីតិវិធីក្នុងការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី បានកំណត់នៅក្នុងវិធានរបស់តុលាការ អ.វ.ត.ក បានបញ្ជាក់ថាដើម្បីក្លាយជាដើមបណ្តឹងរដ្ឋប្បវេណីជនរងគ្រោះត្រូវដាក់
ពាក្យសុំតាមរយៈអង្គភាពគាំពារជនរងគ្រោះ។ នៅក្នុងពាក្យសុំរបស់ខ្លួនជនរងគ្រោះត្រូវបង្ហាញថាខ្លួនបានទទួលរងព្យសនកម្ម (ការខូចខាត) ដែលជាផលលំបាកនៃឧក្រិដ្ឋកម្មដែលចោទប្រកាន់នៅក្នុងសំណុំរឿងណាមួយនៅចំពោះមុខតុលាការ អ.វ.ត.ក ។ ការខូចខាតនេះគឺរួមបញ្ចូលទាំងការបាត់បងញាតិសន្តានដែលជាជនរងគ្រោះដោយសារឧក្រិដ្ឋកម្មទាំងនេះ។[56]

### ២.២.២. លក្ខណៈ នៃការចូលរបស់ដើមបណ្តឹងរដ្ឋប្បវេណី និង តំណាងដើមបណ្តឹងរដ្ឋប្បវេណី

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាហៅកាត់ថា អ.វ.ត.ក នីតិវិធីក្នុងការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបានកំណត់នៅក្នុងវិធានរបស់តុលាការ អ.វ.ត.ក បានបញ្ជាក់ថា ដើម្បីក្លាយជាដើមបណ្តឹងរដ្ឋប្បវេណីជនរងគ្រោះត្រូវដាក់ពាក្យសុំតាមរយៈអង្គភាពគាំពារជនរងគ្រោះ។ នៅក្នុងពាក្យសុំរបស់ខ្លួន ជនរងគ្រោះត្រូវបង្ហាញថាខ្លួនបានទទួលរងព្យសនកម្ម (ការខូចខាត) ដែលជាផលលំបាកនៃឧក្រិដ្ឋកម្មដែលចោទប្រកាន់នៅក្នុងសំណុំរឿងណាមួយនៅចំពោះមុខតុលាការ អ.វ.ត.ក ។ ការខូចខាតនេះគឺរួមបញ្ចូលទាំងការបាត់បងញាតិសន្តានដែលជាជនរងគ្រោះដោយសារឧក្រិដ្ឋកម្មទាំងនេះ។[57]

---

[55] កម្រងរឿងរ៉ាវរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា,ទំព័រ ៣។

[56] វិធាន ២៣ សទ្ធ, អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា,វិសោធនកម្មលើកទី១០។

[57] កម្រងរឿងរ៉ាវរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, ទំព័រ ២២។

### ២.២.២.១. លក្ខណៈ នៃការចូលរបស់ដើមបណ្តឹងរដ្ឋប្បវេណី

បណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងការទទួលយកនូវពាក្យសុំតាំងខ្លួនជា ដើមបណ្តឹងរដ្ឋប្បវេណី ដូចតទៅ៖

ដើម្បីឱ្យពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីអាចទទួលយកបានអ្នកដាក់ពាក្យសុំតាំងខ្លួនជា ដើមបណ្តឹងរដ្ឋប្បវេណីត្រូវតែជាជនរងគ្រោះដែលមានបំណងចង់តាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរយ៉ាងយូរ (១៥) ថ្ងៃបន្ទាប់ពីសហចៅក្រមស៊ើបអង្កេតជូនដំណឹងដល់ភាគីទាំងអស់អំពីការបញ្ចប់កិច្ចស៊ើបសួរតាមផ្លូវតុលាការដោយអនុលោមតាមវិធាន ៦៦ (១) ។ អនុលោមតាមបទប្បញ្ញត្តិស្តីពីវិធានការការពារជនរងគ្រោះដែលមានចែងក្នុងវិធានផ្ទៃក្នុងនេះ សហចៅក្រមស៊ើបអង្កេតត្រូវជូនដំណឹងនេះទៅសហព្រះរាជអាជ្ញា និងជនត្រូវចោទ ។

ក- បង្ហាញពីអត្តសញ្ញាណឱ្យបានច្បាស់លាស់ និង

ខ- បង្ហាញជាលទ្ធផលដោយផ្ទាល់ពីបទឧក្រិដ្ឋ យ៉ាងហោចណាស់មួយនៃបទឧក្រិដ្ឋជាច្រើន ដែលត្រូវបានចោទប្រកាន់លើជនត្រូវចោទ ថាខ្លួនពិតជាបានទទួលរងនូវព្យសនកម្មខាងរូបរាងកាយខាងសម្ភារៈ ឬផ្លូវចិត្តដែលអាចជាមូលដ្ឋានសម្រាប់ការទាមទារសំណងផ្លូវចិត្ត និងសមូហភាព។ នៅពេលពិចារណាអំពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីសហចៅក្រមស៊ើបអង្កេតត្រូវតែមានជំនឿថាអង្គហេតុដែលគាំទ្រដល់ការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនោះមានភាពពិតប្រាកដ។[58]

### ២.២.២.២. តំណាងដើមបណ្តឹងរដ្ឋប្បវេណី

នៅក្នុងវិធានរបស់ អ.វ.ត.ក ការតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖

១. ចាប់ពីពេលចេញដីកាដំណោះស្រាយតទៅដើម្បីចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីដើមបណ្តឹងរដ្ឋប្បវេណីទាំងឡាយត្រូវតំណាងដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមួយរូប នៅគ្រប់ពេលទាំង អស់ ។

២. នៅពេលដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានតំណាងដោយមេធាវីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីនឹង ត្រូវបានអនុវត្តតាមរយៈមេធាវីនោះ។

៣. ដើមបណ្តឹងរដ្ឋប្បវេណីអាចបង្កើតជាក្រុម និងជ្រើសរើសមេធាវីឱ្យធ្វើជាតំណាងក្រុមជារួមចេញពីបញ្ជីដែលរៀបចំឡើងដោយអង្គភាពគាំពារជនរងគ្រោះ។ លើសពីនេះទៅទៀតសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះអាចរៀបចំឱ្យមានតំណាងរួមដូចខាងក្រោម ៖

[58] វិធាន ២៣ សន្ទួ, អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, វិសោធនកម្មលើកទី១០។

ក-) ក្នុងករណីដែលតម្រូវឱ្យមានផលប្រយោជន៍នៃយុត្តិធម៌សហចៅក្រមស៊ើបអង្កេត អាចតម្រូវ ឱ្យដើមបណ្ដឹងរដ្ឋប្បវេណីបង្កើតជាក្រុមដើម្បីជ្រើសរើសមេធាវីម្នាក់ឬច្រើននាក់ធ្វើជាតំណាងរួមក្នុងរយៈពេលកំណត់ណាមួយ ។

ខ-) នៅពេលផលប្រយោជន៍យុត្តិធម៌តម្រូវ សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះអាច ចងក្រងដើមបណ្ដឹងរដ្ឋប្បវេណីជាក្រុម ឬចាត់ពួកគេឱ្យចូលក្នុងក្រុមដែលមានស្រាប់ និងចាត់តាំងមេធាវីរួមមួយរូបសម្រាប់ក្រុមនេះបន្ទាប់ពីពិគ្រោះយោបល់ជាមួយអង្គភាពគាំពារជនរងគ្រោះ។

គ-) សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះអង្គភាពគាំពារជនរងគ្រោះត្រូវចាត់វិធានការសមស្របទាំងឡាយដើម្បីធានាថាក្នុងការជ្រើសរើសមេធាវីតំណាងឱ្យក្រុមផលប្រយោជន៍របស់ដើមបណ្ដឹងរដ្ឋប្បវេណីនីមួយៗត្រូវបានគោរព និងទំនាស់ផលប្រយោជន៍ដទៃទៀតក៏ត្រូវបានចៀសវាង។

ឃ-)គ្រប់ពេលវេលាទាំងអស់ដើមបណ្ដឹងរដ្ឋប្បវេណីអាចដាក់ពាក្យសុំដោយមានបញ្ជាក់ពីមូលហេតុទៅសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះឱ្យពិចារណាឡើងវិញអំពីការចាត់តាំងមេធាវីរបស់ពួកគេដោយសហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ ។

## ២.៣. យុត្តាធិការក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

អ.វ.ត.ក ត្រូវបានបង្កើតឡើងក្នុងគោលបំណងផ្ដល់ការជំនុំជម្រះក្ដីដោយយុត្តិធម៌ និងស្របតាមនិយាមយុត្តិធម៌អន្តរជាតិ នឹងប្រើប្រាស់ទាំងច្បាប់ជាតិនិងច្បាប់អន្តរជាតិ។

### ២.៣.១. ដែនយុត្តាធិការលើពេលវេលារបស់តុលាការត្រូវបានកំណត់ត្រឹមៈ

អំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩

### ២.៣.២. ដែនយុត្តាធិការលើបុគ្គលៈ

មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ អ្នកដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ។

### ២.៣.៣. ដែនយុត្តាធិការតាមបទចោទៈ

- ទារុណកម្ម មនុស្សឃាត និងការរើសអើងដោយមូលហេតុសាសនា ដែលមានចែងក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦
- អំពើប្រល័យពូជសាសន៍
- ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ

- ការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩
- ការបំផ្លិចបំផ្លាញសម្បត្តិវប្បធម៌ក្នុងអំឡុងពេលសង្គ្រាម
- ឧក្រិដ្ឋកម្មប្រឆាំងនឹងជនដែលត្រូវបានការពារដោយអនុសញ្ញាទីក្រុងវីយែនឆ្នាំ១៩៦១ ស្តីអំពីទំនាក់ទំនងការបរទេស។[59]

[59] គេហទំព័រអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា,ព័ត៌មានសង្ខេបអំពី អ.វ.ត., https://www.eccc.gov.kh/sites/default/files/ECCC%20at% 20a%20Glance-KH-%20Updated%20March%202013.pdf

# ជំពូកទី៣
# សេចក្ដីសម្រេចនិងការអនុវត្តរបស់
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

# ជំពូកទី៣
# សេចក្តីសម្រេច និង លទ្ធផលសម្រេចរបស់ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ៣.១ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

សេចក្តីសម្រេចរបស់តុលាការ បានសម្រេចទៅលើសំណុំរឿង ធំៗ រួមមាន សំណុំរឿងលេខ ០០១, សំណុំរឿងលេខ ០០២, សំណុំរឿងលេខ ០០២/០១ ,សំណុំរឿងលេខ ០០២/០២, សំណុំរឿងលេខ ០០៣, និង សំណុំរឿងលេខ ០០៤, សំណុំរឿងលេខ ០០៤/០១, សំណុំរឿងលេខ ០០៤/០២ ។ នៅក្នុងនោះជនជាប់ចោទ ០៩ រូបរួមមាន៖

(០១)កាំង ហ្គេកអ៊ាវ,(០២) ខៀវ សំផន,(០៣) នួន ជា,(០៤) មាស មុត,(០៥) យឹម ទិត្យ ,(០៦) អៀង ធីរិទ្ធ , (០៧) អៀង សារី ,(០៨) អោ អាន និង (០៩) អ៊ឹម ចែម។ [60]

### ៣.១.១ សំណុំរឿង ០០១

សំណុំរឿង០០១ ជាសំណុំរឿងដំបូងនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ កាំង ហ្គេក អ៊ាវ ហៅឌុច អតីតប្រធានមន្ទីរស២១ ក្នុងទីក្រុងភ្នំពេញ ជាជនជាប់ចោទក្នុងសំណុំរឿង០០១។

អង្គជំនុំជម្រះតុលាការកំពូលបានផ្តន្ទាទោស ឌុច កាលថ្ងៃសុក្រ ទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឱ្យជាប់ពន្ធនាគារអស់មួយជីវិត។ សេចក្តីសម្រេចចិត្តនេះគឺជាសេចក្តីសម្រេចចុងក្រោយនិងបិទផ្លូវតវ៉ា។ អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ដែលប្រកាសកាលពីថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ២០១០ និងដោយមតិភាគច្រើនលើសលុប ក៏បានបដិសេធចោលសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលកាត់បន្ថយរយៈពេល៥ឆ្នាំ ជាសំណងចំពោះការជាប់ឃុំឃាំងដោយខុសច្បាប់នៅមន្ទីរឃុំឃាំងរបស់តុលាការយោធា ចន្លោះពីថ្ងៃទី ១០ ខែឧសភា ឆ្នាំ១៩៩៩ ដល់ថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ២០០៧។ បន្ទាប់ពីបានធ្វើសវនាការបឋមនៅថ្ងៃទី១៧ និង១៨ ខែកុម្ភៈ ឆ្នាំ២០០៩ ការជំនុំជម្រះលើអង្គសេចក្តីត្រូវបានចាប់ផ្តើមធ្វើឡើងនៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៩។ ការជំនុំជម្រះ ឌុច បានបញ្ចប់នៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៩។ ក្នុងរយៈពេលជំនុំជម្រះចំនួន៧៧ថ្ងៃ មានសាក្សីជាអ្នកជំនាញចំនួន៩នាក់ សាក្សីផ្តល់សក្ខីកម្មទាក់ទង នឹងអង្គហេតុចំនួន១៧នាក់ សាក្សីផ្តល់សក្ខីកម្មទាក់ទងនឹងអត្តចរិតចំនួន៧នាក់ និងដើមបណ្តឹង រដ្ឋប្បវេណីចំនួន២២នាក់ បានឡើងបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ សាធារណជនចំនួនជាង ៣១.០០០នាក់ បាន

[60] គេហទំព័រអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា,ឯកសារតុលាការ ជនជាប់ចោទ https://www.eccc.gov.kh/km/document/court/by/indicted-person

តាមដានដំណើរការនីតិវិធីនេះដោយផ្ទាល់នៅសាលសវនាការ។ នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ អង្គជំនុំជម្រះសាលាដំបូងបានដាក់ទោស កាំង ហ្កេកអ៊ាវ និងផ្ដន្ទាទោសឱ្យជាប់ពន្ធនាគាររយៈពេល៣៥ឆ្នាំ។ ទោសនេះត្រូវបានកាត់បន្ថយរយៈពេល៥ឆ្នាំ ជាសំណងចំពោះការឃុំខ្លួនគាត់ខុសនីតិវិធីច្បាប់ដោយតុលាការយោធាកម្ពុជា ពីថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ ដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧។ ជនត្រូវចោទក៏ទទួលបាននូវការទទួលស្គាល់នូវរយៈពេលឃុំខ្លួននៅក្រោមសមត្ថកិច្ចរបស់តុលាការយោធាកម្ពុជា និងរយៈពេលឃុំខ្លួនបណ្ដោះអាសន្ននៅក្រោមសមត្ថកិច្ចរបស់ អ.វ.ត.ក។ ជនត្រូវចោទ និងសហព្រះរាជអាជ្ញា បានប្ដឹងសាទុក្ខទៅអង្គជំនុំជម្រះតុលាការកំពូល ជំទាស់ទៅនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង។ ដើមបណ្ដឹងរដ្ឋប្បវេណីមួយចំនួនក៏បានប្ដឹងសាទុក្ខប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងសំណងផ្លូវចិត្តនិងការបដិសេធភាពអាចទទួលយកបាននៃពាក្យសុំធ្វើជាដើមបណ្ដឹងរដ្ឋប្បវេណី។ អង្គជំនុំជម្រះតុលាការកំពូលបានបើកសវនាការសាធារណៈទៅលើបណ្ដឹងសាទុក្ខ ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង០០១ នៅសប្ដាហ៍ចុងក្រោយនៃខែមីនា ឆ្នាំ២០១១។ អង្គជំនុំជម្រះតុលាការកំពូលបានប្រកាសសាលដីកាសង្ខេបនៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២។

នៅក្នុងសាលក្រមថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ អង្គជំនុំជម្រះសាលាដំបូង ដែលត្រូវបានអង្គជំនុំជម្រះតុលាការកំពូលទទួលស្គាល់មួយផ្នែកនិងធ្វើវិសោធនកម្មមួយផ្នែក នៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឌុច មានទោសទៅតាមមាត្រាទី៥ ទី៦ និងទី២៩(ថ្មី) នៃច្បាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ចំពោះបទល្មើសទាំងប៉ុន្មានខាងក្រោម ដែលត្រូវបាន ប្រព្រឹត្តនៅទីក្រុងភ្នំពេញក្នុងទឹកដីនៃប្រទេសកម្ពុជា ចន្លោះពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩៖

ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ៖

- ការរើសអើងដោយសារហេតុផលនយោបាយ
- ការសម្លាប់រង្គាល (រួមបញ្ចូលទាំងការធ្វើមនុស្សឃាត)
- ការធ្វើឱ្យទៅជាទាសករ
- ការដាក់ក្នុងមន្ទីរឃុំឃាំង
- ការធ្វើទារុណកម្ម និង
- អំពើអមនុស្សធម៌ផ្សេងៗទៀត

ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩៖

- ការធ្វើមនុស្សឃាតដោយចេតនា
- ការធ្វើទារុណកម្ម និងការធ្វើបាបដោយអមនុស្សធម៌

- ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬឱ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព
- ការដកហូតដោយចេតនាពីឈ្លើយសឹកឬជនស៊ីវិល នូវសិទ្ធិទទួលបានការកាត់ ទោសដោយយុត្តិធម៌ និងទៀងទាត់
- និង ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់។[61]

### ៣.១.២ សំណុំរឿង ០០២

នៅថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ នួន ជា និង ខៀវ សំផន (រួមទាំង អៀង សារី និង អៀង ធីរិទ្ធ) ត្រូវបាន បញ្ជូនខ្លួនមកជំនុំជម្រះពីបទចោទទាំងឡាយពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អំពើប្រល័យពូជសាសន៍ និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩ ដែលត្រូវបានកំណត់ថាជាសំណុំរឿង ០០២ នៅចំពោះមុខ អ.វ.ត.ក។ អតីតមេដឹកនាំខ្មែរក្រហមពីរនាក់ស្ថិតនៅក្នុងដំណាក់កាលជំនុំជម្រះនៃសំណុំរឿង ០០២។ ជនជាប់ចោទទាំងពីរនាក់នេះមាន៖

- ➢ នួន ជា អតីតប្រធានរដ្ឋសភានៃរបបកម្ពុជាប្រជាធិបតេយ្យ និងជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា នួន ជា ត្រូវបានចោទប្រកាន់ថា មានការទទួលខុសត្រូវតាមរយៈការធ្វើសកម្មភាព ឬ បរាជ័យក្នុងការទប់ស្កាត់ (រួមបញ្ចូលទាំងការប្រព្រឹត្តតាមរយៈឧស្សាហកម្មឧក្រិដ្ឋកម្ម រួម) បញ្ជា ញុះញង់ រៀបចំផែនការ ដឹកនាំ ឬសមគំនិតដោយការជួយឬជំរុញ ឬបង្ក លក្ខណៈងាយស្រួលដល់ការប្រព្រឹត្តឧក្រិដ្ឋកម្ម ឬទទួលខុសត្រូវក្នុងនាមជាអ្នកដឹកនាំ ចំពោះឧក្រិដ្ឋកម្មដូចខាងក្រោម ដែលត្រូវបានប្រព្រឹត្តនៅចន្លោះពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩៖

- ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ៖ មនុស្សឃាត ការសម្លាប់ផ្តាច់ពូជ ការដាក់ក្នុង មន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ផ្សេងទៀត។
- ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ៖ ការសម្លាប់រង្គាលក្រុមជនជាតិវៀតណាមនិងចាម។

- ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ៖ មនុស្សឃាតដោយចេតនា ការធ្វើទារុណកម្មឬការប្រព្រឹត្តអមនុស្សធម៌ ការបង្កដោយ ចេតនាឱ្យមានរបួសធ្ងន់ធ្ងរឬឱ្យមានការឈឺចាប់ដល់រូបរាងកាយឬសុខភាព ការដក ហូតដោយចេតនាពីឈ្លើយសឹកឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ក្តីដោយយុត្តិធម៌ ការបង្ខាំងនិងការនិរទេសជនស៊ីវិលដោយខុសច្បាប់។

[61] គេហទំព័រអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា,សំណុំរឿង ០០១, https://www.eccc.gov.kh/km/indicted-person/ kaamng-hkekqaav

- អំពើមនុស្សឃាត ៖ ការធ្វើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញខាងផ្នែកសាសនា ដូច មានចែងក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦។[62]នួន ជា បានបដិសេធរាល់បទចោទប្រកាន់ទាំងអស់មកលើគាត់។

➢ ខៀវ សំផន អតីតប្រមុខរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ។

ខៀវ សំផន ត្រូវបានចោទប្រកាន់ថាមានការទទួលខុសត្រូវតាមរយៈការធ្វើសកម្មភាព ឬបរាជ័យក្នុងការទប់ស្កាត់ (រួមបញ្ចូលទាំងការប្រព្រឹត្តតាមរយៈឧស្សាហកម្ម ឧក្រិដ្ឋកម្មរួម) បញ្ជា ញុះញង់ រៀបចំផែនការ ដឹកនាំ ឬសមគំនិតដោយការជួយឬជំរុញ ឬបង្កលក្ខណៈងាយស្រួលដល់ការប្រព្រឹត្តឧក្រិដ្ឋកម្ម ឬទទួលខុសត្រូវក្នុងនាមជាអ្នកដឹកនាំ ចំពោះឧក្រិដ្ឋកម្មដូចខាងក្រោម ដែលត្រូវបានប្រព្រឹត្តនៅចន្លោះពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី ៦ ខែមករា ឆ្នាំ១៩៧៩៖

- ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ៖ មនុស្សឃាត ការសម្លាប់ផ្តាច់ពូជ ការដាក់ក្នុងមន្ទីរ ឃុំឃាំង ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ផ្សេងទៀត។
- ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ៖ ការសម្លាប់រង្គាលក្រុមជនជាតិវៀតណាមនិងចាម។
- ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ៖ មនុស្សឃាតដោយចេតនា ការធ្វើទារុណកម្មឬការប្រព្រឹត្តអមនុស្សធម៌ ការបង្កដោយចេតនាឱ្យមាន របួសធ្ងន់ធ្ងរឬឱ្យមានការឈឺចាប់ដល់រូបរាងកាយឬសុខភាព ការដកហូតដោយចេតនា ពីឈ្លើយសឹកឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ក្តីដោយយុត្តិធម៌ ការបង្ខាំងនិងការ និរទេសជនស៊ីវិលដោយខុសច្បាប់។
- អំពើមនុស្សឃាត ៖ ការធ្វើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញខាងផ្នែកសាសនា ដូច មានចែងក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦។

ខៀវ សំផន បានបដិសេធរាល់បទចោទប្រកាន់ទាំងអស់មកលើគាត់។[63] ជនជាប់ចោទទាំងពីរត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩ និងអំពើប្រល័យប្រឆាំងនឹងជនជាតិចាម និងជនជាតិវៀតណាម។ អង្គជំនុំជម្រះសាលាដំបូង បានបើកសវនាការបឋមនៅខែ មិថុនា ឆ្នាំ ២០១១។ ចាប់ពីពេលនោះមក យ៉ាងហោចណាស់ក៏សំណុំរឿង ០០២ ត្រូវបានបំបែកទៅជាសវនាការដាច់ដោយឡែកពីគ្នា ដែលសវនាការនីមួយៗដោះស្រាយផ្នែកផ្សេងគ្នានៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

ជនជាប់ចោទពីនាក់ផ្សេងទៀតគឺ អៀង សារី និងប្រពន្ធរបស់គាត់ អៀង ធីរិទ្ធ ក៏ជាផ្នែកមួយនៃសំណុំរឿង ០០២ ផងដែរ។ កិច្ចដំណើរការនីតិវិធីប្រឆាំងនឹង អៀង សារី ត្រូវបានបញ្ចប់ ក្រោយពីគាត់បានស្លាប់នៅថ្ងៃដដែល

[62] សំណុំរឿង ០០២ នួន ជា, https://www.eccc.gov.kh/km/node/73

[63] សំណុំរឿង ០០២ ខៀវ សំផន, https://www.eccc.gov.kh/km/indicted-person/khiev-smphn

នេះ។ អៀង ធីរិទ្ធ ត្រូវបានបញ្ជូនទៅជំនុំជម្រះ ប៉ុន្តែ ក្រោយមកត្រូវបានរកឃើញ ថាពុំមានសម្បទាអាចចូលរួមក្នុងការជំនុំជម្រះបានទេ ដោយសារតែជំងឺវង្វេងស្មារតី ហើយត្រូវបានបំបែកចេញពីសំណុំរឿង។ ក្រោយពីការវាយតម្លៃឡើងវិញដោយអ្នកជំនាញផ្នែកវេជ្ជសាស្ត្រនៅក្នុងខែ សីហា ឆ្នាំ ២០១២ មក អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា អៀង ធីរិទ្ធ នៅតែពុំមានសម្បទាអាចចូលរួមក្នុងការជំនុំមជម្រះដដែល។ អ្នកជំនាញផ្នែកវេជ្ជសាស្ត្របានសន្និដ្ឋានថា មិនអាចមានការព្យាបាលបន្ថែមទៀតដើម្បីធ្វើឱ្យសម្បទាចូលរួមក្នុងសវនាការរបស់ អៀង ធីរិទ្ធ មានភាពប្រសើរឡើងបានទេ។ អៀង ធីរិទ្ធ ត្រូវបានដោះលែងពីមន្ទីរឃុំឃាំង និង បានបាត់បង់ជីវិត ថ្ងៃទី២២ ខែ សីហា ឆ្នាំ ២០១៥ មានអាយុ ៨៣ ឆ្នាំ។

- **សំណុំរឿង ០០២/០១**

ការជំនុំជម្រះដំណាក់កាលទីមួយ (សំណុំរឿង ០០២/០១) ត្រូវបានចាប់ផ្តើមនៅថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១១ ដោយផ្តោតជាចម្បងទៅលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលទាក់ទងនឹងការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញ និងក្រោយមកទៀត ចេញពីតំបន់ផ្សេងៗ (ដំណាក់កាលទីមួយ និងទីពីរ) និងការសម្លាប់ទាហាន លន់ នល់ នៅទីតាំងសម្លាប់មនុស្សទួលពោធិ៍ជ្រៃ បន្ទាប់ពីខ្មែរក្រហមឡើងកាន់អំណាចភ្លាមៗ ក្នុងឆ្នាំ ១៩៧៥។ អង្គជំនុំជម្រះសាលាដំបូង ក៏ពិចារណាទៅលើតួនាទីរបស់ជនជាប់ចោទទាក់ទិននឹងគោលនយោបាយ ដែលជាប់ពាក់ព័ន្ធនឹងបទចោទទាំងអស់ ដែលនឹងផ្តល់ជាមូលដ្ឋានសម្រាប់ការពិនិត្យទៅលើបទចោទសេសសល់ទាំងអស់ នៅក្នុងសវនាការនាពេលខាងមុខ។ សវនាការសួរដេញដោលលើភស្តុតាងក្នុងសំណុំរឿង ០០២/០១ ត្រូវបានបញ្ចប់នៅថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣ ហើយសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលត្រូវបានបញ្ចប់នៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣។ សាលក្រមសាលាដំបូងត្រូវបានប្រកាសនៅថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤។ នួន ជា និង ខៀវ សំផន ត្រូវបានតុលាការរកឃើញថា មានពិរុទ្ធភាពចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ហើយត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត។

ជនជាប់ចោទទាំងពីរនាក់បាននិយាយថា ពួកគាត់នឹងប្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនេះ។ នៅថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ អង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានប្រកាសសាលដីការបស់ខ្លួនលើបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនៅក្នុងសំណុំរឿង ០០២/០១ ដោយអង្គជំនុំជម្រះតុលាការកំពូលបានបដិសេធចោលការដាក់ពិរុទ្ធភាពមួយចំនួន និងតម្កល់ការផ្តន្ទាទោសឱ្យជាប់ពន្ធនាគារអស់មួយជីវិត ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ សម្រាប់ នួន ជា និង ខៀវ សំផន។[64]

---

[64] សំណុំរឿង ០០២/០១, https://www.eccc.gov.kh/km/case/topic/1295

អនុលោមតាមមាត្រា ៣៩ (ថ្មី) នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក. អង្គជំនុំជម្រះសម្រេចផ្ដន្ទាទោស ជន ជាប់ចោទ នួន ជា ដាក់ពន្ធនាគារអស់មួយជីវិត។ ដោយពិចារណាទៅលើការផ្ដន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតចំពោះគាត់ នៅក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះរួមបញ្ចូលគ្នានូវការផ្ដន្ទាទោសទាំងពីរ ទៅជាការផ្ដន្ទាទោសដាក់ពន្ធនាគារ អស់មួយជីវិត តែមួយ ។[65]

❖ **សំណុំរឿង ០០២/០២**

សវនាការលើអង្គសេចក្ដីក្នុងសំណុំរឿង ០០២/០២ បានចាប់ផ្ដើមនៅថ្ងៃទី ១៧ ខែតុលា ឆ្នាំ ២០១៤ ។ ការបង្ហាញភស្តុតាងបានចាប់ផ្ដើមនៅថ្ងៃទី ៨ ខែមករា ឆ្នាំ ២០១៥ និងបានបញ្ចប់នៅថ្ងៃទី ១១ ខែមករាឆ្នាំ ២០១៧។ សេចក្ដីប្រកាសបិទបញ្ចប់ត្រូវបានធ្វើឡើងចាប់ពីថ្ងៃទី ១៣ ដល់ ថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ២០១៧ ។ សាលក្រមក្នុងសំណុំរឿង ០០២/០២ ត្រូវបានរំពឹងទុក នៅក្នុងត្រីមាសទី ២ ឆ្នាំ ២០១៨ ។[66]

សំណុំរឿង ០០២/០២ គឺសំដៅលើការជំនុំជម្រះដំណាក់កាលទីពីរប្រឆាំងនឹង ខៀវ សំផន នឹង នួន ជា ដែលនឹងត្រូវជំនុំជម្រះទៅលើបទចោទបន្ថែមទៀត ពី (**ដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២**)។ នៅក្នុងសេចក្ដីសម្រេចមួយកាលពីថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ទីតាំងឧក្រិដ្ឋកម្ម និងការចោទប្រកាន់ផ្នែកអង្គហេតុខាងក្រោមនេះ នឹងបង្កើតបានជាមូលដ្ឋានសម្រាប់សំណុំរឿង ០០២/០២៖

- អំពើប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិចាម និងជនជាតិវៀតណាម (ដោយមិនរាប់បញ្ចូលនូវឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលប្រព្រឹត្តឡើងដោយកងទ័ពបដិវត្តន៍កម្ពុជានៅលើដែនដីវៀតណាមនោះឡើយ)។
- ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈ (នៅទូទាំងប្រទេស)។
- ការបោសសម្អាតផ្ទៃក្នុង។
- មន្ទីរសន្តិសុខ ស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់ មន្ទីរសន្តិសុខអូរកន្សែង និង មន្ទីរសន្តិសុខភ្នំក្រោល។
- ការដ្ឋានសាងសង់ទំនប់ ១ មករា ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង និងការដ្ឋានលើកទំនប់ត្រពាំងថ្ម។
- សហករណ៍ត្រាំកក់។
- ការប្រព្រឹត្តមកលើពុទ្ធសាសនិកជន (កម្រិតត្រឹមតែសហករណ៍ត្រាំកក់) និង

[65] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៃអ.វ.ត.ក,សំណុំរឿងលេខ៖០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ, ១៦ វិច្ឆិកា ២០១៨, ទំព័រ ៣៨៤០។
[66] សំណុំរឿង ០០២ https://www.eccc.gov.kh/km/case/topic/119

- ការកំណត់គោលដៅមកលើអតីតមន្ត្រីនៃរបបសាធារណរដ្ឋខ្មែរ (ការអនុវត្តនេះត្រូវបានកម្រិតត្រឹមតែសហករណ៍ត្រាំកក់ ការដ្ឋានសាងសង់ទំនប់ ១ មករា មន្ទីរសន្តិសុខ ស-២១ និងមន្ទីរសន្តិសុខក្រាំងតាចាន់) ។[67]

អនុលោមតាមមាត្រា ៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. អង្គជំនុំជម្រះសម្រេចផ្តន្ទាទោស ជនជាប់ចោទ ខៀវ សំផន ដាក់ពន្ធនាគារអស់មួយជីវិត។ ដោយពិចារណាទៅលើការផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតចំពោះគាត់ នៅក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះរួមបញ្ចូលគ្នានូវការផ្តន្ទាទោសទាំងពីរ ទៅជាការផ្តន្ទាទោសដាក់ពន្ធនាគារ អស់មួយជីវិត តែមួយ ។[68]

### ៣.១.៣ សំណុំរឿង ០០៣

សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចោទប្រកាន់ មាស មុត ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ និងការរំលោភបំពានក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦។ បទចោទទាំងនេះត្រូវបានកែប្រែនៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ និងបទចោទបន្ថែម (រួមទាំង បទប្រល័យពូជសាសន៍) ត្រូវបានចោទប្រកាន់ប្រឆាំង មាស មុត។

អង្គបុរេជំនុំជម្រះបានបើកសវនាការរយៈពេល ០៣ថ្ងៃ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ និងបានចេញរបាយការណ៍សាធារណៈ អំពីសំណុំរឿងនេះ និងបណ្តឹងឧទ្ធរណ៍។

- អំពើប្រល័យពូជសាសន៍ទៅលើជនជាតិវៀតណាម ដោយការសម្លាប់។
- ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ជាការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ពន្ធនាគារ ការដាក់ឱ្យទៅជាទាសករ អំពើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ និងនយោបាយ អំពើអមនុស្សធម៌ផ្សេងៗទៀត (ការធ្វើបាបដោយអមនុស្សធម៌ ការបាត់ខ្លួនដោយបង្ខំ ការធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរជាមនុស្ស ពលកម្មដោយបង្ខំ អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភផ្លូវភេទ)។
- ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ក្រោមទម្រង់ជាការបង្ខាំងជនស៊ីវិលដោយខុសច្បាប់ ការធ្វើមនុស្សឃាតដោយចេតនា ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬឱ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព និងអំពើទារុណកម្ម។
- ការរំលោភបំពានលើក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ គឺ អំពើមនុស្សឃាតដោយគិតទុកជាមុន។

ឧក្រិដ្ឋកម្មនានាដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តនៅតាមតំបន់ និងទីតាំងនានាដូចខាងក្រោម៖

---

[67] សំណុំរឿង ០០២/០២, https://www.eccc.gov.kh/km/case/topic/1298

[68] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៃអ.វ.ត.ក,សំណុំរឿងលេខ៖០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ, ១៦ វិច្ឆិកា ២០១៨, ទំព័រ ៣៨៤១។

- មន្ទីរសន្តិសុខ ស-២១
- ដែនទឹក និងនៅលើកោះដែលអះអាងថាកាន់កាប់ដោយកម្ពុជាប្រជាធិបតេយ្យ
- កំពង់សោម
- ទីតាំងសម្លាប់មនុស្សចម្ការទុរេន
- ការដ្ឋានកងកេង និង បិទត្រាង (តំបន់រាម)
- ការដ្ឋានស្ទឹងហាវ
- មន្ទីរសន្តិសុខទឹកសាប
- មន្ទីរសន្តិសុខវត្តឥន្ទញាណ[69]

យោងតាមវិធាន ៥៤ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក សហព្រះរាជអាជ្ញាជាតិ សូមធ្វើសេចក្តីប្រកាសព័ត៌មានជាសាធារណៈទាក់ទងនឹងស្ថានភាពនសំណុំរឿងលេខ ០០៣ ដែលមានជនជាប់ចោទឈ្មោះ មាស មុត ដូចខាងក្រោម៖

នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២១ អង្គជំនុំជម្រះតុលាការកំពូល បានសម្រេចប្រកាសបញ្ចប់សំណុំរឿងលេខ ០០៣ ដោយមូលហេតុគ្មានដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលអាចអនុវត្តបាន។

នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២១ សហចៅក្រមស៊ើបអង្កេតជាតិ និងអន្តរជាតិ បានសម្រេចជាឯកច្ឆ័ន្ទ ចេញដីកាបង្គាប់អោយបញ្ចូលសំណុំរឿងលេខ ០០៣ ទៅក្នុងបណ្ណសារដ្ឋាន។

សហព្រះរាជអាជ្ញាជាតិ សូមបញ្ជាក់ថា យោងតាមកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា និងយោងតាមច្បាប់ស្តីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានផ្តល់សមត្ថកិច្ចដល់ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាតែមួយគត់ក្នុងការកាត់សេចក្តីលើមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងអ្នកទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាង ធ្ងន់ធ្ងរទៅលើច្បាប់កម្ពុជា ដែលពាក់ព័ន្ធទៅនឹងអំពើឧក្រិដ្ឋ ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់អន្តរជាតិ និងរំលោភទៅលើអនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបាន ប្រព្រឹត្តក្នុងអំឡុងថ្ងៃ១៧ មេសា ១៩៧៥ ដល់ថ្ងៃ ៦ មករា ១៩៧៩។[70]

[69] សំណុំរឿង ០០៣, https://eccc.gov.kh/km/indicted-person/maas-mut

[70] សេចក្តីប្រកាស ព័ត៌មានជាសាធារណៈទាក់ទងនឹងស្ថានភាពនសំណុំរឿងលេខ ០០៣, https://www.eccc.gov.kh/km/articles/secktiiprkaasbtrmaanrpsshbrhraajqaajnyaajaati-daakdngnyngsthaanbhaabnaismnnumryanglekh003

### ៣.១.៤ សំណុំរឿង ០០៤

សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរចំនួនពីរដោយស្នើឱ្យសហចៅក្រមស៊ើបអង្កេតផ្តួចផ្តើមបើកកិច្ចស៊ើបសួរពាក់ព័ន្ធនឹងជនសង្ស័យប្រាំនាក់។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទាំងពីរនេះ ត្រូវបានបំបែកទៅជាសំណុំរឿង ០០៣ និង ០០៤។

សំណុំរឿង ០០៤ ជាសំណុំរឿងប្រឆាំងនឹង យឹម ទិត្យ ក្រោយពីការបំបែកសំណុំរឿងនេះរួចមក និងការបង្កើតបានជាសំណុំរឿង ០០៤/០១ (អ៊ឹម ចែម) និងសំណុំរឿង ០០៤/០២ (អោ អាន)។ នៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ ២០១៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចោទប្រកាន់ យឹម ទិត្យ នៅក្នុងសំណុំរឿង ០០៤។ នៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៧ កិច្ចស៊ើបសួរតាមផ្លូវតុលាការទៅលើសំណុំរឿង ០០៤ ត្រូវបានបិទជាលើកទីពីរ ក្រោយពីការដោះស្រាយលើសំណើសុំបន្ថែមមួយចំនួនពីសំណាក់ភាគីនានារួចមក។

សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយពីរដាច់ពីគ្នា។ សហចៅក្រមស៊ើបអង្កេតជាតិលើកលែង បទចោទប្រឆាំង យឹម ទិត្យ ដោយសារពុំមានយុត្តាធិការបុគ្គល ចំណែកឯសហចៅក្រមស៊ើបអង្កេតអន្តរជាតិចោទប្រកាន់ យឹម ទិត្យ បញ្ជូនទៅជំនុំជម្រះពីអំពើប្រល័យពូជសាសន៍ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងបទល្មើសថ្នាក់ជាតិ។

យឹម ទិត្យ ស្នើសុំការអនុញ្ញាតធ្វើអន្តរាគមន៍ ក្នុងសំណុំរឿង ០០៤/០២ ស្ថិតក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះតុលាការកំពូល៖

- អំពើប្រល័យពូជសាសន៍ទៅលើប្រជាជនខ្មែរក្រោម
- ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាអំពើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ឱ្យទៅជាទាសករ ការដាក់ពន្ធនាគារ ការធ្វើទារុណកម្ម ការនិរទេស អំពើអមនុស្សធម៌ផ្សេងៗទៀត (ការជម្លៀសដោយបង្ខំ ការបង្ខាំង និងការធ្វើការងារក្នុងលក្ខខណ្ឌអមនុស្សធម៌ អាពាហ៍ពិពាហ៍ដោយបង្ខំ) និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងពូជសាសន៍។
- ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ក្រោមទម្រង់ជាការធ្វើមនុស្សឃាតដោយចេតនា និងការជម្លៀស ឬការនិរទេសជនស៊ីវិលដោយខុសច្បាប់។
- ការរំលោភបំពានទៅលើក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ គឺ អំពើមនុស្សឃាតដោយចេតនា។

ឧក្រិដ្ឋកម្មទាំងនេះត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តនៅតាមតំបន់ និងទីតាំងនានាដូចខាងក្រោម៖

- ភូមិភាគនិរតី (តំបន់១៣)៖ មន្ទីរសន្តិសុខវត្តព្រះធាតុ មន្ទីរសន្តិសុខក្រាំងតាចាន់ ទីតាំងសម្លាប់មនុស្សភូមិព្រាល ទីតាំងសម្លាប់មនុស្សវត្តអង្គុញ ទីតាំងសម្លាប់មនុស្សព្រៃភូមិស្លែង ទីតាំងសម្លាប់មនុស្សព្រៃសុខុន និងវត្តអង្គសិរីមាលី។

- ភូមិភាគពាយ័ព្យ (តំបន់ ១)៖ មន្ទីរសន្តិសុខគាស់ក្រឡ សហាករណ៍ធិបតី (រួមទាំង មន្ទីរសន្តិសុខវត្តធិបតី និងមន្ទីរសន្តិសុខនិងការដ្ឋានទួលម្ទេស) ការដ្ឋានទំនប់កង្ហត់ មន្ទីរសន្តិសុខបាណន់ មន្ទីរសន្តិសុខខ្នងគូ និងការដ្ឋានរោងចក្រស្កសរកំពង់គល់។
- ភូមិភាគពាយ័ព្យ (តំបន់ ២)៖ មន្ទីរសន្តិសុខភូមិវាល មន្ទីរសន្តិសុខស្វាយជ្រុំ ទីតាំងសម្លាប់មនុស្សទួលសេះញ៉ូវ និងទីតាំងសម្លាប់មនុស្សព្រៃក្របៅ។
- ភូមិភាគពាយ័ព្យ (តំបន់ ៣)៖ មន្ទីរសន្តិសុខវត្តគិរីរម្យ។
- ភូមិភាគពាយ័ព្យ (តំបន់ ៤)៖ មន្ទីរសន្តិសុខឃុំកំពង់ព្រៀង (មន្ទីរសន្តិសុខវត្តពោធិ៍លង្កា ភូមិកាច់រទេះ ភូមិថ្មី និងភូមិសាលាត្រាវ) ឃុំរាំងកេសី មន្ទីរសន្តិសុខវត្តសម្តេច និងឃុំរាំងកេសី។
- «ភូមិភាគពាយ័ព្យ (តំបន់ ៧)៖ គុកលេខ ៨ និង ទីតាំងសម្លាប់មនុស្សវាល់បាក់ជញ្ជីង។[71]

យោងតាមវិធាន ៥៤ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក សហព្រះរាជអាជ្ញាជាតិ សូមធ្វើសេចក្តីប្រកាសព័ត៌មានជាសាធារណៈទាក់ទងនឹងស្ថានភាពនសំណុំរឿងលេខ ០០៤ ដែលមានជនជាប់ចោទឈ្មោះ យឹម ទិត្យ ដូចខាងក្រោម៖

នៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១ អង្គជំនុំជម្រះតុលាការកំពូល បានសម្រេចប្រកាសបញ្ចប់សំណុំរឿងលេខ ០០៤ ដោយមូលហេតុគ្មានដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលអាចអនុវត្តបាន។

នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២១ សហចៅក្រមស៊ើបអង្កេតជាតិ និងអន្តរជាតិ បានសម្រេចជាឯកច្ឆ័ន្ទ ចេញដីកាបង្គាប់អោយបញ្ចូលសំណុំរឿងលេខ ០០៤ ទៅក្នុងបណ្ណសារដ្ឋាន។

សហព្រះរាជអាជ្ញាជាតិ សូមបញ្ជាក់ថា យោងតាមកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា  និងយោងតាមច្បាប់ស្តីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានផ្តល់សមត្ថកិច្ចដល់ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាតែមួយគត់ក្នុងការកាត់សេចក្តីលើមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងអ្នកទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្ម និងការំលោភយ៉ាង ធ្ងន់ធ្ងរទៅលើច្បាប់កម្ពុជាដែលពាក់ព័ន្ធទៅនឹងអំពើឧក្រិដ្ឋ ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់អន្តរជាតិ និងរំលោភទៅលើអនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបាន ប្រព្រឹត្តក្នុងអំឡុងថ្ងៃ១៧ មេសា ១៩៧៥ ដល់ថ្ងៃ ៦ មករា ១៩៧៩។[72]

[71] សំណុំរឿង ០០៤/០១, https://eccc.gov.kh/km/case/topic/1661

[72] គេហទំព័រអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា,សេចក្តីប្រកាស ព័ត៌មានជាសាធារណៈទាក់ទងនឹងស្ថានភាពនសំណុំរឿងលេខ ០០៤, https://www.eccc.gov.kh/km/articles/secktiiprkaasbtrmaanrpsshbrhraajqaajnyaajaati-daakdngnyngsthaanbhaabnaismnnumryanglekh004

- **សំណុំរឿង ០០៤/១**

សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ដីកាបញ្ជូនរឿងឱ្យស៊ើបសួរចំនួន ២ ទៅសហចៅក្រមស៊ើបអង្កេត ស្នើសុំឱ្យបើកការស៊ើបអង្កេតលើឧក្រិដ្ឋកម្មពាក់ព័ន្ធនឹងជនសង្ស័យចំនួនប្រាំរូបទៀត។ ដីកាបញ្ជូនរឿងឱ្យស៊ើបសួរទាំងពីរនេះគឺ សំណុំរឿង ០០៣ និង សំណុំរឿង ០០៤។

សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចោទប្រកាន់អ្នកស្រី អ៊ឹម ចែម ដោយកំបាំងមុខនៅក្នុងសំណុំរឿង០០៤ ។

សហចៅក្រមស៊ើបអង្កេតបានច្រានចោលសំណុំរឿងប្រឆាំងនឹងអ៊ឹមចែមដោយបានរកឃើញថាលោកស្រីមិនត្រូវទទួលរងនូវយុត្តាធិការផ្ទាល់ខ្លួនរបស់ អ.វ.ត.ក ដែលមានន័យថាលោកស្រីមិនមែនជាមេដឹកនាំជាន់ខ្ពស់ ឬក៏មិនមែនជាមន្ត្រីដែលទទួលខុសត្រូវខ្ពស់បំផុតនៃរបបខ្មែរក្រហមឡើយ ។ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់បណ្ដឹងសាទុក្ខប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតទៅអង្គបុរេជំនុំជម្រះ។

អង្គបុរេជំនុំជម្រះនៃ (អ.វ.ត.ក) បានចេញការពិចារណារបស់ខ្លួន លើពាក្យបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត ដែលបានសម្រេចលើកលែងការចោទប្រកាន់ប្រឆាំងនឹង អ៊ឹម ចែម លើបទល្មើសព្រហ្មទណ្ឌនានាដោយមូលហេតុមិនមានយុត្តាធិការបុគ្គល។ អ៊ឹម ចែម ត្រូវបានដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យចំពោះឧក្រិដ្ឋកម្មៈ

- មនុស្សឃាត ដែលជាការរំលោភបំពានក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ ដែលបានប្រព្រឹត្តនៅមន្ទីរសន្តិសុខភ្នំទ្រយោង និងការដ្ឋានស្ពានស្រែង
- ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលក្នុងនោះមានការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងទៀតនៅមន្ទីរសន្តិសុខភ្នំទ្រយោង និង
- ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលក្នុងនោះមាន ការធ្វើមនុស្សឃាត ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង និងអំពើអមនុស្សធម៌ផ្សេងទៀតនៅការដ្ឋានស្ពានស្រែង។[73]

ជាឯកច្ឆ័ន្ទ អង្គបុរេជំនុំជម្រះ យល់ឃើញថា មានការខ្វះចន្លោះនៃនីតិវិធី ជាពិសេសទាក់ទងនឹងការកំណត់ភស្តុតាង និងការពន្យារពេល ដោយមិនសមស្របក្នុងការបិទការស៊ើបអង្កេត។

អង្គបុរេជំនុំជម្រះបានសម្រេចថា ច្បាប់ជាធរមានចំពោះមុខ អ.វ.ត.ក មិនបានដកហូតនូវសមត្ថកិច្ចរបស់តុលាការជាតិនោះទេ។ ចៅក្រមទាំង ៥រូបរបស់អង្គបុរេជំនុំជម្រះ មានការយល់ឃើញផ្សេងគ្នាចំពោះអង្គសេចក្ដីនៃបណ្ដឹងឧទ្ធរណ៍នេះ។ ចៅក្រម ៣ រូប បានយល់ឃើញថា អ.វ.ត.ក មិនមានយុត្តាធិការបុគ្គលចំពោះ អ៊ឹម ចែម។

[73] ជនជាប់ចោទ អ៊ឹម ចែម, https://www.eccc.gov.kh/km/indicted-person/qym-caem

ចៅក្រម ២ រូប បានយល់ឃើញថា មានភស្តុតាងគ្រប់គ្រាន់ក្នុងការចោទប្រកាន់ អ៊ឹម ចែម ថាជាជនម្នាក់ក្នុងចំណោមមនុស្សផ្សេងទៀត ដែលជាអ្នកទទួលខុសត្រូវខ្ពស់បំផុត និងជឿជាក់ថា អ.វ.ត.ក មានយុត្តាធិការបុគ្គលលើគាត់។ ដើម្បីបដិសេធសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត យើងត្រូវការសំឡេងគាំទ្រ ៤ លើ៥ ដូច្នេះសេចក្តីសម្រេចអំពីកង្វះយុត្តាធិការបុគ្គលលើ អ៊ឹម ចែម ត្រូវបានតម្កល់។ សេចក្តីសម្រេចនេះនឹងបិទបញ្ចប់នូវសំណុំរឿង អ.វ.ត.ក ០០៤/១។ ថ្ងៃទី ៥ ខែ កុម្ភៈ ឆ្នាំ ២០១៦ សំណុំរឿងនេះត្រូវបានបំបែកសំណុំឯកសារជាសំណុំរឿង ០០៤/១ ។[74]

- **សំណុំរឿង ០០៤/២**

កាលពីថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៩ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរចំនួនពីរដោយស្នើឱ្យសហចៅក្រមស៊ើបអង្កេតផ្តួចផ្តើមបើកកិច្ចស៊ើបសួរ ពាក់ព័ន្ធនឹងជនសង្ស័យប្រាំនាក់។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទាំងពីរនេះ ត្រូវបានបំបែកទៅជាសំណុំរឿង ០០៣ និង ០០៤។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិចោទប្រកាន់ អោ អាន នៅក្នុងសំណុំរឿង ០០៤ កាលពីថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៥ និងបានពង្រីកបទចោទប្រកាន់ នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៦។ នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ សហចៅក្រមស៊ើបអង្កេតទាំងពីរបានបញ្ចប់កិច្ចស៊ើបសួរប្រឆាំង អោ អាន ហើយសំណុំរឿងនេះត្រូវបានបំបែកចេញពីគ្នា ដោយបង្កើតបានជាសំណុំរឿង ០០៤/០២។ ការបំបែកសំណុំរឿងនេះត្រូវបានសម្រេចឡើង ដោយសារតែជនជាប់ចោទមានសិទ្ធិទទួលបានការជូនដំណឹងអំពីសេចក្តីសម្រេចលើបទចោទប្រឆាំងនឹងរូបគាត់ដោយមិនត្រូវឱ្យមានការពន្យារពេលហួសហេតុនោះឡើយ និងដើម្បីចេញដីកាដំណោះស្រាយនៅក្នុងពេលវេលាមួយសមស្របដោយអនុលោមតាមវិធាន ៦៧ និងវិធាន ២១(៤) នៃវិធានផ្ទៃក្នុងថាតើវាជាដីកាលើកលែងការចោទប្រកាន់ ឬជាដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ សហចៅក្រមស៊ើបអង្កេតទាំងពីរបានចេញដីកាដំណោះស្រាយពីរដាច់ដោយឡែកពីគ្នា នៅក្នុងសំណុំរឿងប្រឆាំងនឹង អោ អាន ដោយសារតែការមិនចុះសម្រុងគ្នាថាតើ អោ អាន ស្ថិតនៅក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ក្នុងឋានៈជាមេដឹកនាំជាន់ខ្ពស់ ឬជាបុគ្គលម្នាក់ក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យដែរឬអត់នោះ។

សហចៅក្រមស៊ើបអង្កេតជាតិយល់ឃើញថា អោ អាន មិនស្ថិតក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក នោះទេទោះជាក្នុងប្រភេទបុគ្គលមួយណាក៏ដោយ និងបានច្រានចោលសំណុំរឿងប្រឆាំងនឹង អោ អាន

[74] សំណុំរឿង ០០៤/០១, https://www.eccc.gov.kh/km/case/topic/1661

ដោយសារតែហេតុផលនេះឯង។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិយល់ឃើញថា អោ អាន ស្ថិតនៅក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ក្នុងឋានៈជាអ្នកទទួលខុសត្រូវជាន់ខ្ពស់ម្នាក់ និងថា មានភ័ស្តុតាងគ្រប់គ្រាន់ដើម្បីចោទប្រកាន់គាត់ពីបទប្រល័យពូជសាសន៍ជនជាតិចាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក៏ដូចជាបទល្មើសជាតិដែលស្ថិតនៅក្រោមច្បាប់កម្ពុជាផងដែរ។

សហមេធាវីរបស់ អោ អាន និងសហព្រះរាជអាជ្ញាជាតិបានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចំណែកសហព្រះរាជអាជ្ញាអន្តរជាតិបានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងការចោទប្រកាន់) របស់សហចៅក្រមស៊ើបអង្កេតជាតិ។ អង្គបុរេជំនុំជម្រះបានបើកសវនាការ *អសាធារណៈ* ចំនួនបីថ្ងៃ ដើម្បីសម្រេចលើបណ្តឹងឧទ្ធរណ៍នានាប្រឆាំងនឹងដីកាដំណោះស្រាយទាំងពីរ កាលពីថ្ងៃទី១៩, ២០ និង ២១ ខែមិថុនា ឆ្នាំ ២០១៩។ នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៩ អង្គបុរេជំនុំជម្រះបានដាក់សេចក្តីពិចារណារបស់ខ្លួន លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយទាំងនេះ។ អង្គបុរេជំនុំជម្រះបានប្រកាសជាឯកច្ឆន្ទថា "ការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នារបស់សហចៅក្រមស៊ើបអង្កេតទាំពីរ គឺខុសច្បាប់" ដោយសារតែអង្គបុរេជំនុំជម្រះ "មិនអាចរកសំឡេងគាំទ្រភាគច្រើនលើសលប់ដែលតម្រូវឱ្យបួនសំឡេង ដើម្បីឈានដល់ការចេញសេចក្តីសម្រេច ផ្អែកលើសំអាងហេតុរួមគ្នាលើអង្គសេចក្តីបាននោះ" ចៅក្រមទាំងទាំងអស់បានភ្ជាប់នូវមតិយោបល់របស់ពួកគាត់រៀងៗខ្លួនជាមួយនឹងសេចក្តីពិចារណាជាឯកច្ឆន្ទនេះ។[75] ដោយកត់សម្គាល់ឃើញថាមិនមានកិច្ចព្រមព្រៀងណាមួយត្រូវបានធ្វើឡើងថាតើ អោ អាន ស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត. បន្ទាប់ពីការស៊ើបអង្កេតអស់រយៈពេល ១៣ ឆ្នាំ អង្គជំនុំជម្រះតុលាការកំពូលបានរកឃើញថា គ្មានការចោទប្រកាន់ច្បាស់លាស់ និងអាចអនុវត្តបានប្រឆាំងនឹង អោ អាន បានទេ។ ដោយពិចារណាលើសិទ្ធិទទួលបានរបស់ភាគីនីមួយៗចំពោះការសំរេចចិត្តចុងក្រោយនៃកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះតុលាការកំពូលបានបញ្ចប់រឿងក្តីប្រឆាំងនឹង អោ អាន នៅចំពោះមុខ អ.វ.ត.ក។[76] បណ្តឹងសារទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងការបញ្ចប់អានុភាពសំណុំរឿង ០០៤/០២ របស់អង្គជំនុំជម្រះរបស់សាលាដំបូងត្រូវបានបដិសេធនៅក្នុងផ្នែកសម្រេចសេចក្តី។[77]

---

[75] សំណុំរឿង ០០៤/០២, https://www.eccc.gov.kh/km/case/topic/1691

[76] អង្គជំនុំជម្រះតុលាការកំពូលបញ្ចប់សំណុំរឿងប្រឆាំងនឹង អោន អាន នៅចំពោះមុខ អ.វ.ត.ក។

[77] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការបញ្ចប់អានុភាពសំណុំរឿង ០០៤/០២ របស់អង្គជំនុំជម្រះសាលាដំបូង,១០ សីហា ២០២០។

## ៣.២. សំណងជនរងគ្រោះ និង ការរក្សាទុកឯកសារសំខាន់ៗក្រោយពីអង្គជំនុំជម្រះ

ក្រោយពីមានសេចក្ដីសម្រេចទាំងឡាយរបស់ចៅក្រមក្នុងតុលាការ អ.វ.ត.ក និង មានការទាមទារពីជនរងគ្រោះទាក់ទងនឹងសំណង។ ជាគោលការរបស់រឿងក្ដីព្រហ្មទណ្ឌនេះ សំណងដែលទទួលបានពីពន្យសកម្មនៃការខូចខាតត្រូវតែមាន។ បន្ថែមពីនេះ ដោយសារតុលាការកូនកាត់នេះការរក្សាឯកសារជាការសំខាន់សម្រាប់ជាព័ត៌មានឱ្យជនរងគ្រោះបានដឹងឮ នឹងផ្សព្វផ្សាយ។ ពិសេសជាងនេះសម្រាប់អ្នកស្រាវជ្រាវច្បាប់ឱ្យសិក្សាបន្ថែមឱ្យកាន់តែស៊ីជម្រៅជាមុន ហេតុនេះទើបមាន មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ ទទួលបន្ទុកគ្រប់គ្រងថែរក្សាឯកសារទាំងនោះ។

### ៣.២.១. សំណងជនរងគ្រោះ

សំណងនៅក្នុង អ.វ.ត.ក គឺសំណងផ្លូវចិត្ត និងសមូហភាព បន្ថែមពីនេះ អ.វ.ត.ក មិនមានគោលការណ៍សំណងជាទឹកប្រាក់នោះទេ។[78] ប្រសិនបើជនជាប់ចោទត្រូវបានផ្ដន្ទាទោសដោយ អ.វ.ត.ក ជនរងគ្រោះអាចស្នើសុំទៅតុលាការឱ្យចេញដីកាបង្គាប់ឱ្យមានការសងសំណង។ នៅក្រោមច្បាប់កម្ពុជាបច្ចុប្បន្នភាគីដើមបណ្ដឹងរដ្ឋប្បវេណីអាចទាមទារសំណងក្នុងករណីបណ្ដឹងព្រហ្មទណ្ឌដែលគាត់បានរងគ្រោះ។ ចៅក្រមបានសម្រេចថា អង្គជំនុំជម្រះវិសាមញ្ញមិនអាចផ្ដល់សំណងជាថវិកាបានឡើយដោយហេតុថាជនរងគ្រោះមានចំនួនច្រើនលើសលប់។ ប៉ុន្តែជនរងគ្រោះអាចទទួលសំណងសមូហភាពនិងសំណងផ្លូវចិត្ត ដូចជាការតម្រូវឱ្យផ្សព្វផ្សាយជាសាធារណៈនូវសាលក្រមដោយចំណាយថវិការបស់ជនជាប់ចោទ ឬតុលាការអាចបញ្ជាឱ្យផ្ដល់ថវិកាសម្រាប់សកម្មភាព ឬសេវាកម្មនានាដែលមិនរកប្រាក់ចំណេញហើយដែលសកម្មភាពឬសេវាទាំងនោះគឺដើម្បីជាប្រយោជន៍ដល់ជនរងគ្រោះទូទៅ។[79] ចៅក្រមបានកំណត់ថាសំណងផ្នែកហិរញ្ញវត្ថុបុគ្គលនឹងមិនអាចធ្វើទៅបានទេទោះយ៉ាងណាពួកគេមានអំណាចក្នុងការផ្ដល់រង្វាន់អ្វីដែលគេហៅថា "សំណងសមូហភាពនិងសំណងផ្លូវចិត្ត" ។ នៅក្នុងបរិបទនេះ "សមូហភាព" មានន័យថាតុលាការអាចធ្វើការសំណងតែប៉ុណ្ណោះដែលផ្ដល់ប្រយោជន៍ដល់ដើមបណ្ដឹងរដ្ឋប្បវេណីជាក្រុមឬផ្ដល់ផលប្រយោជន៍ដល់ក្រុមជនរងគ្រោះឬសង្គមកម្ពុជា។ ពាក្យថាសំណង "សីលធម៌" នៅក្នុងបរិបទនេះសំដៅទៅលើប្រភេទជាក់លាក់នៃសំណងដែលតុលាការអាចបញ្ជាបាន។ សំណងថា "សីលធម៌" គឺជាសំណងជានិមិត្តរូបជាងពួកគេជាសារធាតុឬ សេដ្ឋកិច្ច ។ ឧទាហរណ៍នៃ "សំណងសមូហភាពនិងសំណងផ្លូវចិត្ត" អាចជាការបញ្ជាទិញដើម្បីបោះពុម្ពសាលក្រមរបស់តុលាការនៅក្នុងប្រព័ន្ធផ្សព្វផ្សាយតាមការចំណាយរបស់ជនជាប់ចោទ។ បញ្ជាទិញមូលនិធិ

---

[78] វិធាន ២៣ស្ទួន, អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, វិសោធនកម្មលើកទី១០។

[79] គេហទំព័រអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា,« តើជនរងគ្រោះមានសិទ្ធិទទួលសំណងដែរឬទេ?», https://www.eccc.gov.kh/km/about-eccc/faq

សេវាកម្មមិនរកប្រាក់ចំណេញឬសកម្មភាពផ្សេងទៀតដែលមានបំណងផ្តល់ប្រយោជន៍ដល់ជនរងគ្រោះ ឬការបង្កើតអនុស្សាវរីយ៍មួយ។ ទម្រង់បែបបទព័ត៌មានជនរងគ្រោះផ្តល់ឱ្យអ្នកដែលដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមានឱកាសដើម្បីស្នើសុំប្រភេទសំណងសមូហភាពនិងសំណងដែលពួកគេចង់ឱ្យតុលាការបញ្ជា។

### ៣.២.២. ការរក្សាទុកឯកសារសំខាន់ៗក្រោយពីអង្គជំនុំជម្រះ

មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ ពាក់ព័ន្ធនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ម.ត.ឯ.ច.) បង្កើតឡើងជាតម្រូវការសម្រាប់ការរៀបចំ ការអនុវត្តនូវកេរតំណែល និងការបន្សល់ទុករឿងក្តីរបស់សាលាក្តីខ្មែរក្រហម ។ ម.ត.ឯ.ច. នេះ បង្កើតឡើងដោយអនុក្រឹត្យលេខ ១៥៩ អនក្រ.បក ចុះថ្ងៃទី១៦ វិច្ឆិកា ឆ្នាំ ២០១៥។ ការខិតខំប្រឹងប្រែងជាបន្តទៀតរវាងរាជរដ្ឋាភិបាលកម្ពុជា ជាមួយអង្គការសហប្រជាជាតិ ក្នុងការអនុវត្តការផ្លាស់ប្តូរលិខិតទៅវិញទៅមក និងបានដាក់ចេញនូវលក្ខខណ្ឌដែលរាជរដ្ឋាភិបាលកម្ពុជានឹងធ្វើឱ្យមាន សម្រាប់ប្រើក្នុងពេលអនាគត ម.ត.ឯ.ច. និងបានសម្ពោធជាផ្លូវការនៅថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ ២០១៧ ក្រោមអធិបតីភាពឯកឧត្តម ប៊ិន ឈិន ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការ គណៈរដ្ឋមន្ត្រី និងឯកឧត្តម ហ៊ីដេហ៊ីសា ហូរិនូជិ ឯកអគ្គរដ្ឋទូតជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា ។ ម.ត.ឯ.ច. មានគោលបំណងតម្កល់ និងបម្រើការស្រាវជ្រាវ នូវសំណុំរឿងដែលបានមកពីការកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ដើម្បីឱ្យសាធារណៈជនអាចសិក្សាស្រាវជ្រាវ និងស្វែងយល់តាមរយៈឯកសារនានា ពាក់ព័ន្ធនឹងការជំនុំជម្រះក្តី នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ ការប្រើប្រាស់ដើម្បីផ្ទុកទាំងឯកសាររឹង ឯកសារទន់ រួមមានបណ្ណាល័យអេឡិចត្រូនិកដែលពាក់ព័ន្ធសវនាការខ្មែរក្រហម ការអនុវត្តពាក់ព័ន្ធនឹងសកម្មភាពជាកេរតំណែល និងការបន្សល់ទុករបស់ ECCC រួមបញ្ចូលគម្រោងសំណងក្រៅប្រព័ន្ធតុលាការ។

លើសពីនេះទៅទៀត ម.ត.ឯ.ច. មានសក្តានុពលដ៏រឹងមាំក្នុងការទទួលយក នូវកេរដំណែលដែលជាកេរមរកតរបស់អ.វ.ត.ក. សម្រាប់ការគ្រប់គ្រង ថែរក្សា និងបម្រើការស្រាវជ្រាវ ដោយផ្អែកលើ៖

១- នៅពាក់កណ្តាលឆ្នាំ១៩៩៧ រដ្ឋាភិបាលកម្ពុជាបានស្នើឱ្យអង្គការសហប្រជាជាតិជួយក្នុងការផ្តល់នូវដំណោះស្រាយរបស់តុលាការពីបទឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ ក្រោយពីការចរចាជាច្រើនឆ្នាំ កិច្ចព្រមព្រៀងមួយត្រូវបានចុះហត្ថលេខានៅថ្ងៃទី ៦ ខែមិថុនាឆ្នាំ២០០៣ រវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិ សម្រាប់ការចូលរួមពីអន្តរជាតិនៅសាលាក្តីខ្មែរក្រហម ដែលបង្កើតឡើងនៅក្រោមច្បាប់កម្ពុជា។ សាលាក្តីនេះបានផ្តល់ដល់ជនរងគ្រោះក្នុងការចូលរួមយ៉ាងពេញលេញនៅក្នុងដំណើរការតុលាការ ដែលមានតែមួយគត់ក្នុងចំណោមសាលាក្តីអន្តរជាតិ។

២- ការផ្លាស់ប្តូរលិខិតទៅវិញ ទៅមករវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៥ និងថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៥ ។

៣- អនុក្រឹត្យលេខ១៥៩ ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ ពាក់ព័ន្ធនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

៤- អនុស្សរណៈយោគយល់រវាងអ.វ.ត.ក តំណាងដោយដោយឯកឧត្តម ក្រាញ់ តូនី និង ឯកឧត្តម ចាន់ តានី រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ជាតំណាងរបស់ ដែលបានចុះហត្ថលេខានៅថ្ងៃទី១៨ ខែតុលា ឆ្នាំ ២០១៦ ។

៥- ការឯកភាព និងការគាំទ្រពីសំណាក់ សម្តេចអគ្គមហាសេបតី តេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងការដាក់បញ្ចូល ម.ត.ឯ.ច. ជាគម្រោងសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅថ្ងៃទី១១ វិច្ឆិកា ឆ្នាំ២០១៦ តាមរបាយការណ៍ស្តីពីការប្រកាសសាលដីកាស្ថាពរក្នុងសំណុំរឿង ០០២/០១ និងសំណើសុំរាជរដ្ឋាភិបាលគាំទ្រដល់គម្រោងសំណងចំពោះដើមបណ្តឹង រដ្ឋប្បវេណីក្នុងសំណុំរឿង ០០២/០២ របស់ឯកឧត្តមបណ្ឌិតព្រឹទ្ធាចារ្យ សុខ អាន ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ចុះនៅថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៦។ ទស្សនៈវិស័យៈ

បម្រើសាធារណៈដើម្បីសិក្សានិងដឹងអំពីនីតិវិធីនៃសាលាក្តីខ្មែរក្រហមដែលជាតុលាការកូនកាត់ដើម្បីនាំមេដឹកនាំខ្មែរក្រហមនៅរបបកម្ពុជាប្រជាធិបតេយ្យក្នុងឆ្នាំ 1975-1979 ឱ្យទៅរកយុត្តិធម៌នៅទាំងជាតិនិងអន្តរជាតិ។

ការរៀបចំ និងការប្រព្រឹត្តទៅមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ ពាក់ព័ន្ធនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ត្រូវបានបង្កើត ឡើងដោយអនុក្រឹត្យលេខ ១៥៩ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៥ ដែលបានផ្តល់តួនាទីនិងភារកិច្ច ដូចតទៅ ៖

- តម្កល់ឯកសារច្បាប់ និងឯកសារពាក់ព័ន្ធនានា ស្តីពីដំណើរការជំនុំជម្រះក្តីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលបានមកពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។
- បំពេញតួនាទីជានិហិដ្ឋាន(Depository)
- ផ្តល់ជាកន្លែងសម្រាប់អ្នកស្រាវជ្រាវជាតិ និងអន្តរជាតិផ្នែកគតិយុត្ត និងយុត្តាធិការពាក់ព័ន្ធនឹងការកាត់សេចក្តីអតីតមេដឹកនាំខ្មែរក្រហម។
- រៀបចំសិក្ខាសាលា និងវគ្គបណ្តុះបណ្តាល ដើម្បីឱ្យសាធារណជនបានយល់ដឹងអំពីដំណើរការ និងសមិទ្ធផលរបស់សាលាក្តីខ្មែរក្រហម។[80]

[80] គេហទំព័រមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ពាក់ព័ន្ធនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, https://www.ldc-eccc.gov.kh/index.php?pt=sub-category&p=2

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

សរុបសេចក្តីមក ក្រោយពីបានធ្វើការស្រាវជ្រាវអំពីសមត្ថកិច្ចអង្គជំនុំជម្រះក្នុងតុលាការកម្ពុជា ឬហៅកាត់ថា អ.វ.ត.ក ដែលជាតុលាការកូនកាត់ថ្មីមួយក្នុងប្រទេសកម្ពុជា ដែលធ្វើការជំនុំជម្រះបទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តក្នុងរបប កម្ពុជាប្រជាធិបតេយ្យ ក្នុងគោលបំណងស្វែងរកយុត្តធម៌ និង កាត់ទោសមេដឹកជាន់ខ្ពស់ខ្មែរក្រហម។ យោងតាមការសិក្សាស្រាវជ្រាវ ទៅលើអត្ថបទនេះ បានពិនិត្យ ឃើញថាតុលាការកូនកាត់នេះពិតមានសមត្ថកិច្ចអំណាចជាតុលាការគំរូរបស់ប្រជាជនខ្មែរពិតមែន ដោយមូលហេតុថាដែលយុត្តធិការបានកំណត់យ៉ាងជាក់លាក់ទៅលើការកាត់ទោសមេដឹកនាំជាន់ខ្ពស់ទាំង៩រូប នៅក្នុង ៤ សំណុំរឿងកន្លងមក និងសម្រេចរួមមកហើយ។

បន្ថែមពីនេះការគិតគូរពីនីតិវិធីតាមផ្នែកនីមួយៗរបស់ អ.វ.ត.ក នេះបានយក លំនាំតាមតុលាការក្នុងស្រុក និងបញ្ចូលយន្តការមួយចំនួនតាមកិច្ចព្រមព្រៀងជាមួយអង្គការសហប្រជាជាតិ ក្នុងនោះ លំដាប់ថ្នាក់របស់តុលាការរួមមាន សាលាដំបូង និង តុលាការកំពូល។ រីឯសមាសភាពក្នុងតុលាការគឺបែបចែកច្បាស់លាស់តាមការិយាល័យក្នុងនោះ មានការិយាល័យសហចៅក្រមស៊ើបអង្កេត ការិយាល័យសហព្រះរាជអាជ្ញា និង មានការិល័យរដ្ឋបាល។ ហើយអ្វីដែលជាចំណែកសំខាន់ ក៏ជាចំណុចពិសេសទៀតនោះ គឺអធិបតេយ្យភាពនៃអង្គជំនុំជម្រះ និងគោលការបំពេញបន្ថែមរបស់តុលាការព្រហ្មទណ្ឌអន្តរ ពោលគឺពិតមានការចូលរួមជាជំនួយរបស់បរទេស ប៉ុន្តែអធិតេយ្យភាព ឬដែនយុត្តាធិការបានកំណត់ ប្រើប្រាស់ច្បាប់ជាតិ និងអន្តរជាតិក្នុងការជំនុំជម្រះក្តីដោយយុត្តិធម៌ និងស្របតាមនិយាមយុត្តិធម៌អន្តរជាតិ។

បន្ថែមពីនេះកំណត់រយៈពេលនៃការកាត់ក្តី ដោយចន្លោះ ១៧ មេសា ១៩៧៤ ដល់ ៦ មករា ១៩៧៩ ក្នុងអំឡុងរបបកម្ពុជាប្រជាធិតេយ្យ ហើយក៏បានកំណត់បុគ្គល ដែលជាមេដឹកនាំជាន់ខ្ពស់នៃរបបខ្មែរក្រហម ជាអ្នកដែលទទួលខុសត្រូវ និង បានកំណត់យុត្តាធិការតាមបទល្មើស។

ពិសេសជាងតុលាការព្រហ្មទណ្ឌអន្តរជាតិទៀតនោះគឺជាការចូលរួមផ្ទាល់របស់ជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណីនេះឯង។ តុលាការកូនកាត់នេះបានបង្កើននូវសមត្ថកិច្ចរបស់ខ្លួនក្នុងនាមជាតុលាការកាត់ទោសតែមេដឹកនាំជាន់ខ្ពស់ក្នុងរបបខ្មែរក្រហម ដោយមានការចូលរួមពីជនរងគ្រោះ សូមបីតែតុលាការព្រហ្មទណ្ឌមកទល់បច្ចុប្បន្ននេះមិនទាន់បានធ្វើនៅឡើយ។

# ឯកសារយោង

# ឯកសារយោង

## សៀវភៅ និង អត្ថបទ


១. សហនិពន្ធ ផេង ពង្សរ៉ាស៊ី, ដេវីដ ឆេនដល័រ, គ្រីស្ទហ្វ័រ ឌៀវីង និង សុភ័ក្រ្ត ភាណា, សៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩) បោះពុម្ពលើកទី២ មជ្ឈមណ្ឌលឯកសារកម្ពុជា ២០២០។

២. កម្រងរឿងរ៉ាវរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, បោះពុម្ពផ្សាយលើកទី២ ខែមីនា ឆ្នាំ២០១៥។

៣. ឡុង សារ៉ាពេជ្រ, ព្រឹត្តិការណ៍អន្តរជាតិតុលាការព្រហ្មទណ្ឌអន្តរជាតិ ក្នុងបរិបទនៃ ការដកខ្លួនរបស់ប្រទេសរុស្ស៊ី ចេញពីរដ្ឋហត្ថលេខីនៃលក្ខន្តិកៈទីក្រុងរ៉ូម,ការផ្សព្វផ្សាយរបស់សមាគមសាលាត្រាជូ, ២០១៦។

៤. កញ្ញា ជាម សុទ្បែន និង កញ្ញា ជា ម៉ាន់នីតា, ការរៀបចំ និង ការប្រព្រឹត្តទៅនៃ អង្គជំនុំជម្រះវិសាញ្ញក្នុងតុលាការកម្ពុជា, សារណាបញ្ចប់ការសិក្សាឆ្នាំ ២០២២ ជំនាន់ទី២០ ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ។

៥. FIDH, របាយការតុលាការព្រហ្មទណ្ឌអន្តរជាតិ, ការសម្របនីតិកម្មកម្ពុជាទៅនឹងលក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ លេខ ៤៤៣ ខែមីនា ឆ្នាំ ២០០៦,


## លិខិតបទដ្ឋានជាតិ


៦. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣

៧. ព្រះរាជក្រឹតស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកត/០៧០៤/១២៤, ១៥ ខែកក្កដា ឆ្នាំ២០០៤

៨. ច្បាប់ស្ដីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, លេខ នស/រកម/១០០៤/០០៦,២៤ តុលា ២០០៤

៩. អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា , វិធានផ្ទៃក្នុងនៃ (វិសោធនកម្មលើកទី ១០នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២២.)

១០. សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៃអ.វ.ត.ក,សំណុំរឿងលេខៈ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ,១៦ វិច្ឆិកា ២០១៨។

១១. សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការបញ្ចប់អានុភាពសំណុំរឿង ០០៤/០២ របស់អង្គជំនុំជម្រះសាលាដំបូង,១០ សីហា ២០២០។

១២. សេចក្តីប្រកាស ព័ត៌មានជាសាធារណៈទាក់ទងនឹងស្ថានភាពនសំណុំរឿងលេខ ០០៤, ០៣ មករា ២០២២។

## លិខិតបទដ្ឋានអន្តរជាតិ

១៣. កិច្ចព្រមព្រៀងរវាងអង្គសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់ក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៣

១៤. Rome Statue of international Criminal court https://www.icc-cpi.int/sites/default/files/2024-05/Rome-Statute-eng.pdf

## គេហទំព័រ

១៥. គេហទំព័រ: អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា https://www.eccc.gov.kh/km

១៦. គេហទំព័រ: មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ ពាក់ព័ន្ធនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, https://www.ldc-eccc.gov.kh/index.php?pt=sub-category&p=14&p=13

១៧. គេហទំព័រ: Measboralaws អំពី យុត្តាធិការ https://www.measboralaws.com/images/pdf/books-magazines/88a6644c576f91c1e50662b216d9ab7c.pdf

# ឧបសម្ព័ន្ធ

# ព័ត៌មានសង្ខេបស្ដីអំពី
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)

ខែមីនា ឆ្នាំ២០១៣

## អ.វ.ត.ក ជាតុលាការកូនកាត់

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវបានបង្កើតឡើងនៅឆ្នាំ២០០៦ ដើម្បីកាត់សេចក្ដីមេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតនៃរបបខ្មែរក្រហម ចំពោះឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ (របបខ្មែរក្រហម) ចន្លោះពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។ នៅក្នុងអំឡុងពេលនោះ ប្រជាជនប្រមាណ ១,៧លាននាក់ ត្រូវបានជឿជាក់ថាស្លាប់ដោយកង្វះអាហារ ទារុណកម្ម ការកាប់សម្លាប់ និងការបង្ខំឱ្យធ្វើការបាក់កម្លាំង។

អ.វ.ត.ក គឺជា**តុលាការពិសេសកម្ពុជាដែលមានការចូលរួមពីអន្តរជាតិ** ត្រូវបានបង្កើតឡើងក្រោមច្បាប់កម្ពុជា បន្ទាប់ពីមានកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិឆ្នាំ២០០៣ ផ្ដល់ល័ក្ខខ័ណ្ឌឱ្យមានជំនួយបច្ចេកទេសនិងការចូលរួមរបស់អន្តរជាតិ។ យើងសង្ឃឹមថា តុលាការនេះនឹងនាំយុត្តិធម៌ជូនប្រជាជនកម្ពុជា ពង្រឹងនីតិរដ្ឋនៅកម្ពុជា និងលើកកម្ពស់ការផ្សះផ្សាជាតិ។

## ដែនយុត្តាធិការ

អ.វ.ត.ក ត្រូវបានបង្កើតឡើងក្នុងគោលបំណងផ្ដល់ការជំនុំជម្រះក្ដីដោយយុត្តិធម៌  និងស្របតាមនិយាមយុត្តិធម៌អន្តរជាតិ និងប្រើប្រាស់ទាំងច្បាប់ជាតិនិងច្បាប់អន្តរជាតិ។

**ដែនយុត្តាធិការលើពេលវេលា**របស់តុលាការត្រូវបានកំណត់ត្រឹម៖

- អំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩

**ដែនយុត្តាធិការលើបុគ្គល**៖

- មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ
- អ្នកដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ

**ដែនយុត្តាធិការតាមបទចោទ**៖

- ទារុណកម្ម មនុស្សឃាត និងការរើសអើងដោយមូលហេតុសាសនា ដែលមានចែងក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦
- អំពើប្រល័យពូជសាសន៍
- ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ
- ការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩
- ការបំផ្លិចបំផ្លាញសម្បត្តិវប្បធម៌ក្នុងអំឡុងពេលសង្គ្រាម
- ឧក្រិដ្ឋកម្មប្រឆាំងនឹងជនដែលត្រូវបានការពារដោយអនុសញ្ញាទីក្រុងវីយែនឆ្នាំ១៩៦១ ស្ដីអំពីទំនាក់ទំនងការបរទេស។

# កាលប្បវត្តិនៃការបង្កើត អ.វ.ត.ក

**១៧ មេសា ១៩៧៥** — ខ្មែរក្រហមដែលដឹកនាំដោយ ប៉ុល ពត បានកាន់កាប់អំណាចនៅកម្ពុជា។ ប្រជាជនកម្ពុជាជាង១,៧លាននាក់ត្រូវបានសម្លាប់មុនពេលដែលរបបនេះត្រូវបានផ្តួលរំលំនៅថ្ងៃ ៧ មករា ១៩៧៩។

**១៥ សីហា ១៩៧៩** — តុលាការប្រជាជនបដិវត្តន៍កម្ពុជាបានជំនុំជម្រះ អៀង សារី និង ប៉ុល ពត ពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។ តុលាការនេះពុំមានការទទួលស្គាល់ពីសហគមន៍អន្តរជាតិទេ ព្រោះវាពុំមានបទដ្ឋានយុត្តិធម៌អន្តរជាតិ។

**២១ មិថុនា ១៩៩៧** — រាជរដ្ឋាភិបាលកម្ពុជាស្នើទៅ អ.ស.ប សុំជំនួយអន្តរជាតិដើម្បីបង្កើតតុលាការមួយកាត់សេចក្តីអតីតមេដឹកនាំខ្មែរក្រហម។

**១៥ មីនា ១៩៩៩** — អ្នកជំនាញ អ.ស.ប លើកសំណើអំពីតុលាការសិទ្ធិមនុស្សមួយនៅក្រៅប្រទេសកម្ពុជា ដោយយកគំរូតាមតុលាការឧក្រិដ្ឋកម្មសម្រាប់ប្រទេសផ្សេងទៀត។ រាជរដ្ឋាភិបាលកម្ពុជាបដិសេធសំណើនេះ ហើយការចរចាបានអូសបន្លាយពេលវេលាយ៉ាងវែង។

**១០ សីហា ២០០១** — **ច្បាប់ស្តីពីការបង្កើត**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានប្រកាស ក៏ប៉ុន្តែ អ.ស.ប និងរាជរដ្ឋាភិបាលកម្ពុជាពុំទាន់ឈានដល់កិច្ចព្រមព្រៀងនៅឡើយទេ។

**៨ កុម្ភៈ ២០០២** — អ.ស.ប បានប្រកាសដកខ្លួនចេញពីការចរចាជាមួយរាជរដ្ឋាភិបាលកម្ពុជា អំពីតុលាការខ្មែរក្រហម។

**៦ មិថុនា ២០០៣** — នៅរាជធានីភ្នំពេញ រាជរដ្ឋាភិបាលកម្ពុជានិង អ.ស.ប បានចុះហត្ថលេខាលើ**កិច្ចព្រមព្រៀង**ស្តីពីការជំនុំជម្រះក្តីនៅក្រោមច្បាប់កម្ពុជាចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងក្រោមរបបកម្ពុជាប្រជាធិបតេយ្យ។

**២៧ តុលា ២០០៤** — សេចក្តីប្រកាសអំពីវិសោធនកម្មលើច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

**១៨ មករា ២០០៦** — រាជរដ្ឋាភិបាលកម្ពុជាប្រគល់ឲ្យ អ.វ.ត.ក នូវទីតាំងមួយកន្លែងដែលស្ថិតនៅជាប់នឹងអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ។

**៨ កុម្ភៈ ២០០៦** — បុគ្គលិកបានចូលធ្វើការជាលើកដំបូងបំផុត។

**៣ កក្កដា ២០០៦** — ចៅក្រមជាតិនិងអន្តរជាតិធ្វើពិធីស្បថចូលកាន់តំណែង។

**១២ មិថុនា ២០០៧** — អ.វ.ត.ក អនុម័ត**វិធានផ្ទៃក្នុង** ដើម្បីឲ្យតុលាការដំណើរការបានយ៉ាងពេញលេញ។

# រចនាសម្ព័ន្ធនៃ អ.វ.ត.ក




## បុគ្គលិក

អ.វ.ត.ក មានទាំងបុគ្គលិកនិងអ្នកច្បាប់ជាតិនិងអន្តរជាតិ។

គម្រោងថវិកាឆ្នាំ២០១៣ ដែលទើបតែបានកែប្រែរួច អាចឲ្យ អ.វ.ត.ក ជួលបុគ្គលិកចំនួន ៤៣៦នាក់។ ក្នុងនោះ ២៦៧នាក់ ជាបុគ្គលិកជាតិក្រោមកិច្ចសន្យាជាមួយរាជរដ្ឋាភិបាលកម្ពុជា ហើយ ១៦៩នាក់ ជាបុគ្គលិករបស់ អ.ស.ប។

## ហិរញ្ញវត្ថុ

ថវិកាដែលចំណាយសម្រាប់ដំណើរការរបស់ អ.វ.ត.ក គឺបានមកពីជំនួយវិភាគទានស្ម័គ្រចិត្តរបស់បណ្ដាប្រទេសម្ចាស់ជំនួយ។ រាជរដ្ឋាភិបាលកម្ពុជានិង អ.ស.ប ទទួលខុសត្រូវក្នុងការចាត់ចែងខ្ទង់ចំណាយ។

| | ភាគីជាតិ | ភាគីអន្តរជាតិ | សរុប |
|---|---|---|---|
| បានចំណាយ ២០០៦-២០១២ | $៤២,១ លាន | $១៣១.២ លាន | $១៧៣,៣ លាន |
| គម្រោង ២០១៣* | $៩,៤ លាន | $២៦ លាន | $៣៥,៤ លាន |

* *មិនរួមបញ្ចូលថវិកាបម្រុង*

**ម្ចាស់ជំនួយធំៗ៖** រាជរដ្ឋាភិបាលកម្ពុជា ប្រទេសជប៉ុន អូស្ត្រាលី សហរដ្ឋអាមេរិក អាល្លឺម៉ង់ បារាំង ចក្រភពអង់គ្លេស ន័រវែស និងសហភាពអឺរ៉ុប។

# នីតិវិធីនៅ អ.វ.ត.ក

យោងតាមច្បាប់តុលាការខ្មែរក្រហម កិច្ចព្រមព្រៀង និងវិធានផ្ទៃក្នុង ការកាត់សេចក្តីនៅចំពោះមុខ អ.វ.ត.ក ប្រព្រឹត្តទៅនៅក្នុងក្របខ័ណ្ឌប្រព័ន្ធច្បាប់ស៊ីវិល និងតាមដំណាក់កាលដូចខាងក្រោម ៖

### ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ

នេះគឺជាឯកសារលាយលក្ខណ៍អក្សរដែលសហព្រះរាជអាជ្ញាស្នើសុំទៅសហចៅក្រមស៊ើបអង្កេតឲ្យបើកការស៊ើបអង្កេត និងលើកសំណើសុំចោទប្រកាន់។

### ការស៊ើបអង្កេតតាមផ្លូវតុលាការ

សហចៅក្រមស៊ើបអង្កេតចាប់ផ្តើមស៊ើបអង្កេតតែទៅលើអង្គហេតុដែលបានលើកឡើងនៅក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួរ (និងដីកាបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ប្រសិនបើមាន) ហើយប្រហែលជាចោទប្រកាន់បុគ្គលណាម្នាក់ដែលបានលើកឡើងនៅក្នុងដីកានោះ។

### សវនាការនៅចំពោះមុខអង្គបុរេជំនុំជម្រះ

ភាគីអាចប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត អាចស្នើសុំឲ្យធ្វើមោឃភាពកិច្ចស៊ើបសួរ ឬអាចស្នើឲ្យដាក់ទណ្ឌកម្មលើបុគ្គលណាដែលត្រូវបានចោទប្រកាន់ថាជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ។

### សេចក្តីសន្និដ្ឋានស្ថាពរ

គឺជាឯកសារលាយលក្ខណ៍អក្សរដែលសហព្រះរាជអាជ្ញាស្នើសុំទៅសហចៅក្រមស៊ើបអង្កេតឲ្យចោទប្រកាន់ ឬតម្កល់សំណុំរឿងទុកមិនចាត់ការ។

### ដីកាដំណោះស្រាយ

ជាឯកសារដែលរៀបរៀងដោយសហចៅក្រមស៊ើបអង្កេតនៅចុងបញ្ចប់នៃការស៊ើបអង្កេតតាមផ្លូវតុលាការ។ វាគឺជាសេចក្តីសម្រេចចិត្តថានឹងត្រូវចោទប្រកាន់ ឬលើកលែងការចោទប្រកាន់ និងក៏ជាសេចក្តីសម្រេចចិត្តថាទទួលឬមិនទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ ដីកាដំណោះស្រាយបើកផ្លូវឲ្យមានបណ្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ។

### សវនាការជំនុំជម្រះក្តី

សហព្រះរាជអាជ្ញា ដើមបណ្តឹងរដ្ឋប្បវេណី មេធាវីការពារក្តី និងជនជាប់ចោទ ដាក់ភ័ស្តុតាងនិងសាក្សីជូនតុលាការ និងវិភាគភ័ស្តុតាងនិងសាក្សីរបស់ភាគីដទៃ ដើម្បីធានាការពិត។

### សាលក្រម

អង្គជំនុំជម្រះសាលាដំបូងសម្រេចចិត្តទៅលើសំណុំរឿង។ ប្រសិនបើរកឃើញថាជនជាប់ចោទមានទោស អង្គជំនុំជម្រះសាលាដំបូងនឹងចេញសាលក្រមដាក់ទោស ហើយប្រសិនបើអាច ផ្តល់សំណងរដ្ឋប្បវេណីដល់ជនរងគ្រោះ។

### ការប្តឹងសាទុក្ខទៅអង្គជំនុំជម្រះតុលាការកំពូល

សហព្រះរាជអាជ្ញា មេធាវីការពារក្តី និងដើមបណ្តឹងរដ្ឋប្បវេណី អាចដាក់ពាក្យបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចចិត្តរបស់អង្គជំនុំជម្រះសាលាដំបូង។ សេចក្តីសម្រេចចិត្តរបស់អង្គជំនុំជម្រះតុលាការកំពូលគឺជាសេចក្តីសម្រេចចិត្តស្ថាពរនិងបិទផ្លូវតវ៉ា។

# សំណុំរឿងនៅ អ.វ.ត.ក

អ.វ.ត.ក កំពុងដំណើរការសំណុំរឿងចំនួន ៤ ក្នុងនោះសំណុំរឿង ០០១ ត្រូវបានបញ្ចប់ជាស្ថាពរ។

## សំណុំរឿង ០០១


*កាំង ហ្កេកអ៊ាវ ហៅ ឌុច*

បានជំនុំជម្រះ កាំង ហ្កេកអ៊ាវ ហៅ ឌុច អតីតប្រធានមន្ទីរសន្តិសុខ ស-២១ (ទួលស្លែង) នៅទីក្រុងភ្នំពេញ ពីបទ**ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ** និង **ការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩** និងត្រូវផ្តន្ទាទោសកាលពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឲ្យជាប់ពន្ធនាគាររយៈពេល៣៥ឆ្នាំ។ ដោយមានបណ្តឹងសាទុក្ខពីសហព្រះរាជអាជ្ញា ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន និងមេធាវីការពារក្តី អង្គជំនុំជម្រះតុលាការកំពូលបានបើកការជំនុំជម្រះ បន្ទាប់មកប្រកាសសាលដីកានៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ដោយរក្សាសេចក្តីសម្រេចរបស់សាលាដំបូង បូកបន្ថែមទោសមួយចំនួនពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងអំពើអមនុស្សធម៌ និងបន្ថែមទោស ឌុច ឲ្យ**ជាប់ពន្ធនាគារអស់មួយជីវិត។**

## សំណុំរឿង ០០២


*នួន ជា*


*ខៀវ សំផន*


*អៀង សារី*


*អៀង ធីរិទ្ធ*

ពីដំបូង អតីតមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមចំនួន ៤ រូប ត្រូវបានចោទប្រកាន់ក្នុងសំណុំរឿង ០០២ ប៉ុន្តែបច្ចុប្បន្ននៅសល់តែជនជាប់ចោទ ២រូប ប៉ុណ្ណោះ គឺ **នួន ជា** អតីតអនុលេខាបក្សកុម្មុយនីស្តកម្ពុជា និង **ខៀវ សំផន** អតីតប្រមុខរដ្ឋ ដែលកំពុងប្រឈមមុខនឹងការជំនុះជម្រះក្តីពីបទ៖

- **ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ៖** ការសម្លាប់រង្គាល ការដាក់ជាទាសករ ការនិរទេសការឃុំឃាំង ការធ្វើទារុណកម្ម ការរើសអើង
- **ការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩៖** មនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម ការឃុំឃាំងជនស៊ីវិលដោយខុសច្បាប់ និងអំពើអមនុស្សធម៌ផ្សេងៗទៀត
- **អំពើប្រល័យពូជសាសន៍៖** ការសម្លាប់រង្គាលជនជាតិចាមនិងវៀតណាម

អង្គជំនុំជម្រះសាលាដំបូងបានបើកសវនាការបឋមលើសំណុំរឿង ០០២ កាលពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១១ និងបើកសវនាការដំបូងនៅចុងខែវិច្ឆិកា ឆ្នាំ២០១១ ផ្តោតទៅលើការជម្លៀសប្រជាជនដោយបង្ខំ និងទៅលើបទឧក្រិដ្ឋនានាក្រោមឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។

បទចោទប្រកាន់នានាប្រឆាំងនឹង **អៀង សារី** អតីតឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស ត្រូវបានលុបចោលបន្ទាប់ពីមរណភាពរបស់គាត់នៅខែមីនា ឆ្នាំ២០១៣។ ដោយឡែក បទចោទប្រកាន់ប្រឆាំងនឹង **អៀង ធីរិទ្ធ** អតីតរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ស្ថិតនៅដដែលតាំងពីខែវិច្ឆិកា ឆ្នាំ២០១១ បើទោះជាគាត់ត្រូវបានរកឃើញថាពុំមានកាយសម្បទានិងបញ្ញាស្មារីគ្រប់គ្រាន់ដើម្បីចូលរួមក្នុងការជំនុំជម្រះក្តី ដោយសារជំងឺបាត់ការចងចាំ។

## សំណុំរឿង ០០៣ និង ០០៤

សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ដីកាបញ្ជូនសំណុំរឿងឲ្យស៊ើបសួរ ទៅឲ្យសហចៅក្រមស៊ើបអង្កេត នៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០០៩ ស្នើសុំឲ្យមានការស៊ើបអង្កេតលើជនសង្ស័យចំនួន៥រូបបន្ថែមទៀត។ សំណុំរឿង ០០៣ និង ០០៤ កំពុងស្ថិតនៅក្នុងដំណាក់កាលស៊ើបអង្កេតតាមផ្លូវតុលាការ។

# ការចូលរួមរបស់ជនរងគ្រោះ

អ.វ.ត.ក គឺជាតុលាការនិយាមអន្តរជាតិទី១ ដែលប្រើប្រព័ន្ធច្បាប់ស៊ីវិល និងមានការចូលរួមពីជនរងគ្រោះក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណីនិងជាដើមបណ្តឹងធម្មតា។ ដើមបណ្តឹងធម្មតាគឺអ្នកដែលជូនដំណឹងទៅសហព្រះរាជអាជ្ញា អំពីឧក្រិដ្ឋកម្មដែលគាត់ជឿថាត្រូវបានប្រព្រឹត្ត ហើយដើមបណ្តឹងរដ្ឋប្បវេណីគឺជាអ្នកដែលរងគ្រោះដោយផ្ទាល់ពីឧក្រិដ្ឋកម្មដែលតុលាការកំពុងតែស៊ើបអង្កេត និងជាអ្នកដែលទាមទារសំណងរដ្ឋប្បវេណីនិងសំណងសមូហភាព។

| សំណុំរឿង ០០១ | តួលេខ |
|---|---|
| ពាក្យសុំដែលបានទទួល | ៩៤ |
| ដើមបណ្តឹងរដ្ឋប្បវេណីដែលបានចូលរួមក្នុងដំណើរការក្តី | ៩០<br>(ដកពាក្យវិញ៣នាក់ បដិសេធ១នាក់) |
| ពាក្យសុំដែលទទួលយកក្រោយពីការប្រកាសសាលដីកា | ៧៦<br>(បដិសេធ ១៤នាក់) |

| សំណុំរឿង ០០២ | តួលេខ |
|---|---|
| ពាក្យសុំដែលបានទទួល | ៤ ១០០ |
| ស្ថានភាពនៃពាក្យសុំបន្ទាប់ពីការសម្រេចចិត្តរបស់សហចៅក្រមស៊ើបអង្កេត | ៣ ៨៦៦<br>(២នាក់ ដកពាក្យវិញបន្ទាប់ពីត្រូវបានទទួលស្គាល់រួចហើយ, ១១នាក់ ដកពាក្យវិញ, ១០០នាក់ ត្រូវបដិសេធ, ១៧នាក់ ទទួលមរណភាព, ហើយ ១០៤នាក់ទៀត បានប្តូរទៅជាពាក្យបណ្តឹងធម្មតា) |

| សំណុំរឿង ០០៣ និង ០០៤ | សរុប | សំណុំរឿង ០០៣ | សំណុំរឿង ០០៤ |
|---|---|---|---|
| ពាក្យសុំដែលបានទទួល | ១ ២០២ | ៣២៣ | ៨៧៩ |
| ពាក្យសុំដែលទទួលបានត្រឹមថ្ងៃទី ៣១ មីនា ២០១៣ | ៨៨៨ | ៩ | ៥៦៥ |
| | | ៣១៤ | |

អ.វ.ត.ក បានទទួលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួនរាប់ពាន់ ពីជនរងគ្រោះនិងសាច់ញាតិរបស់ជនរងគ្រោះ។ តារាងខាងលើបង្ហាញតួលេខពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីតាមសំណុំរឿងនីមួយៗ។ សូមកត់សម្គាល់ថា បុគ្គលមួយចំនួនបានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនដង នៅក្នុងសំណុំរឿងខុសៗគ្នា។ ជាឧទាហរណ៍ មានតែពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួនតែ ២២៥ ប៉ុណ្ណោះ ក្នុងចំណោមពាក្យសុំទាំង ៨៨៨ ក្នុងសំណុំរឿង ០០៣ និង ០០៤ ដែលជាពាក្យសុំថ្មី។ ក្រៅពីនោះគឺជាពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឬពាក្យបណ្តឹងដែលបន្តពីសំណុំរឿងមុន (អាចជាសំណុំរឿង ០០១ ឬ ០០២ ឬទាំងពីរ)។

*(ប្រភព: អង្គភាពគាំពារជនរងគ្រោះ)*

## ព័ត៌មានសង្ខេបស្តីអំពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)

# ការយល់ឃើញរបស់ជនរងគ្រោះ

លទ្ធផលខាងក្រោមយោងតាមសម្ភាសន៍ជាមួយបណ្តឹងរដ្ឋប្បវេណីដែលជ្រើសរើសដោយព្រាវចេញពីក្នុងចំណោមដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២ ចំនួន ២០០០ នាក់ ដែលបានទទួលការឧបត្ថម្ភពីអង្គការអាដហុក។ (*ប្រភព: "ការចូលរួមរបស់ជនរងគ្រោះនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការ កម្ពុជា" ផ្សាយដោយអង្គការ អាដហុក ខែមករា ឆ្នាំ២០១៣ <http: //adhoccambodia.org/>*













# ការគាំទ្រនិងការចូលរួមរបស់សាធារណជន

អ.វ.ត.ក បានទទួលការគាំទ្រនិងការចូលរួមពីសាធារណជន ក្នុងចំនួនដ៏ច្រើនលើសលុបដែលមិនធ្លាប់មានពីមុនមក។ សាធារណជនជាង ៣១៩ ០០០ នាក់ បានមកឃើញ អ.វ.ត.ក ដោយផ្ទាល់ តាមរយៈកម្មវិធីផ្សព្វផ្សាយរបស់តុលាការ។

- គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ សាធារណជនជាង ១៨៧ ០០០ នាក់ រួមទាំងប្រជាពលរដ្ឋខ្មែរនៅតំបន់ចុងកាត់មាត់ញក និងជនបរទេស បានចូលទស្សនាសវនាការសាធារណៈ ឬចូលរួមក្នុងដំណើរទស្សនកិច្ចសិក្សា ឬកម្មវិធីទស្សនកិច្ចផ្សេងទៀតនៅ អ.វ.ត.ក។ ភាគច្រើននៃប្រជាជនកម្ពុជា គឺមកពីតាមបណ្តាខេត្តនានាទូទាំងព្រះរាជាណាចក្រកម្ពុជា។
- គ្រាន់តែក្នុងសំណុំរឿង ០០១ សាធារណជនចំនួន ៣៦ ៤៩៣ នាក់ បានតាមដានសវនាការ ហើយសាធារណជនចំនួន ៦៧ ៧០៥ នាក់ផ្សេងទៀត បានតាមដានសវនាការក្នុងសំណុំរឿង០០២ គិតត្រឹមខែធ្នូ ឆ្នាំ២០១២។
- ជាងនេះទៅទៀត ប្រជាជននៅតាមជនបទជាង ៦៦ ០០០ នាក់ បានចូលរួមក្នុងកម្មវិធីរាត្រីនៃការចងចាំ និងសិស្សនិស្សិតប្រមាណ ៦៦ ០០០ នាក់ បានស្តាប់បទបង្ហាញស្តីអំពីវិវឌ្ឍន៍ថ្មីៗរបស់ អ.វ.ត.ក។

| | Public Hearings (people/days) | KRT Study Tours (participants/tours) | Court Visits (people/groups) | VIP Visits (people/delegations) | Video Screenings (viewers/screenings) | School Lectures (students/schools) | TOTAL (people) |
|---|---|---|---|---|---|---|---|
| 2009 | 33,010/87 | 3,018/10 | N/A | N/A | N/A | 4,000/1 | 40,028 |
| 2010 | 3,326/5 | 29,291/80 | 1,780/69 | 151/23 | 31,118/71 | 16,100/5 | 81,766 |
| 2011 | 19,207/25 | 25,400/74 | 447/38 | 119/32 | 23,991/56 | 31,620/13 | 100,784 |
| 2012 | 60,492/133 | 10,147/ 31 | 949/46 | 90/18 | 10,926/23 | 14,100/20 | 96,474 |
| TOTAL | 116,035/250 | 67,856/195 | 3,176/153 | 360/73 | 65,805/150 | 65,820/39 | 319,052 |

# ការយល់ឃើញរបស់សាធារណជន

*លទ្ធផលខាងក្រោមមានប្រភពមកពីការស្ទង់មតិទៅលើប្រជាជនចំនួនពីរដង ពាក់ព័ន្ធនឹង អ.វ.ត.ក ម្តងមុនការចាប់ផ្តើមសវនាការក្នុងសំណុំរឿង ០០១ និងម្តងទៀតបន្ទាប់ពីការប្រកាសសាលដីកា។ (ប្រភព: "បន្ទាប់ពីសំណុំរឿងក្តីទីមួយ" ដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សនៃសាកលវិទ្យាល័យប៊ឺកលី កាលីហ្វ័រញ៉ា ខែមិថុនា ឆ្នាំ២០១១ <http://hrc.berkley.edu>)*

អ.វ.ត.ក ជួយឱ្យមានការផ្សះផ្សារជាតិ (% យល់ស្រប)




អ.វ.ត.ក នាំយុត្តិធម៌ជូនជនរងគ្រោះ និង/ឬក្រុមគ្រួសាររបស់ជនរងគ្រោះ




អ.វ.ត.ក ជួយស្តារទំនុកចិត្តនៅកម្ពុជាឡើងវិញ (% យល់ស្រប)




អ.វ.ត.ក នឹងផ្តល់ផលល្អឬអាក្រក់ចំពោះជនរងគ្រោះនិងក្រុមគ្រួសាររបស់គាត់




ពណ៌ខៀវ: *ផលល្អ, ពណ៌ក្រហម: ផលអាក្រក់, ពណ៌បៃតង: មិនដឹង*

អ.វ.ត.ក មានភាពអព្យាក្រឹត




ចៅក្រមនៅ អ.វ.ត.ក ប្រកាន់យុត្តិធម៌ ឬលម្អៀង (%យុត្តិធម៌)




ផ្លូវជាតិលេខ៤
សង្កាត់ចោមចៅ ខណ្ឌពោធិសែនជ័យ
ប្រអប់សំបុត្រលេខ ៧១
ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
(នៅទិសខាងលិចរាជធានីភ្នំពេញ ចម្ងាយ ១៦ គីឡូម៉ែត្រ ពីវត្តភ្នំ)

ទូរស័ព្ទទូទៅ +៨៥៥ (0)២៣ ៨៦១ ៥00
ទូរសារ +៨៥៥ (0)២៣ ៨៦១ ៥៥៥
សម្រាប់សារព័ត៌មាន +៨៥៥ (0)១២ ៨៦១ ៦៦៩
+៨៥៥ (0)១២ ៨៦១ ៥៦៤
ការចូលរួមរបស់ជនរងគ្រោះ +៨៥៥ (0)២៣ ២១៤ ២៩១
ទស្សនកិច្ចនៅតុលាការ +៨៥៥ (0)១២ ៨៦១ ៦៣៩

**អ.វ.ត.ក នៅលើអ៊ីនធឺណិត**

**ECCC** www.eccc.gov.kh
**UNAKRT** www.unakrt-online.org
**Email** info@eccc.gov.kh

**Twitter** twitter.com/KRTribunal
**Flickr** www.flickr.com/krtribunal
**Facebook** www.facebook.com/krtribunal
**Youtube** www.youtube.com/krtribunal

# ឧបសម្ព័ន្ធ ២

**ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញបូកជាមួយច្បាប់វិសោធនកម្មដែលបានប្រកាសឱ្យប្រើ ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ២០០៤ (នស/រកម/១០០៤/០០៦)**

# ច្បាប់

# ស្តីពី

# ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះរៀបចំឡើងក្នុងគោលបំណងវិនិច្ឆ័យទោស មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិនិងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអម្លុងថ្ងៃ ១៧ មេសា ១៩៧៥ ដល់ថ្ងៃ ៦ មករា ១៩៧៩។

## ជំពូកទី ២

## សមត្ថកិច្ច

**មាត្រា ២ ថ្មី.-**

ត្រូវបានបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងរចនាសម្ព័ន្ធតុលាការដែលមានស្រាប់ ពោលគឺសាលាដំបូង និង តុលាការកំពូល ដើម្បីជំនុំជម្រះមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និង ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់កម្ពុជា ដែលពាក់ព័ន្ធនឹងអំពើឧក្រិដ្ឋការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិ និង ទម្លាប់អន្តរជាតិ និងការរំលោភទៅលើអនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអម្លុងថ្ងៃ ១៧ មេសា ១៩៧៥ ដល់ ថ្ងៃ ៦ មករា ១៩៧៩។

មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និង អ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះអំពើឧក្រិដ្ឋខាងលើនេះ ហៅថា "ជនសង្ស័យ" ។

**មាត្រា ៣ ថ្មី.-**

អង្គជំនុំជម្រះវិសាមញ្ញមានអំណាចវិនិច្ឆ័យទោសជនសង្ស័យ ដែលបានប្រព្រឹត្តបទឧក្រិដ្ឋ ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ ១៧ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃ ៦ មករា ឆ្នាំ ១៩៧៩ :

- មនុស្សឃាត មាត្រា ៥០១. ៥០៣. ៥០៤. ៥០៥. ៥០៦. ៥០៧ និងមាត្រា ៥០៨
- ទារុណកម្ម មាត្រា ៥០០
- ការវាយប្រហារលើសាសនា មាត្រា ២០៩ និងមាត្រា ២១០ ។

អាជ្ញាយុកាលនៃបណ្តឹងអាជ្ញានៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ដែលទាក់ទងដល់បទល្មើសខាងលើ ត្រូវបានពន្យាពេលបន្ថែម ៣០ ឆ្នាំទៀត ទៅលើអាជ្ញាយុកាលនៃបណ្តឹងអាជ្ញាសម្រាប់ឧក្រិដ្ឋកម្មទាំងឡាយខាងលើ ដែលស្ថិតក្នុងសមត្ថកិច្ចនៃអង្គជំនុំជម្រះវិសាមញ្ញ ។

ទោសប្បញ្ញត្តិចែងក្នុងមាត្រា ២០៩, ៥០០, ៥០៦ និងមាត្រា ៥០៧ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦ ត្រូវកំណត់ថាអតិបរិមាត្រឹមទោសដាក់ពន្ធនាគារអស់មួយជីវិត អនុលោមតាមមាត្រា ៣២ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រ ម្ពុជា និងបញ្ជាក់បន្ថែមដោយមាត្រា ៣៨ និងមាត្រា ៣៩ ថ្មី នៃច្បាប់នេះ ។

**មាត្រា ៤.-**

អង្គជំនុំជម្រះវិសាមញ្ញមានអំណាចវិនិច្ឆ័យទោសជនសង្ស័យទាំងឡាយដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដូចមានចែងក្នុងអនុសញ្ញាឆ្នាំ ១៩៤៨ ស្តីពីការបង្ការនិងផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ហើយ ដែលបានប្រព្រឹត្ត ក្នុងអំឡុងថ្ងៃ ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃ ៦ ខែ មករា ឆ្នាំ ១៩៧៩ ។

អំពើប្រល័យពូជសាសន៍ដែលគ្មានអាជ្ញាយុកាល គឺជាអំពើមួយក្នុងចំណោមអំពើដូចខាងក្រោមហើយ ដែលបានប្រព្រឹត្តក្នុងគោលបំណងបំផ្លិចបំផ្លាញទាំងស្រុង ឬមួយផ្នែកនៃក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនាណាមួយដូចជា :

- ការធ្វើមនុស្សឃាតទៅលើសមាជិកនៃក្រុម
- ការធ្វើឱ្យរបួសយ៉ាងធ្ងន់ធ្ងរដល់រូបរាងកាយ ឬ សតិបញ្ញាសមាជិកនៃក្រុម

- ការធ្វើដោយចេតនាឱ្យក្រុមនេះ ទទួលរងនូវស្ថានភាពរស់នៅមួយដែលបានរៀបចំឡើង សម្រាប់បំផ្លិចបំផ្លាញរាងកាយទាំងស្រុង ឬមួយផ្នែក
- ការដាក់នូវវិធានការនានា ដែលមានបំណងរារាំងមិនឱ្យមានការផ្តល់កំណើតទារក
- ការបញ្ជូនកុមារដោយបង្ខំ ពីក្រុមមួយទៅឱ្យក្រុមមួយផ្សេងទៀត។

បទល្មើសខាងក្រោមត្រូវផ្តន្ទាទោសដូចបទល្មើសខាងលើដែរ :

- ការប៉ុនប៉ងប្រព្រឹត្តអំពើប្រល័យពូជសាសន៍
- ការសមគំនិតប្រព្រឹត្តអំពើប្រល័យពូជសាសន៍
- ការចូលរួមប្រព្រឹត្តអំពើប្រល័យពូជសាសន៍។

**មាត្រា ៥**.-

អង្គជំនុំជម្រះវិសាមញ្ញមានអំណាចវិនិច្ឆ័យទោសជនសង្ស័យទាំងឡាយ ដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងអំឡុងថ្ងៃ ១៧ ខែមេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃ ៦ ខែមករា ឆ្នាំ ១៩៧៩។

ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលគ្មានអាជ្ញាយុកាលគឺអំពើណាមួយដូចខាងក្រោម ដែលវាយប្រហារជាទូទៅ ឬដោយមានការរៀបចំប្រឆាំងទៅលើប្រជាជនស៊ីវិលដោយមូលហេតុ ជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬ សាសនា ណាមួយដូចជា :

- ការធ្វើមនុស្សឃាត
- ការសម្លាប់រង្គាល
- ការធ្វើឱ្យទៅជាទាសករ
- ការនិរទេស
- ការដាក់ក្នុងមន្ទីរឃុំឃាំង
- ការធ្វើទារុណកម្ម
- ការរំលោភលើផ្លូវភេទ
- ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយ ពូជសាសន៍ ឬ សាសនា
- អំពើអមនុស្សធម៌ផ្សេងៗទៀត។

**មាត្រា ៦**.-

អង្គជំនុំជម្រះវិសាមញ្ញមានអំណាចវិនិច្ឆ័យទោសជនសង្ស័យដែលបានប្រព្រឹត្ត ឬបានបញ្ជាឱ្យប្រព្រឹត្តអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ ដូចជាអំពើប្រឆាំង

មនុស្ស ឬទ្រព្យសម្បត្តិ ដែលត្រូវការពារដោយបទប្បញ្ញត្តិនៃអនុសញ្ញានេះ ហើយដែបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ ១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃ ៦ ខែមករា ឆ្នាំ១៩៧៩ :

- ការធ្វើមនុស្សឃាតដោយចេតនា
- ការធ្វើទារុណកម្ម ឬការធ្វើបាបដោយអមនុស្សធម៌
- ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬឱ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព
- ការបំផ្លាញ ឬធ្វើឱ្យខូចខាតធ្ងន់ធ្ងរទៅលើទ្រព្យសម្បត្តិ ដោយមិនមានហេតុផលចាំបាច់ខាងយោធា ដែល ធ្វើឡើងដោយខុសច្បាប់ និងគ្មានត្រាប្រណី
- ការបង្ខំឱ្យឈ្លើយសឹក ឬជនស៊ីវិល បម្រើការនៅក្នុងកងកម្លាំងរបស់គូបដិបក្ខ
- ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយ យុត្តិធម៌ និងទៀងទាត់
- ការនិរទេស ការជន្លៀស ឬការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់
- ការយកជនស៊ីវិលជាចំណាប់ខ្មាំង ។

**មាត្រា ៧.-**

អង្គជំនុំជម្រះវិសាមញ្ញមានអំណាចវិនិច្ឆ័យទោសជនសង្ស័យទាំងឡាយ ដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះការបំផ្លិចបំផ្លាញសម្បត្តិវប្បធម៌ក្នុងពេលមានជម្លោះប្រដាប់អាវុធ យោងតាមអនុសញ្ញាក្រុងឡាអេ ឆ្នាំ១៩៥៤ ស្តីពីការការពារសម្បត្តិ វប្បធម៌នៅក្នុងពេលមានជម្លោះប្រដាប់អាវុធ ហើយដែលបាន ប្រព្រឹត្តក្នុងអំឡុងថ្ងៃ ១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃ ៦ ខែមករា ឆ្នាំ១៩៧៩។

**មាត្រា ៨.-**

អង្គជំនុំជម្រះវិសាមញ្ញមានអំណាចវិនិច្ឆ័យទោសជនសង្ស័យដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះបទឧក្រិដ្ឋប្រឆាំងទៅលើអ្នកដែលទទួលបានការការពារជាអន្តរជាតិ យោងតាមអនុសញ្ញាទីក្រុងវីយែន ឆ្នាំ១៩៦១ ស្តីពីទំនាក់ទំនងការទូតហើយ ដែលបានប្រព្រឹត្ត ក្នុងអំឡុងថ្ងៃ ១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃ ៦ ខែ មករា ឆ្នាំ១៩៧៩។

## ជំពូកទី ៣

## សមាសភាពរបស់អង្គជំនុំជម្រះវិសាមញ្ញ

**មាត្រា ៩ ថ្មី.-**

សាលាដំបូងជាអង្គជំនុំជម្រះវិសាមញ្ញដោយចៅក្រមវិជ្ជាជីវៈប្រាំរូប ដែលរួមមានចៅក្រមខ្មែរបីរូប មួយរូបធ្វើជាប្រធាន និងមានចៅក្រមបរទេសពីររូប និងមានក្រឡាបញ្ជីមួយរូប ឬច្រើនរូប តាមការចាត់តាំងរបស់ប្រធានចូលរួម ព្រមទាំងមានសហព្រះរាជអាជ្ញាដែលត្រូវដាក់ពាក្យប្តឹងនៅចំពោះមុខសាលាដំបូងនេះ។

តុលាការកំពូលដែលជាកន្លែងទទួលពាក្យបណ្ដឹងឧទ្ធរណ៍ផងនិងសម្រេចសេចក្ដីចុងក្រោយផង ជាអង្គជំនុំជម្រះវិសាមញ្ញដោយចៅក្រមប្រាំពីររូប ដែលរួមមាន ចៅក្រមខ្មែរបួនរូប ដែលមួយរូបធ្វើជាប្រធាន និង ចៅក្រមបរទេសបីរូប និង មានក្រឡាបញ្ជីមួយរូប ឬច្រើនរូប តាមការចាត់តាំងរបស់ប្រធានចូលរួម ប្រមទាំងមានសហព្រះរាជអាជ្ញាដែលត្រូវដាក់ពាក្យប្ដឹងនៅចំពោះមុខតុលាការកំពូលនេះ ។

## ជំពូកទី ៤

## ការតែងតាំងចៅក្រមជម្រះក្ដី

**មាត្រា ១០ ថ្មី**.-

ចៅក្រមជម្រះក្ដីនៃអង្គជំនុំជម្រះវិសាមញ្ញ ត្រូវបានជ្រើសតាំងក្នុងចំណោមចៅក្រមក្នុងតំណែងបច្ចុប្បន្ន និង ចៅក្រមដែលបានជ្រើសតាំងបន្ថែមតាមនីតិវិធីនៃការជ្រើសតាំងចៅក្រមជាធរមាន ហើយដែលមានចរិតលក្ខណៈ និងសីលធម៌ខ្ពស់ មិនលំអៀង និងសុចរិត មានបទពិសោធន៍ក្នុងការងារជំនាញ ជាពិសេសខាងច្បាប់ព្រហ្មទណ្ឌ ឬច្បាប់អន្តរជាតិ ក្នុងនោះរួមមាន ច្បាប់មនុស្សធម៌អន្តរជាតិ និង ច្បាប់សិទ្ធិមនុស្សផង ។

ចៅក្រមជម្រះក្ដីត្រូវឯករាជ្យក្នុងការបំពេញការងាររបស់ខ្លួន ហើយមិនត្រូវទទួល ឬស្វែងរកការបង្គាប់បញ្ជាពីរដ្ឋាភិបាលណាមួយ ឬពីប្រភពណាមួយផ្សេងទៀតឡើយ ។

**មាត្រា ១១ ថ្មី**.-

ឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវជ្រើសតាំងចៅក្រមខ្មែរយ៉ាងតិចប្រាំពីររូប ឱ្យធ្វើជាចៅក្រមជម្រះក្ដីសម្រាប់អង្គជំនុំជម្រះវិសាមញ្ញ និងជ្រើសតាំងចៅក្រមជម្រះក្ដីបម្រុងមួយចំនួនតាមតម្រូវការ ព្រមទាំងត្រូវជ្រើសតាំងផងដែរនូវប្រធាននៃអង្គជំនុំជម្រះវិសាមញ្ញក្នុងចំណោមចៅក្រមខ្មែរខាងលើ តាមនីតិវិធីនៃការជ្រើសតាំងចៅក្រមជាធរមាន ។

ចៅក្រមបម្រុងខ្មែរត្រូវជំនួស ចៅក្រមជម្រះក្ដីខ្មែរពេញសិទ្ធិ នៅពេលដែលចៅក្រមនេះអវត្តមាន ឬមានធុរៈ ។ ចៅក្រមជម្រះក្ដីទាំងនេះ អាចបន្តបំពេញការងារប្រចាំថ្ងៃ នៅក្នុងសាលាជម្រះក្ដីដែលខ្លួនកំពុងបំពេញ ។

ឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវជ្រើសតាំងយ៉ាងតិច បុគ្គលប្រាំរូប ដែលមានសញ្ជាតិបរទេស ឱ្យធ្វើជាចៅក្រមជម្រះក្ដីបរទេសសម្រាប់អង្គជំនុំជម្រះវិសាមញ្ញ ក្រោយពីការជ្រើសរើសឱ្យឈរឈ្មោះដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

អគ្គលេខាធិការអង្គការសហប្រជាជាតិត្រូវរៀបចំបញ្ជីបេក្ខជនជាចៅក្រមបរទេស ដែលមានចំនួនយ៉ាងតិចប្រាំពីររូប ជូនរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ហើយឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវជ្រើសតាំង

ចៅក្រមពេញសិទ្ធិប្រាំរូប និងចៅក្រមបម្រុងយ៉ាងតិចពីររូបពីក្នុងបញ្ជីឈ្មោះនោះ។ បន្ថែមពីលើចៅក្រមបរទេស ដែលចូលរួមក្នុងអង្គជំនុំជម្រះវិសាមញ្ញ និងដែលមានវត្តមាននៅគ្រប់ដំណាក់កាលនៃដំណើរការជំនុំជម្រះ ប្រធានអង្គជំនុំជម្រះវិសាមញ្ញ អាចចាត់តាំងតាមករណីនីមួយៗ នូវចៅក្រមបម្រុងមួយរូប ឬច្រើនរូប ដែលត្រូវបានជ្រើសរើសរួចហើយ ដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមឱ្យមានវត្តមាននៅដំណាក់កាលជំនុំជម្រះនីមួយៗ ហើយឱ្យជំនួសចៅក្រមបរទេស ប្រសិនបើចៅក្រមរូបនោះ ពុំមានលទ្ធភាពអាច បន្តការជំនុំជម្រះតទៅទៀតបាន។

**មាត្រា ១២.-**

ចៅក្រមជម្រះក្តីទាំងអស់ ដែលស្ថិតក្រោមច្បាប់នេះ មានឋានៈ និងលក្ខខណ្ឌការងារស្មើៗគ្នាទៅតាមលំដាប់ថ្នាក់នៃអង្គជំនុំជម្រះវិសាមញ្ញនីមួយៗ។

ចៅក្រមជម្រះក្តីមួយរូបៗត្រូវបានជ្រើសតាំងសម្រាប់រយៈពេលនៃការជំនុំជម្រះ។

**មាត្រា ១៣.-**

ចៅក្រមជម្រះក្តីត្រូវមានបុគ្គលិកខ្មែរ និងបុគ្គលិកអន្តរជាតិជាជំនួយការ ទៅតាមតម្រូវការជាក់ស្តែងសម្រាប់បម្រើការងារនៅការិយាល័យរបស់ខ្លួន។

ក្នុងការជ្រើសរើសបុគ្គលិកជាជំនួយការ និងអ្នកជំនួយការច្បាប់ ប្រធានការិយាល័យរដ្ឋបាលត្រូវធ្វើសម្ភាសន៍ក្នុងករណីចាំបាច់ និងត្រូវមានការយល់ព្រមដោយមតិភាគច្រើនពីចៅក្រមខ្មែរ ក្នុងការជួលបុគ្គលិកដែលនឹងត្រូវតែងតាំងដោយរាជរដ្ឋាភិបាលកម្ពុជា។ អនុប្រធានការិយាល័យរដ្ឋបាលត្រូវមានភារកិច្ចទទួលខុសត្រូវចំពោះការជ្រើសរើស និងការគ្រប់គ្រងបុគ្គលិកអន្តរជាតិទាំងអស់។ ចំនួនបុគ្គលិក និងអ្នកជំនួយការច្បាប់ត្រូវជ្រើសរើសទៅតាមសមាមាត្រនៃចៅក្រមខ្មែរ និងចៅក្រម បរទេស។

បុគ្គលិកជាជំនួយការខ្មែរត្រូវជ្រើសរើសក្នុងចំណោមមន្ត្រីរាជការក្នុងក្របខ័ណ្ឌរដ្ឋ ឬ ជនជាតិខ្មែរដទៃទៀតដែលមាន សមត្ថភាពក្នុងករណីចាំបាច់។

## ជំពូកទី ៥

## ការសម្រេចសេចក្តីរបស់អង្គជំនុំជម្រះវិសាមញ្ញ

**មាត្រា ១៤ ថ្មី.-**

១-ចៅក្រមទាំងអស់ត្រូវព្យាយាមសម្រេចឱ្យបានភាពឯកច្ឆ័ន្ទក្នុងសេចក្តីសម្រេចរបស់ខ្លួន។ ប្រសិនបើភាពឯកច្ឆ័ន្ទនេះ ពុំអាចរកបានទេ ត្រូវអនុវត្តគោលការណ៍ដូចខាងក្រោម :

ក/ ការសម្រេចសេចក្តីដោយអង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូង តម្រូវឱ្យមានការបោះឆ្នោតគាំទ្រពីចៅក្រមបួនរូបយ៉ាងតិច ។

ខ/ ការសម្រេចសេចក្តីដោយអង្គជំនុំជម្រះវិសាមញ្ញរបស់តុលាការកំពូល តម្រូវឱ្យមានការបោះឆ្នោតគាំទ្រពីចៅក្រមប្រាំរូបយ៉ាងតិច ។

២-នៅពេលដែលពុំមានឯកភាពឯកច្ឆ័ននោះទេ សេចក្តីសម្រេចនៃអង្គជំនុំជម្រះត្រូវកត់ត្រាទុកនូវយោបល់របស់មតិភាគច្រើន និងមតិភាគតិច ។

**មាត្រា ១៥**.-

ប្រធានត្រូវធ្វើការកោះប្រជុំចៅក្រមដែលបានតែងតាំង នៅក្នុងរយៈពេលសមស្របដើម្បីដំណើរការងារនៃអង្គជំនុំជម្រះវិសាមញ្ញ ។

## ជំពូកទី ៦

## សហព្រះរាជអាជ្ញា

**មាត្រា ១៦**.-

រាល់ការសន្និដ្ឋានចោទប្រកាន់ជូនទៅអង្គជំនុំជម្រះវិសាមញ្ញ គឺជាការទទួលខុសត្រូវរបស់ព្រះរាជអាជ្ញាពីរនាក់ ម្នាក់ជាកម្ពុជា និងម្នាក់ទៀតជាបរទេសដែលហៅថា "សហព្រះរាជអាជ្ញា" ដែលត្រូវធ្វើការរួមគ្នាដើម្បីរៀបចំឯកសារ និងធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់ជនសង្ស័យសម្រាប់អង្គជំនុំជម្រះវិសាមញ្ញ ។

**មាត្រា ១៧ ថ្មី**.-

សហព្រះរាជអាជ្ញានៃសាលាដំបូងមានសិទ្ធិប្តឹងឧទ្ធរណ៍ ពីសេចក្តីសម្រេចនៃអង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូង ។

**មាត្រា ១៨ ថ្មី**.-

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវជ្រើសតាំងព្រះរាជអាជ្ញា និងព្រះរាជអាជ្ញាបម្រុងខ្មែរមួយចំនួនតាមតម្រូវការពីក្របខ័ណ្ឌចៅក្រមវិជ្ជាជីវៈខ្មែរ ។

ព្រះរាជអាជ្ញាបម្រុងត្រូវជំនួសព្រះរាជអាជ្ញាពេញសិទ្ធិ នៅពេលដែលព្រះរាជអាជ្ញានោះអវត្តមាន ឬមានធុរៈ ។

ព្រះរាជអាជ្ញាទាំងនេះអាចបន្តបំពេញការងារប្រចាំថ្ងៃនៅក្នុងសាលាជំនុំជម្រះក្តីដែលខ្លួនកំពុងបំពេញ ។

ព្រះរាជអាជ្ញាបរទេសមួយរូប ដែលមានសមត្ថកិច្ចបង្ហាញខ្លួនក្នុងគ្រប់លំដាប់ថ្នាក់ នៃអង្គជំនុំជម្រះវិសាមញ្ញ ត្រូវបានជ្រើសតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្រោយពីការជ្រើសរើសឱ្យឈរឈ្មោះដោយ អគ្គលេខាធិការអង្គការសហប្រជាជាតិ ។

អគ្គលេខាធិការអង្គការសហប្រជាជាតិត្រូវរៀបចំបញ្ជីបេក្ខជនយ៉ាងតិចពីររូប ជាសហព្រះរាជអាជ្ញាបរទេស ជូនរាជរដ្ឋាភិបាលកម្ពុជា ហើយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវជ្រើសតាំងព្រះរាជអាជ្ញាពេញសិទ្ធិមួយរូប និង ព្រះរាជអាជ្ញាបម្រុង មួយរូប ចេញពីបញ្ជីបេក្ខជននេះ ។

**មាត្រា ១៩.-**

សហព្រះរាជអាជ្ញាត្រូវបានជ្រើសតាំងក្នុងចំណោមបុគ្គលទាំងឡាយ ដែលបានជ្រើសតាំងតាមនីតិវិធីនៃការជ្រើសតាំងព្រះរាជអាជ្ញា ហើយដែលមានចរិតលក្ខណៈ និងស្មារតីខ្ពស់ សុចរិតនិងមានបទពិសោធន៍ជំនាញក្នុងការធ្វើការស៊ើបអង្កេត និងក្នុងការចោទប្រកាន់រឿងក្តីព្រហ្មទណ្ឌ ។

សហព្រះរាជអាជ្ញាត្រូវឯករាជ្យក្នុងការបំពេញមុខងាររបស់ខ្លួន និងមិនត្រូវទទួល ឬស្វែងរកការបង្គាប់បញ្ជាពីរដ្ឋាភិបាលណាមួយ ឬប្រភពណាមួយផ្សេងទៀតឡើយ ។

**មាត្រា ២០ ថ្មី.-**

សហព្រះរាជអាជ្ញាត្រូវធ្វើការចោទប្រកាន់ដោយអនុវត្តតាមនីតិវិធីដែលនៅជាធរមាន។ ប្រសិនបើនីតិវិធីដែលមានស្រាប់ពុំបានចែងពីករណីពិសេសមួយ ឬ ប្រសិនបើមានភាពមិនច្បាស់លាស់ក្នុងការបកស្រាយ ឬ អនុវត្តនីតិវិធីនោះ ឬ ប្រសិនបើមានបញ្ហាទាក់ទងទៅនឹងភាពសមស្របនៃនីតិវិធីទាំងនេះជាមួយបទដ្ឋានអន្តរជាតិ សហព្រះរាជអាជ្ញាអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ ។

ក្នុងករណីដែលមានភាពខ្វែងយោបល់គ្នារវាង សហព្រះរាជអាជ្ញ ត្រូវអនុវត្តគោលការណ៍ដូចខាងក្រោម :

ការចោទប្រកាន់ត្រូវបន្ត ដរាបណាសហព្រះរាជអាជ្ញា ឬក៏សហព្រះរាជអាជ្ញាម្នាក់ពុំបានស្នើក្នុងរយៈពេលសាមសិបថ្ងៃថា ភាពខ្វែងយោបល់គ្នាត្រូវបានដោះស្រាយ ដោយអនុលោមតាមបទប្បញ្ញត្តិដូចខាងក្រោម :

សហព្រះរាជអាជ្ញាត្រូវដាក់ជូននូវកំណត់ហេតុជាលាយលក្ខណ៍អក្សរអំពីអង្គហេតុ និងហេតុផលទាំងឡាយចំពោះ គោលជំហរខុសគ្នារបស់គេ ដល់ប្រធានការិយាល័យរដ្ឋបាល ។

ភាពខ្វែងយោបល់គ្នាត្រូវតែដោះស្រាយភ្លាម ដោយអង្គបុរេជំនុំជម្រះដែលមានចៅក្រមប្រាំរូប ចៅក្រមខ្មែរបីរូប ត្រូវបានជ្រើសតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដោយមានចៅក្រមមួយរូបជាប្រធាន ហើយនិង

ចៅក្រមបរទេស ពីររូប ត្រូវបានជ្រើសតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម បន្ទាប់ពីមានការជ្រើសរើសឱ្យឈរឈ្មោះ ដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

ការជ្រើសរើសចៅក្រមខាងលើនេះត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃមាត្រា ១០ ថ្មី នៃច្បាប់នេះ ។

បន្ទាប់ពីទទួលបានកំណត់ហេតុដូចដែលមានចែងនៅក្នុងកថាខ័ណ្ឌទី ៣ ប្រធានការិយាល័យរដ្ឋបាលត្រូវកោះប្រជុំអង្គបុរេជំនុំជម្រះជាបន្ទាន់ ហើយត្រូវជូនដំណឹងអំពីកំណត់ហេតុដល់សមាជិកអង្គបុរេជំនុំជម្រះ ។

សេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះដែលពុំបើកផ្លូវឱ្យមានបណ្ដឹងឧទ្ធរណ៍ តម្រូវឱ្យមានសំឡេងវិជ្ជមានពីចៅក្រម បួនរូបយ៉ាងតិច ។ សេចក្ដីសម្រេចនេះត្រូវជូនដំណឹងដល់ប្រធានការិយាល័យរដ្ឋបាលដែលត្រូវផ្សព្វផ្សាយសេចក្ដីសម្រេចនេះ ហើយជូនដំណឹងដល់សហព្រះរាជអាជ្ញា ។ សហព្រះរាជអាជ្ញាត្រូវចាត់ការបន្តជាបន្ទាន់ដោយអនុវត្តតាមសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ ។ ប្រសិនបើពុំមានមតិភាគច្រើន ដូចតម្រូវឱ្យមានចំពោះការធ្វើសេចក្ដីសម្រេចទេ ការចោទប្រកាន់ត្រូវធ្វើបន្ត ទៅទៀត ។

ក្នុងពេលធ្វើការចោទប្រកាន់ សហព្រះរាជអាជ្ញាអាចស្វែងរកការជួយឧបត្ថម្ភពីរាជរដ្ឋាភិបាលកម្ពុជា ប្រសិនបើការ ជួយឧបត្ថម្ភនេះពិតជាមានប្រយោជន៍ចំពោះការចោទប្រកាន់ ហើយការជួយឧបត្ថម្ភនេះត្រូវតែផ្ដល់ជូន ។

**មាត្រា ២១ ថ្មី.-**

សហព្រះរាជអាជ្ញាទាំងអស់ដែលស្ថិតក្រោមច្បាប់នេះមានឋានៈ និងលក្ខខណ្ឌការងារស្មើៗគ្នា ទៅតាមលំដាប់ថ្នាក់នៃអង្គជំនុំជម្រះវិសាមញ្ញនីមួយៗ ។

ព្រះរាជអាជ្ញាមួយរូបៗ ត្រូវបានជ្រើសតាំងសម្រាប់រយៈពេលនៃការជំនុំជម្រះ ។

ក្នុងករណីដែលព្រះរាជអាជ្ញាបរទេសអវត្តមាន ឬមានធុរៈ ត្រូវជំនួសដោយព្រះរាជអាជ្ញាបម្រុងបរទេស ។

**មាត្រា ២២ ថ្មី.-**

សហព្រះរាជអាជ្ញាមួយរូបៗមានសិទ្ធិជ្រើសរើសព្រះរាជអាជ្ញារងមួយរូប ឬច្រើនរូប ដើម្បីជួយខ្លួនក្នុងការធ្វើសេចក្ដីសន្និដ្ឋានចោទប្រកាន់នៅចំពោះមុខអង្គជំនុំជម្រះ ។ ព្រះរាជអាជ្ញារងបរទេស ត្រូវតែងតាំងដោយសហព្រះរាជអាជ្ញាបរទេសពីបញ្ជីផ្ដល់ដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

សហព្រះរាជអាជ្ញាត្រូវមានបុគ្គលិកខ្មែរ និងបុគ្គលិកអន្តរជាតិ ជាជំនួយការ ទៅតាមតម្រូវការជាក់ស្ដែងសម្រាប់បម្រើការងារនៅការិយាល័យរបស់ខ្លួន ។

ក្នុងការជ្រើសរើសបុគ្គលិកជាជំនួយការ ប្រធានការិយាល័យរដ្ឋបាលត្រូវធ្វើសម្ភាសន៍ ក្នុងករណីចាំបាច់ និងត្រូវមានការយល់ព្រមពីសហព្រះរាជអាជ្ញាខ្មែរ ក្នុងការជួលបុគ្គលិកដែលត្រូវតែងតាំងដោយរាជរដ្ឋាភិបាលកម្ពុជា ។

អនុប្រធានការិយាល័យ រដ្ឋបាលត្រូវទទួលខុសត្រូវចំពោះការជ្រើសរើស និងការគ្រប់គ្រងបុគ្គលិកបរទេសទាំងអស់។ ចំនួនបុគ្គលិក ជំនួយការត្រូវជ្រើសរើសតាមសមាមាត្រព្រះរាជអាជ្ញាខ្មែរ និងព្រះរាជអាជ្ញាបរទេស។

បុគ្គលិកជាជំនួយការខ្មែរត្រូវជ្រើសរើសក្នុងចំណោមមន្ត្រីរាជការក្នុងក្របខ័ណ្ឌរដ្ឋ ឬជនជាតិខ្មែរដទៃទៀត ដែលមាន សមត្ថភាពក្នុងករណីចាំបាច់។

## ជំពូកទី ៧

## អំពីការស៊ើបអង្កេត

**មាត្រា ២៣ ថ្មី.-**

រាល់ការស៊ើបអង្កេត គឺជាការទទួលខុសត្រូវរួមគ្នារបស់ចៅក្រមពីរនាក់ ម្នាក់ជាកម្ពុជា និងម្នាក់ទៀតជាបរទេស ដែលហៅថា "សហចៅក្រមស៊ើបអង្កេត" ដោយអនុវត្តតាមនីតិវិធីដែលនៅជាធរមាន។ ប្រសិនបើនីតិវិធីដែលមានស្រាប់ពុំបានចែងពីករណីពិសេសមួយ ឬ ប្រសិនបើមានភាពមិនច្បាស់លាស់ក្នុងការបកស្រាយ ឬ អនុវត្តនីតិវិធីនោះ ឬ ប្រសិនបើមានបញ្ហាទាក់ទងទៅនឹងភាពសមស្របនៃនីតិវិធីទាំងនេះជាមួយបទដ្ឋានអន្តរជាតិ សហចៅក្រមស៊ើបអង្កេតអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធី ដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ។

ក្នុងករណីដែលមានភាពមិនយល់ស្របគ្នា រវាងសហចៅក្រម ត្រូវអនុវត្តគោលការណ៍ដូចខាងក្រោម ៖

ការស៊ើបអង្កេតត្រូវធ្វើបន្ត ដរាបណាសហចៅក្រមស៊ើបអង្កេតទាំងពីរ ឬមួយរូប ក្នុងចំណោមពួកគេពុំបានប្តឹងមិនសុខចិត្តក្នុងរយៈពេលសាមសិបថ្ងៃ ថាភាពខ្វែងយោបល់គ្នាត្រូវដោះស្រាយដោយអនុវត្តតាមបទប្បញ្ញត្តិដូចខាងក្រោម ៖

សហចៅក្រមស៊ើបអង្កេតត្រូវជូនកំណត់ហេតុជាលាយល័ក្ខណ៍អក្សរ អំពីអង្គហេតុ និងហេតុផលទាំងឡាយចំពោះគោលជំហរខុសគ្នាដល់ប្រធានការិយាល័យរដ្ឋបាល។

ភាពខ្វែងយោបល់គ្នាត្រូវដោះស្រាយភ្លាមដោយអង្គបុរេជំនុំជម្រះដូចមានចែងក្នុងមាត្រា២០ នៃច្បាប់នេះ។

បន្ទាប់ពីទទួលបាននូវកំណត់ហេតុដូចមានចែងក្នុងកថាខ័ណ្ឌទី៣ រួចមកប្រធានការិយាល័យរដ្ឋបាល ត្រូវកោះប្រជុំអង្គ បុរេជំនុំជម្រះជាបន្ទាន់ ហើយជូនដំណឹងអំពីកំណត់ហេតុដល់សមាជិកអង្គបុរេជំនុំជម្រះ។

សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះដែលពុំបើកផ្លូវឱ្យមានបណ្តឹងឧទ្ធរណ៍ តម្រូវឱ្យមានសំឡេងវិជ្ជមាន ពីចៅក្រម បួនរូបយ៉ាងតិច។ សេចក្តីសំរេចនេះត្រូវជូនដំណឹងដល់ប្រធានការិយាល័យរដ្ឋបាលដែលត្រូវផ្សព្វផ្សាយសេចក្តីសម្រេចនេះ ហើយជូនដំណឹងដល់សហចៅក្រមស៊ើបអង្កេត។ សហចៅក្រមស៊ើបអង្កេតត្រូវចាត់ការបន្តជាបន្ទាន់ ដោយអនុវត្តតាមសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះនេះ។ ប្រសិនបើពុំមានមតិភាគច្រើនដូចដែលតម្រូវឱ្យមានចំពោះសេចក្តីសម្រេចការស៊ើបអង្កេតត្រូវ ធ្វើបន្តទៀត។

សហចៅក្រមស៊ើបអង្កេត អាចផ្អែកទៅលើមូលដ្ឋាននៃពត៌មាន ដែលទទួលបានពីស្ថាប័ននានា រួមមាន រដ្ឋាភិបាល ស្ថាប័ននានារបស់អង្គការសហប្រជាជាតិ ឬអង្គការក្រៅរដ្ឋាភិបាលជាដើម ។

សហចៅក្រមស៊ើបអង្កេតមានអំណាច ក្នុងការសួរចម្លើយជនសង្ស័យ ជនរងគ្រោះ និងស្តាប់ចម្លើយសាក្សី និងប្រមូលភស្តុតាងដោយអនុវត្តតាមនីតិវិធីជាធរមាន ។ ក្នុងករណីដែលសហចៅក្រមស៊ើបអង្កេត យល់ថាជាការចាំបាច់ខានមិនបានសហ ចៅក្រមស៊ើបអង្កេតអាចចេញដីកាសុំឱ្យសហព្រះរាជអាជ្ញា ធ្វើការសាកសួរសាក្សីបន្ថែមបាន ។

ក្នុងការអនុវត្តភារកិច្ចនេះ សហចៅក្រមស៊ើបអង្កេតអាចស្វែងរកការជួយឧបត្ថម្ភពីរាជរដ្ឋាភិបាលកម្ពុជាបាន ប្រសិនបើយល់ឃើញថាសមស្រប និងមានប្រយោជន៍ដល់ការស៊ើបអង្កេត ហើយការជួយឧបត្ថម្ភនេះត្រូវតែបានផ្តល់ជូន ។

**មាត្រា ២៤ ថ្មី.-**

ក្នុងដំណាក់កាលស៊ើបអង្កេត ជនសង្ស័យមានសិទ្ធិទទួលបានការការពារពីមេធាវី ដែលជ្រើសរើសដោយខ្លួនឯងដោយខានមិនបាន និងមានជំនួយផ្នែកច្បាប់ផល់ពួកគេដោយឥតគិតថ្លៃ ប្រសិនបើខ្លួនគ្មានលទ្ធភាពគ្រប់គ្រាន់ដើម្បីពឹងមេធាវី ព្រមទាំងមានសិទ្ធិទទួលបាន នូវការបកប្រែចាំបាច់ជាភាសាដែលជនសង្ស័យនិយាយនិងយល់បាន ។

**មាត្រា ២៥.-**

សហចៅក្រមស៊ើបអង្កេតត្រូវបានជ្រើសតាំងក្នុងចំណោមចៅក្រមក្នុងតំណែងបច្ចុប្បន្ន និងចៅក្រមដែលបានជ្រើសតាំងបន្ថែមតាមនីតិវិធីនៃការជ្រើសតាំងចៅក្រមជាធរមាន ហើយដែលមានចរិតលក្ខណៈ និងស្មារតីខ្ពស់សុចរិតមានបទពិសោធន៍ក្នុងការងារជំនាញ ។ សហចៅក្រមស៊ើបអង្កេតត្រូវឯករាជ្យក្នុងការបំពេញមុខងាររបស់ខ្លួនហើយមិនត្រូវទទួល ឬស្វែងរកការបង្គាប់បញ្ជាពីរដ្ឋាភិបាលណាមួយ ឬពីប្រភពណាមួយផ្សេងទៀតឡើយ ។

**មាត្រា ២៦.-**

សហចៅក្រមស៊ើបអង្កេតខ្មែរ និងចៅក្រមស៊ើបអង្កេតបម្រុងខ្មែរត្រូវបានជ្រើសតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមក្នុងចំណោមចៅក្រមវិជ្ជាជីវៈខ្មែរ ។

ចៅក្រមស៊ើបអង្កេតបម្រុងត្រូវជំនួសចៅក្រមស៊ើបអង្កេតពេញសិទ្ធិ នៅពេលណាដែលចៅក្រមនេះអវត្តមាន ឬមានធុរៈ ។ ចៅក្រមស៊ើបអង្កេតទាំងនេះអាចបន្តបំពេញការងារប្រចាំថ្ងៃនៅក្នុងសាលាជម្រះក្តីដែលខ្លួនកំពុងបំពេញ ។

ចៅក្រមស៊ើបអង្កេតបរទេសត្រូវបានជ្រើសតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សម្រាប់រយៈពេលនៃការស៊ើបអង្កេត បន្ទាប់ពីការជ្រើសរើសឱ្យឈរឈ្មោះដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ។ អគ្គលេខាធិការអង្គការសហប្រជាជាតិត្រូវរៀបចំបញ្ជីបេក្ខជនយ៉ាងតិចពីររូបជាចៅក្រមស៊ើបអង្កេតបរទេស ជូនរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ហើយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវជ្រើសតាំងសហចៅក្រមស៊ើបអង្កេតពេញសិទ្ធិមួយរូប និងបម្រុងមួយរូបពីបញ្ជីបេក្ខជននេះ។

**មាត្រា ២៧ ថ្មី.-**

ចៅក្រមស៊ើបអង្កេតទាំងអស់ ដែលស្ថិតក្រោមច្បាប់នេះ មានឋានៈ និងលក្ខខណ្ឌការងារស្មើៗគ្នា។

ចៅក្រមស៊ើបអង្កេតមួយរូបៗត្រូវបានជ្រើសតាំងសម្រាប់រយៈពេលនៃការស៊ើបអង្កេត។

ក្នុងករណីដែលសហចៅក្រមស៊ើបអង្កេតបរទេសណាមួយអវត្តមាន ឬមានធុរៈ ត្រូវជំនួសដោយចៅក្រមស៊ើបអង្កេតបម្រុងបរទេស។

**មាត្រា ២៨.-**

សហចៅក្រមស៊ើបអង្កេតមានបុគ្គលិកខ្មែរ និងបុគ្គលិកអន្តរជាតិជាជំនួយការទៅតាមតម្រូវការជាក់ស្តែងសម្រាប់បម្រើការនៅការិយាល័យរបស់ខ្លួន។

ក្នុងការជ្រើសរើសបុគ្គលិកជាជំនួយការ សហចៅក្រមស៊ើបអង្កេត ត្រូវអនុវត្តតាមស្មារតីនៃបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ១៣ នៃច្បាប់នេះ។

## ជំពូកទី ៨

## ការទទួលខុសត្រូវជាបុគ្គល

**មាត្រា ២៩ ថ្មី.-**

ជនសង្ស័យណាមួយ ដែលមានផែនការញុះញង់ បញ្ជា ប្រព្រឹត្ត ឬជួយនិងជំរុញក្នុងការរៀបចំផែនការ ឬការប្រព្រឹត្តឧក្រិដ្ឋកម្មក្នុងមាត្រា ៣ថ្មី. ៤. ៥. ៦. ៧ និងមាត្រា ៨ នៃច្បាប់នេះ ត្រូវទទួលខុសត្រូវជាបុគ្គលចំពោះឧក្រិដ្ឋកម្មនេះ។

តួនាទី ឬឋានៈរបស់ជនសង្ស័យមិនអាចជួយជននេះឱ្យរួចផុតពីការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋ ឬជួយបន្ថយទណ្ឌកម្មដល់ជននេះបានឡើយ។

ប្រការដែលថាសកម្មភាពណាមួយក្នុងចំណោមសកម្មភាពដែលមានចែងក្នុងមាត្រា ៣ថ្មី, ៤, ៥, ៦, ៧ និងមាត្រា ៨ នៃច្បាប់នេះ ត្រូវបានប្រព្រឹត្តដោយអ្នកនៅក្រោមបង្គាប់នោះមិនអាចជួយឱ្យថ្នាក់លើរួចផុតពីការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនោះបានទេ ប្រសិនបើថ្នាក់លើមានបញ្ជា និងមានការគ្រប់គ្រងដ៏មានប្រសិទ្ធិភាព ឬមានអំណាច និងការត្រួតពិនិត្យទៅលើអ្នក នៅក្រោមបង្គាប់ ហើយថ្នាក់លើបានដឹង និងមានហេតុផលដឹងថាអ្នកនៅក្រោមបង្គាប់ ប្រព្រឹត្ត ឬបានប្រព្រឹត្តនូវសកម្មភាព បែបនេះ ហើយខ្លួនមិនបានចាត់វិធានការចាំបាច់និងសមស្របដើម្បីបង្ការអំពើបែបនេះ ឬដាក់ទណ្ឌកម្មចំពោះការប្រព្រឹត្តបទឧក្រិដ្ឋនេះ។

ប្រការដែលថាជនសង្ស័យបានប្រព្រឹត្តអំពើឧក្រិដ្ឋ ទៅតាមបញ្ជារបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ឬរបស់ថ្នាក់ លើណាមួយ មិនអាចជួយជនសង្ស័យនេះ ឱ្យរួចផុតពីការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋនេះបានឡើយ។

## ជំពូកទី ៩
## ការិយាល័យរដ្ឋបាល

**មាត្រា ៣០.-**

បុគ្គលិកនៃអង្គជំនុំជម្រះវិសាមញ្ញសម្រាប់ចៅក្រមជម្រះក្តី ចៅក្រមស៊ើបអង្កេត និងព្រះរាជអាជ្ញាត្រូវគ្រប់គ្រងដោយការិយាល័យរដ្ឋបាលមួយ ។

ការិយាល័យនេះមានប្រធានខ្មែរមួយរូប អនុប្រធានបរទេសមួយរូប និងបុគ្គលិកមួយចំនួនតាមតម្រូវការជាក់ស្តែង ។

**មាត្រា ៣១ ថ្មី.-**

ប្រធានការិយាល័យរដ្ឋបាលត្រូវតែងតាំងដោយរាជរដ្ឋាភិបាលកម្ពុជាសំរាប់រយៈពេល ២ឆ្នាំ ហើយអាចត្រូវបានតែងតាំងបន្តទៀតបាន ។ ប្រធានការិយាល័យរដ្ឋបាលមានភារកិច្ចគ្រប់គ្រងទូទៅលើការងាររបស់ការិយាល័យរដ្ឋបាល លើកលែងតែការងារដែលស្ថិតនៅក្រោមបទបញ្ញត្តិ និងនីតិវិធីរបស់អង្គការសហប្រជាជាតិ ។

ប្រធានការិយាល័យរដ្ឋបាល ត្រូវបានជ្រើសរើសក្នុងចំណោមអ្នកដែលមានបទពិសោធន៍ខ្ពស់ក្នុងការងាររដ្ឋបាល តុលាការ មានភាពស្ទាត់ជំនាញលើភាសាណាមួយក្នុងចំណោមភាសាបរទេសដែលប្រើការក្នុងអង្គជំនុំជម្រះវិសាមញ្ញ ជាមនុស្សមានចរិតលក្ខណៈ និងស្មារតីខ្ពស់ និងសុចរិត ។

អនុប្រធានបរទេសនៃការិយាល័យរដ្ឋបាល ត្រូវជ្រើសតាំងដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ និងតែងតាំងដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងត្រូវទទួលខុសត្រូវចំពោះការជ្រើសរើស និងការគ្រប់គ្រងបុគ្គលិកអន្តរជាតិទាំងអស់ ដូចដែលបានតម្រូវឱ្យមានដោយសមាសភាគបរទេសនៃអង្គជំនុំជម្រះវិសាមញ្ញ សហ

ចៅក្រមស៊ើបអង្កេតការិយាល័យនៃសហព្រះរាជអាជ្ញា និងការិយាល័យរដ្ឋបាល។ អនុប្រធានការិយាល័យរដ្ឋបាលត្រូវគ្រប់គ្រងប្រាក់ធនធានដែលផ្តល់ជូនតាមរយៈមូលនិធិស្ម័គ្រចិត្តនៃអង្គការសហប្រជាជាតិ។

ការិយាល័យរដ្ឋបាលត្រូវមានបុគ្គលិកខ្មែរ និង បុគ្គលិកអន្តរជាតិជាជំនួយការ តាមតម្រូវការជាក់ស្តែង។

បុគ្គលិកខ្មែរទាំងអស់នៃការិយាល័យរដ្ឋបាល ត្រូវតែងតាំងដោយរាជរដ្ឋាភិបាលកម្ពុជា តាមសំណើរបស់ប្រធានការិយាល័យ។ បុគ្គលិកបរទេសត្រូវតែងតាំងដោយអនុប្រធានការិយាល័យរដ្ឋបាល។

បុគ្គលិកខ្មែរត្រូវជ្រើសរើសក្នុងចំណោមមន្ត្រីរាជការក្នុងក្របខ័ណ្ឌរដ្ឋ ឬជនជាតិខ្មែរដទៃទៀត ដែលមានសមត្ថភាពក្នុងករណីចាំបាច់។

**មាត្រា ៣២.-**

បុគ្គលិកទាំងអស់ដែលមានភារកិច្ចជួយជាជំនួយការដល់ចៅក្រមជម្រះក្តី ចៅក្រមស៊ើបអង្កេត ព្រះរាជអាជ្ញា និងការិយាល័យរដ្ឋបាល ទទួលបាននូវលក្ខខណ្ឌការងារដូចៗគ្នា ទៅតាមលំដាប់ថ្នាក់នៃអង្គជំនុំជម្រះវិសាមញ្ញនីមួយៗ។

## ជំពូកទី ១០
## កិច្ចដំណើរការនៃអង្គជំនុំជម្រះវិសាមញ្ញ

**មាត្រា ៣៣ ថ្មី.-**

អង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូងត្រូវប្រព្រឹត្តទៅឱ្យបានត្រឹមត្រូវ និងឆាប់រហ័សទៅតាមនីតិវិធីជាធរមាន ដោយមានការគោរពយ៉ាងពេញលេញនូវសិទ្ធិរបស់ជនត្រូវចោទ និងមាន ការការពាឱ្យបានត្រឹមត្រូវចំពោះជនរងគ្រោះ និងសាក្សី។ ប្រសិនបើនីតិវិធី ដែលមានស្រាប់ពុំបានចែងពីករណីពិសេសមួយ ឬ ប្រសិនបើមានភាពមិនច្បាស់លាស់ក្នុងការបកស្រាយ ឬ អនុវត្តនីតិវិធីនោះ ឬប្រសិនបើមានបញ្ហាទាក់ទងទៅនឹងភាពសមស្របនៃនីតិវិធីទាំងនេះជាមួយបទដ្ឋានអន្តរជាតិ គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុង កម្រិតអន្តរជាតិ។ អង្គជំនុំជម្រះវិសាមញ្ញរបស់សាលា ដំបូងត្រូវអនុវត្តយុត្តាធិការរបស់ខ្លួនសមស្រប តាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវនឹងដំណើរការសមស្របនៃច្បាប់ដូចដែលបានចែងក្នុងមាត្រា១៤ និង១៥ នៃអនុសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយ។ ជនសង្ស័យដែលត្រូវបានចោទប្រកាន់ ហើយត្រូវបានចាប់ខ្លួនត្រូវបញ្ជូនខ្លួនមកសាលាដំបូងតាមនីតិវិធីជាធរមាន។ រាជរដ្ឋាភិបាលត្រូវទទួលខុសត្រូវក្នុងការធានាសន្តិសុខចំពោះការចូលខ្លួន និងក្នុងការចាត់ការឱ្យចាប់ខ្លួនជនសង្ស័យ ដែលត្រូវបានចោទប្រកាន់តាមច្បាប់នេះ។ នគរបាលយុត្តិធម៌ត្រូវបានជួយឧបត្ថម្ភដោយអង្គភាពអនុវត្តច្បាប់ផ្សេងៗ ទៀតរបស់រាជរដ្ឋាភិបាលដែលរួមមានកងកម្លាំងប្រដាប់

អាវុធ ដើម្បីធានាឱ្យជនដែលត្រូវបានចោទប្រកាន់ត្រូវបាននាំខ្លួនមកក្នុងមន្ទីរឃុំឃាំងភ្លាមៗ។ លក្ខខណ្ឌនៃការចាប់ខ្លួននិងឃុំខ្លួនត្រូវអនុវត្តតាមច្បាប់ជាធរមាន។

តុលាការត្រូវផ្តល់ការការពារដល់ជនរងគ្រោះនិងសាក្សី។ វិធានការការពារទាំងនេះមិនត្រូវកម្រិតត្រឹមតែកិច្ចដំណើរការជំនុំជម្រះជាសម្ងាត់ និងការការពារទូវអត្តសញ្ញាណរបស់ជនរងគ្រោះឡើយ។

**មាត្រា ៣៤ ថ្មី.-**

អង្គជំនុំជម្រះវិសាមញ្ញត្រូវធ្វើជាសាធារណៈនិងបើកចំហសំរាប់តំណាងរបស់រដ្ឋបរទេស តំណាងរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ តំណាងបណ្តាញព័ត៌មាន និងតំណាងអង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ លើកលែងតែក្នុងកាលៈទេសៈពិសេស អង្គជំនុំជម្រះវិសាមញ្ញសម្រេចថា ត្រូវជំនុំជម្រះជាសម្ងាត់ដោយមានមូលហេតុត្រឹមត្រូវ ដោយយោងតាមនីតិវិធីជាធរមាន ដែលការផ្សព្វផ្សាយជាសាធារណៈធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍យុត្តិធម៌។

**មាត្រា ៣៥ ថ្មី.-**

ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ។

នៅក្នុងការចោទប្រកាន់មកលើខ្លួន ជនជាប់ចោទមានសិទ្ធិទទួលបានទូវការធានាជាអប្បបរមា និងស្មើៗគ្នាសមស្របតាមមាត្រា១៤ នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយឆ្នាំ ១៩៦៦ :

**ក**/ ទទួលពត៌មានភ្លាមៗ និងលម្អិតជាភាសាដែលខ្លួនយល់បានអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ចំពោះខ្លួន

**ខ**/ មានពេលវេលា និងលក្ខណៈគ្រប់គ្រាន់ ដើម្បីរៀបចំការពារខ្លួន និងទាក់ទងជាមួយមេធាវីរបស់ខ្លួនដែលជ្រើសរើសដោយខ្លួនឯង

**គ**/ ត្រូវបានទទួលការជំនុំជម្រះដោយគ្មានការអូសបន្លាយ

**ឃ**/ ត្រូវបានជំនុំជម្រះដោយមានវត្តមានរបស់ជនសង្ស័យ និង ការពារខ្លួនដោយខ្លួនឯង ឬតាមរយៈ មេធាវីដែលជ្រើសរើសដោយខ្លួនឯង ត្រូវបានប្រាប់អោយដឹងអំពីសិទ្ធិនេះ និងទទួលបានទូវជំនួយផ្នែកច្បាប់ដោយឥតគិតថ្លៃ ប្រសិនបើជនជាប់ចោទ គ្មានលទ្ធភាពជួលដោយខ្លួនឯង

**ង**/ ពិនិត្យភស្តុតាងដាក់បន្ទុក និងទទួលបានទូវការចូលរួម និងការពិនិត្យភស្តុតាងដោះបន្ទុក ក្នុងលក្ខខ័ណ្ឌដូចគ្នា និងភស្តុតាងដាក់បន្ទុកដែរ

**ច**/ មានការជួយឧបត្ថម្ភដោយសេរីពីអ្នកបកប្រែភាសា ប្រសិនបើជនជាប់ចោទមិនយល់ ឬមិនអាចនិយាយបានទូវ ភាសាដែលប្រើនៅក្នុងតុលាការ

ឆ/ មិនត្រូវបានគេបង្ខំឱ្យឆ្លើយប្រឆាំងនឹងខ្លួនឯង ឬបង្ខំឱ្យឆ្លើយសារភាពថាមានកំហុស។

**មាត្រា ៣៦ ថ្មី.-**

អង្គជំនុំជម្រះវិសាមញ្ញនៃតុលាការកំពូលជំនុំជម្រះលើបណ្តឹងសាទុក្ខរបស់ជនជាប់ចោទ របស់ជនរងគ្រោះ និងរបស់ សហព្រះរាជអាជ្ញា ពីសាលដីការរបស់អង្គជំនុំជម្រះវិសាមញ្ញនៃសាលាដំបូង ក្នុងករណីនេះ តុលាការកំពូល ពិនិត្យ សម្រេច ជាចុងក្រោយទាំងអង្គហេតុ ទាំងអង្គច្បាប់ដោយមិនបង្វិលសំណុំរឿងមកអង្គជំនុំជម្រះវិសាមញ្ញ នៃសាលាដំបូងវិញទេ។

**មាត្រា ៣៧ ថ្មី.-**

ប្រការដែលបានចែងនៅក្នុងមាត្រា៣៣ ៣៤ និង៣៥ ត្រូវអនុវត្តដូចគ្នាចំពោះការជំនុំជម្រះក្តីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញនៃតុលាការកំពូល។

## ជំពូកទី ១១

## ទោសបញ្ញត្តិ

**មាត្រា ៣៨.-**

ទណ្ឌកម្មទាំងអស់ដែលត្រូវយកមកដាក់ត្រូវកំណត់ត្រឹមទោសដាក់ពន្ធនាគារ។

**មាត្រា ៣៩ ថ្មី.-**

ជនទាំងឡាយដែលប្រព្រឹត្តបទឧក្រិដ្ឋណាមួយដូចមានចែងក្នុងមាត្រា ៣ថ្មី, ៤, ៥, ៦, ៧, និងមាត្រា ៨ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសឧក្រិដ្ឋ ដាក់ពន្ធនាគារ ពី ៥ ឆ្នាំ រហូតដល់មួយជីវិត។

ក្រៅពីទោសដាក់ពន្ធនាគារ អង្គជំនុំជម្រះវិសាមញ្ញនៃសាលាដំបូង អាចសម្រេចរឹបអូសទ្រព្យសម្បត្តិ ជាចលនវត្ថុ និងអចលនវត្ថុ និងលុយកាក់ដែលទទួលបានដោយខុសច្បាប់ ឬក៏បានដោយការប្រព្រឹត្តអំពើឧក្រិដ្ឋកម្ម។ ទ្រព្យសម្បត្តិដែលរឹបអូសបាននេះត្រូវប្រគល់ជូនរដ្ឋ។

## ជំពូកទី ១២

## ការលើកលែងទោសនិងការអនុគ្រោះទោស

**មាត្រា ៤០ ថ្មី.-**

រាជរដ្ឋាភិបាលកម្ពុជាមិនអាចស្នើសុំឱ្យមានការលើកលែងទោស ឬការអនុគ្រោះទោសដល់ជនទាំងឡាយណាដែលអាច ត្រូវបានស៊ើបអង្កេត ឬត្រូវបានផ្តន្ទាទោសអំពីឧក្រិដ្ឋកម្ម ដែលមានចែងក្នុងមាត្រា ៣ថ្មី, ៤, ៥, ៦, ៧, និង

មាត្រា៨ នៃច្បាប់នេះបានឡើយ។ វិសាលភាពនៃការលើកលែងទោស ឬ អនុគ្រោះទោសដែលអាចត្រូវបានផ្តល់អោយមុនការអនុម័តច្បាប់នេះ គឺត្រូវសំរេចដោយអង្គជំនុំជម្រះវិសាមញ្ញ។

## ជំពូកទី ១៣
## ឋានៈ សិទ្ធិ បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ

**មាត្រា ៤១**.-

ចៅក្រមបរទេស សហចៅក្រមស៊ើបអង្កេតបរទេស សហព្រះរាជអាជ្ញាបរទេស និងអនុប្រធានការិយាល័យរដ្ឋបាល រួមបញ្ចូលទាំងក្រុមគ្រួសាររបស់ពួកគេ ដែលជាផ្នែកនៃគ្រួសាររបស់ពួកគេ ត្រូវមានបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិទាំងអស់ ការរួចពន្ធ និងគ្រឿងបរិក្ខាប្រើប្រាស់ ដូចដែលផ្តល់ជូនដល់ភ្នាក់ងារការទូត ដោយអនុលោមតាមអនុសញ្ញាទីក្រុងវីយែនស្តីពីទំនាក់ ទំនងការទូតនាឆ្នាំ១៩៦១។ មន្ត្រីទាំងអស់នេះត្រូវបានរួចពីការជាប់ពន្ធលើប្រាក់បៀវត្សបរិលាភ និង វិភាជន៍របស់ពួកគេនៅក្នុងប្រទេសកម្ពុជា។

**មាត្រា ៤២ ថ្មី**.-

១-ចៅក្រមខ្មែរ សហចៅក្រមស៊ើបអង្កេតខ្មែរ សហព្រះរាជអាជ្ញាខ្មែរ និង បុគ្គលិកខ្មែរត្រូវបានផ្តល់អភ័យឯកសិទ្ធិឱ្យរួចផុត ពីដំណើរក្តីតាមផ្លូវច្បាប់ ចំពោះពាក្យពេចន៍ដែលបាននិយាយ ឬសរសេរ និងសកម្មភាពទាំងអស់ដែលបានបំពេញក្នុងតំណែងផ្លូវការរបស់គេ។ អភ័យឯកសិទ្ធិបែបនេះនៅតែមានជាបន្ត ក្រោយពីពួកគេបញ្ចប់ការងារជាមួយអង្គជំនុំជម្រះវិសាមញ្ញ អង្គបុរេជំនុំជម្រះ និងការិយាល័យរដ្ឋបាល។

២-បុគ្គលិកអន្តរជាតិ ត្រូវបានផ្តល់បន្ថែមនូវ :

- **ក**- អភ័យឯកសិទ្ធិឱ្យរួចផុតពីដំណើរក្តីតាមផ្លូវច្បាប់ចំពោះពាក្យពេចន៍ ដែលបាននិយាយ ឬសរសេរ និងសកម្មភាពទាំងអស់ដែលបានបំពេញក្នុងតំណែងផ្លូវការរបស់ពួកគេ។ អភ័យឯកសិទ្ធិបែបនេះនៅតែមានជាបន្ត ក្រោយពីពួកគេបញ្ចប់ការងារជាមួយសហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា អង្គជំនុំជម្រះវិសាមញ្ញ អង្គបុរេជំនុំជម្រះ និងការិយាល័យរដ្ឋបាល។
- **ខ**- អភ័យឯកសិទ្ធិឱ្យរួចផុតពីការបង់ពន្ធលើប្រាក់បៀវត្ស វិភាជន៍ និងបរិលាភដែលបើកជូនពួកគេដោយអង្គការសហប្រជាជាតិ។
- **គ**- អភ័យឯកសិទ្ធិឱ្យរួចផុតពីការដាក់កំហិតព្រំដែនអន្តោប្រវេសន៍។

**ឃ**- សិទ្ធិនាំចូលដោយរួចពន្ធអាករ គ្រឿងសង្ហារឹម និងសម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួនរបស់ពួកគេលើកលែងតែការចំណាយសម្រាប់សេវាកម្ម នៅពេលដែលមកទទួលភារកិច្ចផ្លូវការជាលើកដំបូងនៅប្រទេសកម្ពុជា។

**៣**-មេធាវីរបស់ជនសង្ស័យ ឬជនជាប់ចោទដែលត្រូវបានទទួលស្គាល់ថាជាមេធាវី ដោយអង្គជំនុំជម្រះ មិនត្រូវស្ថិតនៅក្រោមអំណាចរដ្ឋាភិបាល នូវវិធានការណាមួយដែលអាចប៉ះពាល់ដល់ការបំពេញមុខងារ ដោយសេរី និងឯករាជ្យរបស់ខ្លួន នៅក្រោមច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ។

ជាពិសេស មេធាវីត្រូវបានផ្តល់នូវៈ

**ក**- អភ័យឯកសិទ្ធិឱ្យរួចផុតពីការចាប់ ឬឃុំខ្លួន និងការរឹបអូសរបស់របរផ្ទាល់ខ្លួន ក្នុងក្របខ័ណ្ឌនៃការបំពេញភារកិច្ចរបស់ខ្លួនក្នុងរឿងក្តីនេះ

**ខ**- ភាពមិនអាចរំលោភបំពានបាន នូវឯកសារទាំងអស់ ដែលទាក់ទងដល់ការបំពេញមុខងាររបស់ខ្លួនជាមេធាវីរបស់ជនសង្ស័យ ឬជនជាប់ចោទ

**គ**- អភ័យឯកសិទ្ធិឱ្យរួចផុតពីយុត្តាធិការរដ្ឋប្បវេណី និងព្រហ្មទណ្ឌចំពោះពាក្យពេចន៍ដែលបាននិយាយ ឬសរសេរ និងសកម្មភាពដែលបានបំពេញ ក្នុងដំណែងផ្លូវការរបស់គេក្នុងនាមជាមេធាវី។ អភ័យឯកសិទ្ធិបែបនេះនៅបន្តផ្តល់ចំពោះពួកគេ ក្រោយពួកគេបញ្ចប់មុខងារជាមេធាវីរបស់ជនសង្ស័យ ឬជនជាប់ចោទ។

**៤**-បណ្ណសារដ្ឋានរបស់សហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា អង្គជំនុំជម្រះវិសាមញ្ញ អង្គបុរេជំនុំជម្រះ និងការិយាល័យរដ្ឋបាល និងជាទូទៅឯកសារនិងសម្ភារៈទាំងអស់ដែលអាចរកបាន ហើយដែលជាកម្មសិទ្ធិរបស់អ្នកទាំងនោះ ឬប្រើប្រាស់ដោយអ្នកទាំងនោះ ទោះជាស្ថិតនៅកន្លែងណានៃព្រះរាជាណាចក្រកម្ពុជាក៏ដោយ និងគ្រប់គ្រងដោយជនណាក៏ដោយ គឺមិនអាចត្រូវបានរំលោភបំពានបាន ក្នុងរយៈពេលនៃកិច្ចដំណើរការជំនុំជម្រះនេះឡើយ។

## ជំពូកទី ១៤
## ទីតាំងរបស់អង្គជំនុំជម្រះវិសាមញ្ញ

**មាត្រា ៤៣ ថ្មី**.-

អង្គជំនុំជម្រះវិសាមញ្ញដែលធ្វើឡើងនៅថ្នាក់សាលាដំបូង និងតុលាការកំពូល មានទីតាំងនៅក្នុងទីក្រុងភ្នំពេញ។

## ជំពូកទី ១៥
## ការចំណាយ

**មាត្រា ៤៤ ថ្មី.-**

ការចំណាយ និងប្រាក់បៀវត្ស របស់អង្គជំនុំជម្រះវិសាមញ្ញមានៈ

១-ការចំណាយនិងប្រាក់បៀវត្សចំពោះមន្ត្រីរដ្ឋបាល និងបុគ្គលិកខ្មែរ ចំពោះចៅក្រមជម្រះក្ដីនិងចៅក្រមជម្រះក្ដីបម្រុង ចៅក្រមស៊ើបអង្កេត និងចៅក្រមស៊ើបអង្កេតបម្រុង ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញាបម្រុងខ្មែរទាំងអស់ ជាបន្ទុករបស់ថវិកាជាតិខ្មែរ។

២-ការចំណាយចំពោះមន្ត្រីរដ្ឋបាល និងបុគ្គលិកបរទេស ចៅក្រមជម្រះក្ដី សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេតបរទេស ដែលបញ្ជូនមកដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ជាបន្ទុករបស់អង្គការសហប្រជាជាតិ។

៣-មេធាវីការពារក្ដី អាចទទួលប្រាក់កម្រៃពីកិច្ចការពារក្ដីរបស់ខ្លួន។

៤-ការចំណាយសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក៏អាចទទួលបន្ថែមនូវមូលនិធិស្ម័គ្រចិត្តដទៃទៀត ដូចជារដ្ឋាភិបាលបរទេស ស្ថាប័នអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាលនានា ហើយនិងបុគ្គលដែលមានបំណងចង់ជួយដល់កិច្ចដំណើរការនេះ។

## ជំពូកទី ១៦
## ភាសាការងារ

**មាត្រា ៤៥ ថ្មី.-**

ភាសាដែលប្រើប្រាស់ជាផ្លូវការក្នុងការងាររបស់អង្គជំនុំជម្រះវិសាមញ្ញ គឺភាសាខ្មែរ ភាសាអង់គ្លេស និងភាសាបារាំង។

## ជំពូកទី ១៧
## ករណីគ្មានចៅក្រមជម្រះក្ដី ចៅក្រមស៊ើបអង្កេត ឬព្រះរាជអាជ្ញាបរទេស

**មាត្រា ៤៦ ថ្មី.-**

ដើម្បីធានាការអនុវត្តច្បាប់នេះបានទាន់ពេលវេលា និងមិនរអាក់រអួល ក្នុងករណីដែលចៅក្រមជម្រះក្ដី ឬចៅក្រមស៊ើបអង្កេត ឬ ព្រះរាជអាជ្ញាបរទេសណាមួយមិនបានចូលរួម ឬ បដិសេធមិនចូលរួមក្នុងអង្គជំនុំជម្រះវិសាមញ្ញ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជ្រើសតាំងចៅក្រមជម្រះក្ដី ឬចៅក្រមស៊ើបអង្កេត ឬព្រះរាជអាជ្ញាផ្សេងទៀត ឱ្យបំពេញកន្លែងទំនេរក្នុងចំណោមបញ្ជីបេក្ខជនបរទេសដែលមានចែងក្នុងមាត្រា១១ ថ្មី. ១៨ ថ្មី និងមាត្រា២៦

នៃ ច្បាប់នេះ។ ក្នុងករណីដែលឈ្មោះក្នុងបញ្ជីត្រូវបានប្រើអស់ ហើយលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ពុំបានផ្តល់បញ្ជីឈ្មោះបេក្ខជនថ្មីបន្ថែម ឬក្នុងករណីដែលអង្គការសហប្រជាជាតិដកការគាំទ្រពីអង្គជំនុំជម្រះវិសាមញ្ញ កន្លែងទំនេរទាំងនោះ ត្រូវបំពេញបន្ថែម ដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ពីបណ្តាបេក្ខជនដែលបានស្នើឡើង ដោយរដ្ឋាភិបាលនៃបណ្តារដ្ឋជាសមាជិកនៃអង្គការសហប្រជាជាតិ ឬពីក្នុងចំណោមឥស្សរជនច្បាប់បរទេសដទៃទៀត។

បន្ទាប់ពីអនុវត្តនីតិវិធីនេះហើយ បើនៅតែគ្មានចៅក្រមជម្រះក្តី ឬចៅក្រមស៊ើបអង្កេត ឬព្រះរាជអាជ្ញាបរទេស ចូលរួមក្នុងការងាររបស់អង្គជំនុំជម្រះវិសាមញ្ញ ហើយគ្មានបេក្ខជនបរទេសណាត្រូវបានជ្រើសរើសឱ្យបំពេញតំណែងទំនេរនេះទេ នៅពេលនោះ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមអាចជ្រើសតាំងចៅក្រមជម្រះក្តី ឬចៅក្រមស៊ើបអង្កេត ឬព្រះរាជអាជ្ញាខ្មែរជំនួស។

## ជំពូកទី ១៨
## អត្ថិភាពនៃអង្គជំនុំជម្រះវិសាមញ្ញ

**មាត្រា ៤៧.-**

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវរលាយខ្លួនជាស្វ័យប្រវត្តិ ក្រោយពេលដែលការវិនិច្ឆ័យទោសក្នុងរឿងក្តីនេះបានចប់ជាស្ថាពរ។

**មាត្រា ៤៧ ស្ទួន.-**

ក្រោយពេលផ្តល់សច្ចាប័នសមស្របតាមបទបញ្ញត្តិនៃច្បាប់ព្រះរាជាណាចក្រកម្ពុជា ទាក់ទងទៅនឹងសមត្ថកិច្ចនៃការចុះសន្ធិសញ្ញាកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ធ្វើនៅភ្នំពេញថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ ត្រូវអនុវត្តជាច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី ១៩
## អវសានប្បញ្ញត្តិ

**មាត្រា ៤៨.-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

# ឧបសម្ព័ន្ធ ៣

# កិច្ចព្រមព្រៀង
# រវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា
# ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្ម
# ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

ដោយហេតុថា មហាសន្និបាតអង្គការសហប្រជាជាតិបានរំលឹកនៅក្នុងសេចក្តីសម្រេចចិត្តរបស់ខ្លួន លេខ ៥៧/២២៨ ថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ២០០២ ជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរចំពោះច្បាប់កម្ពុជា និងច្បាប់មនុស្សធម៌អន្តរជាតិក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នៅតែជាបញ្ហាដែលបង្កឲ្យមានការ ព្រួយបារម្ភយ៉ាងធ្ងន់ធ្ងរដល់សហគមន៍អន្តរជាតិទាំងមូល។

ដោយហេតុថា នៅក្នុងសេចក្តីសម្រេចចិត្តដដែលនេះ មហាសន្និបាតបានទទួលស្គាល់ការព្រួយបារម្ភពេញច្បាប់របស់រដ្ឋាភិបាល និងប្រជាជនកម្ពុជាក្នុងការស្វែងរកយុត្តិធម៌ ការបង្រួបបង្រួមជាតិ ស្ថេរភាព សន្តិភាព និង សន្តិសុខ។

ដោយហេតុថា អាជ្ញាធរកម្ពុជាបានស្នើសុំជំនួយពីអង្គការសហប្រជាជាតិដើម្បីកាត់សេចក្តីមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ ១៧ មេសា ១៩៧៥ ដល់ថ្ងៃ ០៦ មករា ១៩៧៩។

ដោយហេតុថា នៅមុនពេលចរចាលើកិច្ចព្រមព្រៀងនេះមានការរីកចម្រើនជាច្រើនធ្វើឡើងដោយលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ (បន្ទាប់ពីនេះហៅថា"លោកអគ្គលេខាធិការ") និងរាជរដ្ឋាភិបាលកម្ពុជា ឈានទៅរកការបង្កើតនូវអង្គជំនុំជម្រះវិសាមញ្ញ នៅក្នុងរចនាសម្ពន្ធ័តុលាការកម្ពុជាដែលមានស្រាប់ ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងរយៈពេលកម្ពុជាប្រជាធិបតេយ្យដោយមានជំនួយអន្តរជាតិ។

ដោយហេតុថា តាមសេចក្តីសម្រេចចិត្តលេខ ៥៧/២២៨ មហាសន្និបាតបានស្វាគមន៍ច្បាប់ស្តីពីការបង្កើត អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែល


រក្សាសិទ្ធិ © 2004 ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

ប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិតេយ្យ ហើយបានស្នើសុំលោកអគ្គលេខាធិការឲ្យបន្តការចរចាដោយពុំមានការពន្យារពេលដើម្បីសម្រេចកិច្ចព្រមព្រៀងជាមួយរដ្ឋាភិបាល ដោយឈរលើការចរចាពីពេលមុនស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ សមស្របតាមខ្លឹមសារនៃសេចក្តីសម្រេចនេះ ដើម្បីឲ្យអង្គជំនុំជម្រះវិសាមញ្ញអាចចាប់ផ្តើមដំណើរការបានឆាប់។

ដោយហេតុថា លោកអគ្គលេខាធិការនិងរដ្ឋាភិបាលកម្ពុជាបានធ្វើការចរចា ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ។

អាស្រ័យហេតុនេះ ក្នុងពេលនេះអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា បានព្រមព្រៀងគ្នាដូចតទៅ៖

## មាត្រា ១
## គោលបំណង

គោលបំណងរបស់កិច្ចព្រមព្រៀងនេះ គឺកំណត់អំពីកិច្ចសហប្រតិបត្តិការរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា ដើម្បីកាត់សេចក្តីមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ ១៧ មេសា ១៩៧៥ ដល់ថ្ងៃ ០៦ មករា ១៩៧៩។ ក្នុងចំណោមប្រការផ្សេងៗទៀត កិច្ចព្រមព្រៀងនេះផ្តល់មូលដ្ឋានគតិយុត្តិគោលការណ៍ និងបែបបទសម្រាប់កិច្ចសហប្រតិបត្តិការនេះ។

## មាត្រា ២
## ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ

១- កិច្ចព្រមព្រៀងនេះទទួលស្គាល់ថា អង្គជំនុំជម្រះវិសាមញ្ញមានយុត្តាធិការលើរឿងក្តីដូចដែលបានចែងក្នុង"ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ" (បន្ទាប់ពីនេះហៅថា "ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ") ដូចដែលបានអនុម័តនិងធ្វើវិសោធនកម្មដោយអង្គនីតិប្បញ្ញត្តិកម្ពុជានៅក្រោមរដ្ឋធម្មនុញ្ញកម្ពុជា។ កិច្ចព្រមព្រៀងនេះ ទទួលស្គាល់ផងដែរ


រក្សាសិទ្ធិ © 2004 ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

ជា អង្គជំនុំជម្រះវិសាមញ្ញមានយុត្តាធិការលើរូបបុគ្គលជាមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម ដែលបានចែងក្នុងមាត្រា ១ នៃកិច្ចព្រមព្រៀង។

២-កិច្ចព្រមព្រៀងនេះ ត្រូវអនុវត្តក្នុងប្រទេសកម្ពុជា តាមរយៈច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញនៅពេលអនុម័តនិងធ្វើវិសោធនកម្មរួច។ កិច្ចព្រមព្រៀងនេះត្រូវអនុវត្តតាមអនុសញ្ញាទីក្រុងវីយែន ស្តីពីច្បាប់នៃសន្ធិសញ្ញាជាពិសេសមាត្រា២៦ និង ២៧។

៣-នៅក្នុងករណីចាំបាច់ មានវិសោធនកម្មលើច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ វិសោធនកម្មបែបនេះត្រូវតែមានការពិគ្រោះយោបល់គ្នាជាមុនរវាងភាគីទាំងពីរ។

## មាត្រា ៣

## ចៅក្រម

១-ចៅក្រមកម្ពុជាម្ខាង និងម្ខាងទៀតចៅក្រមដែលតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមតាមសំណើរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ (បន្ទាប់ពីនោះហៅថា "ចៅក្រមអន្តរជាតិ") ត្រូវបម្រើការនៅក្នុងអង្គជំនុំជម្រះនីមួយៗនៃអង្គជំនុំជម្រះវិសាមញ្ញទាំងពីរថ្នាក់។

២-សមាសភាពរបស់អង្គជំនុំជម្រះមានដូចខាងក្រោម៖

ក-អង្គជំនុំជម្រះសាលាដំបូង៖ ចៅក្រមខ្មែរ បីរូប និងចៅក្រមអន្តរជាតិ ពីររូប។

ខ-អង្គជំនុំជម្រះតុលាការកំពូល៖ ដែលជាកន្លែងទទួលពាក្យបណ្តឹងឧទ្ធរណ៍ផង និងជាកន្លែងចេញសេចក្តីសម្រេចបិទផ្លូវតវ៉ាផង៖ ចៅក្រមខ្មែរ បួនរូប និងចៅក្រមអន្តរជាតិបីរូប។

៣-ចៅក្រមត្រូវតែជាបុគ្គលដែលមានចរិតលក្ខណៈ និងស្មារតីខ្ពស់ មិនលំអៀង និងសុចរិត មានគុណសម្បត្តិដែលតម្រូវសម្រាប់តែងតាំងឲ្យបម្រើការក្នុងការិយាល័យតុលាការនៅប្រទេសរបស់ខ្លួន។ ចៅក្រមត្រូវឯករាជ្យក្នុងការបំពេញមុខងាររបស់ខ្លួន និងមិនអាចទទួលយក ឬស្វែងរកការណែនាំពីរដ្ឋាភិបាល ឬប្រភពណាមួយផ្សេងទៀតឡើយ។


រក្សាសិទ្ធិ © 2004 ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

៤-នៅក្នុងគ្រប់សមាសភាពរបស់អង្គជំនុំជម្រះ ត្រូវគិតគូរឲ្យបានត្រឹមត្រូវដល់បទពិសោធន៍របស់ចៅក្រមក្នុងច្បាប់ព្រហ្មទណ្ឌ ច្បាប់អន្តរជាតិ រួមទាំងច្បាប់មនុស្សធម៌អន្តរជាតិ និងច្បាប់សិទ្ធិមនុស្ស។

៥-លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ នឹងបញ្ជូនបញ្ជីឈ្មោះបេក្ខជនសម្រាប់តំណែងជាចៅក្រមអន្តរជាតិយ៉ាងតិចប្រាំពីររូប ហើយពីក្នុងបញ្ជីនេះ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនឹងតែងតាំងចំនួនប្រាំរូប ដើម្បីបម្រើការជាចៅក្រមនៅក្នុងអង្គជំនុំជម្រះក្តីទាំងពីរថ្នាក់។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមតែងតាំងចៅក្រមអន្តរជាតិ ដោយយកពីក្នុងបញ្ជីឈ្មោះដែលលោកអគ្គលេខាធិការអង្គការសហប្រជាជាតិបានប្រគល់ជូនតែប៉ុណ្ណោះ។

៦-ក្នុងករណីដែលមានកន្លែងទំនេររបស់ចៅក្រមអន្តរជាតិណាមួយ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនឹងតែងតាំងចៅក្រមអន្តរជាតិមួយរូបទៀតពីក្នុងបញ្ជីឈ្មោះដដែលនេះជំនួស។

៧-ចៅក្រមត្រូវតែងតាំងសម្រាប់រយៈពេលនៃការជំនុំជម្រះ។

៨-បន្ថែមលើចៅក្រមអន្តរជាតិដែលជម្រះក្តីក្នុងអង្គជំនុំជម្រះ នឹងមានវត្តមាននៅគ្រប់លំដាប់ថ្នាក់នៃការជំនុំជម្រះប្រធានអង្គជំនុំជម្រះដោយផ្អែកតាមករណីនីមួយៗ និងដោយយកពីក្នុងបញ្ជីឈ្មោះដែលលោកអគ្គលេខាធិការបានដាក់ជូន អាចចាត់តាំងនូវចៅក្រមបម្រុងមួយរូប ឬច្រើនជាងនេះ ដែលនឹងត្រូវវត្តមាននៅគ្រប់ដំណាក់កាល នៃការជំនុំជម្រះសម្រាប់ជំនួសចៅក្រមអន្តរជាតិណាម្នាក់ ប្រសិនបើចៅក្រមនោះមិនអាចបន្តការជំនុំជម្រះក្តីបាន។

## មាត្រា៤
## ការសម្រេចសេចក្តី

១-ចៅក្រមត្រូវព្យាយាមឈានទៅដល់ការឯកភាពគ្នាជាឯកច្ឆ័ន្ទនៅក្នុងការសម្រេចសេចក្តីរបស់ខ្លួន។ ប្រសិនបើមិនអាចទទួលបានការឯកភាពគ្នាជាឯកច្ឆ័ន្ទទេ ត្រូវអនុវត្តរូបមន្តខាងក្រោមនេះ៖

ក-ការសម្រេចសេចក្តីរបស់សាលាដំបូងតម្រូវឲ្យមានសំឡេងឆ្នោតគាំទ្រពីចៅក្រមបួននាក់យ៉ាងតិច។

ខ-ការសម្រេចសេចក្តីដោយអង្គជំនុំជម្រះវិសាមញ្ញនៃតុលាការកំពូល តម្រូវឲ្យមានសំឡេងឆ្នោតគាំទ្រពីចៅក្រមប្រាំរូបយ៉ាងតិច។


រក្សាសិទ្ធិ © 2004 ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

២-នៅពេលដែលគ្មានការឯកភាពជាឯកច្ឆ័ន្ទទេ ការសម្រេចសេចក្ដីរបស់អង្គជំនុំជម្រះ ត្រូវមានទស្សនៈរបស់មតិភាគច្រើន និងមតិភាគតិច។

មាត្រា ៥

ចៅក្រមស៊ើបអង្កេត

១-មានចៅក្រមស៊ើបអង្កេតខ្មែរមួយរូប និងចៅក្រមស៊ើបអង្កេតអន្តរជាតិមួយរូប ដែលបម្រើការជាសហចៅក្រមស៊ើបអង្កេត។ សហចៅក្រមស៊ើបអង្កេត ទទួលខុសត្រូវចំពោះការងារស៊ើបអង្កេត។

២-សហចៅក្រមស៊ើបអង្កេត ត្រូវតែជាបុគ្គលដែលមានចរិតលក្ខណៈ និងស្មារតីខ្ពស់មិនលំអៀងនិងសុចរិត មានគុណសម្បត្តិ ដែលតម្រូវសម្រាប់តែងតាំងឲ្យបម្រើការក្នុងការិយាល័យតុលាការនៅក្នុងប្រទេសរបស់ខ្លួនក្នុងផ្នែកនេះ។

៣-សហចៅក្រមស៊ើបអង្កេតត្រូវឯករាជ្យក្នុងការបំពេញមុខងាររបស់ខ្លួន និងមិនទទួលយក ឬស្វែងរកការណែនាំពីរដ្ឋាភិបាល ឬប្រភពណាមួយផ្សេងទៀតបានឡើយ។ ប៉ុន្តែគេត្រូវយល់ថា វិសាលភាពនៃការស៊ើបអង្កេត គឺកំណត់ត្រឹមតែមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មនិងការរំលោភយ៉ាងធ្ងន់ធ្ងរលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់អន្តរជាតិ និងអនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាទទួលស្គាល់ និងដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃទី ១៧ ខែ មេសា ១៩៧៥ ដល់ថ្ងៃទី ៦ ខែ មករា ១៩៧៩។

៤-សហចៅក្រមស៊ើបអង្កេតត្រូវសហការគ្នា ដើម្បីឈានទៅដល់ការឯកភាពគ្នាមួយក្នុងការស៊ើបអង្កេត។ នៅក្នុងករណីដែលចៅក្រមស៊ើបអង្កេតមិនអាចឯកភាពគ្នាថា ត្រូវបន្តការស៊ើបអង្កេតណាមួយ ការស៊ើបអង្កេតនោះត្រូវដំណើរការទៅមុខទៀត លើកលែងតែចៅក្រមទាំងនេះ ឬចៅក្រមណាម្នាក់ក្នុងចំណោមចៅក្រមទាំងនេះធ្វើការស្នើសុំនៅក្នុងរយៈពេលសាមសិបថ្ងៃឲ្យដោះស្រាយការខ្វែងគំនិតគ្នានេះតាមមាត្រា ៧។

៥-បន្ថែមពីលើបញ្ជីឈ្មោះបេក្ខជនចៅក្រមអន្តរជាតិ ដែលបានចែងក្នុងមាត្រា៣ វាក្យខណ្ឌទី៥ លោកអគ្គលេខាធិការអង្គការសហប្រជាជាតិនឹងដាក់ជូននូវបញ្ជីឈ្មោះបេក្ខជនពីររូបទៀត


រក្សាសិទ្ធិ © 2004 ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

ហើយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនឹងតែងតាំងចៅក្រមមួយរូបពីក្នុងបញ្ជីនេះ ដើម្បីបម្រើការជាចៅក្រមស៊ើបអង្កេតអន្តរជាតិ និងមួយរូបទៀតជាចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង។

៦-ក្នុងករណីមានកន្លែងទំនេរ ឬតម្រូវការដើម្បីបំពេញកន្លែងសហចៅក្រមស៊ើបអង្កេតអន្តរជាតិ អ្នកដែលត្រូវតែងតាំងឲ្យបំពេញកន្លែងនោះ ត្រូវតែជាចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងនោះតែម្តង។

៧-ចៅក្រមស៊ើបអង្កេតត្រូវតែងតាំងសម្រាប់រយៈពេលនៃការជំនុំជម្រះ។

មាត្រា៦

ព្រះរាជអាជ្ញា

១-មានព្រះរាជអាជ្ញាខ្មែរមួយរូប និងព្រះរាជអាជ្ញាអន្តរជាតិមួយរូប ដែលមានសមត្ថកិច្ចបង្ហាញខ្លួននៅក្នុងអង្គជំនុំជម្រះក្តីទាំងពីរថ្នាក់ ដោយបម្រើការជាសហព្រះរាជអាជ្ញា។ សហព្រះរាជអាជ្ញាទទួលខុសត្រូវលើការងារចោទប្រកាន់។

២-សហព្រះរាជអាជ្ញាត្រូវតែជាបុគ្គលដែលមានចរិតលក្ខណៈ និងស្មារតីខ្ពស់ និងមានកម្រិតសមត្ថភាពវិជ្ជាជីវៈខ្ពស់ និងមានបទពិសោធន៍ទូលំទូលាយក្នុងការស៊ើបអង្កេត និងការចោទប្រកាន់ក្នុងរឿងក្តីព្រហ្មទណ្ឌ។

៣-សហព្រះរាជអាជ្ញាត្រូវឯករាជ្យក្នុងការបំពេញមុខងាររបស់ខ្លួន និងមិនទទួលយក ឬស្វែងរកការណែនាំពីរដ្ឋាភិបាល ឬប្រភពណាមួយផ្សេងទៀតឡើយ។ ប៉ុន្តែត្រូវយល់ថា វិសាលភាពនៃការចោទប្រកាន់គឺកំណត់ត្រឹមមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់អន្តរជាតិ និងអនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាទទួលស្គាល់ និងដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃ ៦ ខែ មករា ឆ្នាំ ១៩៧៩។

៤-សហព្រះរាជអាជ្ញាត្រូវសហការគ្នា ដើម្បីឈានទៅដល់ការឯកភាពគ្នាមួយក្នុងការចោទប្រកាន់។ ក្នុងករណីដែលព្រះរាជអាជ្ញាមិនអាចឯកភាពគ្នាថា ត្រូវបន្តការចោទប្រកាន់ណាមួយ ការចោទប្រកាន់នោះត្រូវដំណើរការទៅមុខទៀត លើកលែងតែព្រះរាជអាជ្ញាទាំងពីរនេះ


រក្សាសិទ្ធិ © 2004 ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

ឬព្រះរាជអាជ្ញាណាមួយក្នុងចំណោមព្រះរាជអាជ្ញាទាំងពីរ ធ្វើការស្នើសុំនៅក្នុងរយៈពេលសាមសិបថ្ងៃឲ្យដោះស្រាយការខ្វែងគំនិតគ្នានេះតាមមាត្រា៧។

៥-លោកអគ្គលេខាធិការនឹងផ្តល់ជូននូវបញ្ជីឈ្មោះបេក្ខជនពីររូប ហើយពីក្នុងបញ្ជីនេះ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម នឹងតែងតាំងមួយរូបជាសហព្រះរាជអាជ្ញា និងមួយរូបទៀតជាសហព្រះរាជអាជ្ញាអន្តរជាតិបម្រុង។

៦-ក្នុងករណីមានកន្លែងទំនេរ ឬតម្រូវការដើម្បីបំពេញកន្លែងសហចៅក្រមស៊ើបអង្កេតអន្តរជាតិអ្នកដែលត្រូវតែងតាំងឲ្យបំពេញកន្លែងនោះ ត្រូវតែជាចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងនោះតែម្តង។

៧-ព្រះរាជអាជ្ញាត្រូវតែងតាំងសម្រាប់រយៈពេលនៃដំណើរការជំនុំជម្រះ។

៨-សហព្រះរាជអាជ្ញានីមួយៗមានព្រះរាជអាជ្ញារងមួយរូប ឬច្រើនរូបជាជំនួយ ក្នុងការចោទប្រកាន់ចំពោះមុខអង្គជំនុំជម្រះ។ ព្រះរាជអាជ្ញារងអន្តរជាតិត្រូវតែងតាំងដោយព្រះរាជអាជ្ញាអន្តរជាតិពីបញ្ជីឈ្មោះមួយដែលផ្តល់ដោយលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ។

## មាត្រា៧

## ការដោះស្រាយនូវការខ្វែងយោបល់គ្នារវាង
## សហចៅក្រមស៊ើបអង្កេត ឬសហព្រះរាជអាជ្ញា

១-ក្នុងករណីដែលសហចៅក្រមស៊ើបអង្កេត ឬសហព្រះរាជអាជ្ញាបានធ្វើសំណើស្របតាមមាត្រា ៥ វាក្យ ខណ្ឌ ៤ ឬមាត្រា ៦ វាក្យខណ្ឌ ៤ តាមករណីដែលកើតឡើង សហចៅក្រមស៊ើបអង្កេត ឬសហព្រះរាជអាជ្ញាត្រូវធ្វើឯកសាររាយការណ៍ជាលាយលក្ខណ៍អក្សរពីអង្គហេតុ និងហេតុផលបញ្ជាក់ពីគោលជំហរខ្វែងគំនិតគ្នារបស់ខ្លួន ដាក់ជូនប្រធានការិយាល័យរដ្ឋបាល។

២-ការខ្វែងគំនិតគ្នានេះនឹងត្រូវដោះស្រាយជាបន្ទាន់ដោយ"អង្គបុរេជំនុំជម្រះ" មួយមានចៅក្រមប្រាំរូប ដែលបីរូបតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដោយមានមួយរូបជាប្រធាន និងពីររូបទៀតតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមតាមសំណើរបស់លោកអគ្គលេខាធិការ។ ការជ្រើសរើសចៅក្រមនេះត្រូវអនុវត្តតាមមាត្រា ៣ វាក្យខណ្ឌទី ៣។


រក្សាសិទ្ធិ © 2004 ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

៣-ពេលដែលទទួលបានឯកសាររាយការណ៍ដូចបានចែងក្នុងវាក្យខណ្ឌទី ១ ប្រធានការិយាល័យរដ្ឋបាលត្រូវកោះប្រជុំអង្គបុរេជំនុំជម្រះភ្លាម និងបែងចែកឯកសាររាយការណ៍នេះជូនដល់សមាជិកអង្គបុរេជំនុំជម្រះ។

៤-ការសម្រេចសេចក្តីរបស់អង្គបុរេជំនុំជម្រះ ដែលមិនអាចប្តឹងឧទ្ធរណ៍បាន ត្រូវមានសំឡេងឆ្នោតគាំទ្រដោយចៅក្រមយ៉ាងតិចបួនរូប។ ការសម្រេចសេចក្តីនេះត្រូវជូនដល់ប្រធានរដ្ឋបាលដែលនឹងផ្សព្វផ្សាយ ហើយចែកជូនដល់សហចៅក្រមស៊ើបអង្កេត ឬសហព្រះរាជអាជ្ញា។ សហចៅក្រមស៊ើបអង្កេត ឬសហព្រះរាជអាជ្ញានឹងត្រូវ ដំណើរការភ្លាមៗស្របទៅតាមការសម្រេចរបស់អង្គបុរេជំនុំជម្រះ។ ប្រសិនបើគ្មានមតិភាគច្រើនដែលត្រូវការសម្រាប់ធ្វើការសម្រេចសេចក្តីទេ ការស៊ើបអង្កេត ឬការចោទប្រកាន់នឹងត្រូវបន្តដំណើរការទៅមុខទៀត។

## មាត្រា ៨

## ការិយាល័យរដ្ឋបាល

១-ត្រូវមានការិយាល័យរដ្ឋបាលមួយ ដើម្បីបម្រើការអង្គជំនុំជម្រះវិសាមញ្ញ អង្គបុរេជំនុំជម្រះ សហចៅក្រមស៊ើបអង្កេត និងការិយាល័យព្រះរាជអាជ្ញា។

២-ត្រូវមានប្រធានការិយាល័យរដ្ឋបាលខ្មែរមួយរូប ដែលនឹងត្រូវតែងតាំងដោយរាជរដ្ឋាភិបាលកម្ពុជា។ ប្រធានមានភារកិច្ចគ្រប់គ្រងទូទៅលើការងាររបស់ការិយាល័យរដ្ឋបាល លើកលែងតែការងារដែលស្ថិតនៅក្រោមបទប្បញ្ញត្តិ និងនីតិវិធីរបស់អង្គការសហប្រជាជាតិ។

៣-ត្រូវមានអនុប្រធានការិយាល័យរដ្ឋបាលអន្តរជាតិមួយរូប ដែលនឹងត្រូវតែងតាំងដោយលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ។ អនុប្រធានត្រូវទទួលខុសត្រូវចំពោះការជ្រើសរើសបុគ្គលិកអន្តរជាតិទាំងអស់ និងការគ្រប់គ្រងលើសមាសភាពអន្តរជាតិនៃអង្គជំនុំជម្រះវិសាមញ្ញ អង្គបុរេជំនុំជម្រះ សហចៅក្រមស៊ើបអង្កេត ការិយាល័យព្រះរាជអាជ្ញា និងការិយាល័យរដ្ឋបាល។

អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាឯកភាពគ្នាថា នៅពេលដែលអនុប្រធានការិយាល័យអន្តរជាតិត្រូវបានតែងតាំងដោយលោកអគ្គលេខាធិការ ការតែងតាំងដោយរាជរដ្ឋាភិបាលកម្ពុជាឲ្យជននោះទទួលមុខតំណែងក៏ត្រូវធ្វើឡើងភ្លាមដែរ។


រក្សាសិទ្ធិ © 2004 ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

៥-ប្រធាននិងអនុប្រធានការិយាល័យត្រូវសហការគ្នាដើម្បីអនុវត្តឲ្យកិច្ចការរដ្ឋបាលមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អ។

មាត្រា ៩

ឧក្រិដ្ឋកម្មដែលស្ថិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ

យុត្តាធិការលើរឿងក្តីរបស់អង្គជំនុំជម្រះវិសាមញ្ញរួមមានឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដូចដែលបានកំណត់ក្នុងអនុសញ្ញាឆ្នាំ ១៩៤៨ ស្តីពីការបង្ការនិងការផ្តន្ទាទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចបានកំណត់ក្នុងលក្ខន្តិកៈទីក្រុងរ៉ូម នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិឆ្នាំ ១៩៩៨ និងការរំលោភធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ និងឧក្រិដ្ឋកម្មផ្សេងៗទៀត ដូចបានកំណត់ក្នុងជំពូក ២ នៃច្បាប់ស្តីពីការបង្កើត អង្គជំនុំជម្រះវិសាមញ្ញដែលត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០១។

មាត្រា ១០

ទោសប្បញ្ញត្តិ

ទណ្ឌកម្មជាអតិបរមាសម្រាប់ផ្តន្ទាទោសឧក្រិដ្ឋកម្មនៅក្រោមយុត្តាធិការនៃអង្គជំនុំជម្រះវិសាមញ្ញគឺកំណត់ត្រឹមដាក់ពន្ធនាគារអស់មួយជីវិត។

មាត្រា ១១

ការលើកលែងទោស

១-រាជរដ្ឋាភិបាលកម្ពុជានឹងមិនស្នើសុំឲ្យមានការលើកលែងទោស ឬអនុគ្រោះទោសដល់ជនទាំងឡាយណាដែលអាចនឹងត្រូវស៊ើបអង្កេត ឬនឹងត្រូវផ្តន្ទាទោសអំពីឧក្រិដ្ឋកម្ម ដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះទេ។

២-ប្រការនេះផ្អែកលើសេចក្តីប្រកាសដោយរាជរដ្ឋាភិបាលកម្ពុជាថា រហូតមកដល់ពេលនេះមានតែករណីមួយគត់ទាក់ទងនឹងបញ្ហាដែលគ្របដណ្តប់ដោយច្បាប់នេះ នៅថ្ងៃទី ១៤ កញ្ញា ១៩៩៦ ពេលដែលការលើកលែង ទោសត្រូវបានផ្តល់ដល់មនុស្សម្នាក់គត់ដែលត្រូវបានផ្តន្ទាទោសនៅឆ្នាំ ១៩៧៩ ពីបទប្រល័យពូជសាសន៍។ អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាឯកភាពគ្នាថា វិសាលភាពនៃការលើកលែងទោសនេះគឺត្រូវសំរេចដោយ អង្គជំនុំជម្រះវិសាមញ្ញ។


រក្សាសិទ្ធិ © 2004 ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

## មាត្រា ១២

## នីតិវិធី

១-នីតិវិធីត្រូវសមស្របជាមួយច្បាប់កម្ពុជា។ នៅពេលណាដែលច្បាប់កម្ពុជា ពុំអាចដោះស្រាយបានចំពោះបញ្ហាពិសេសណាមួយ ឬមានភាពមិនច្បាស់លាស់ទាក់ទងទៅនឹងការបកស្រាយ ឬការអនុវត្តបទប្បញ្ញត្តិណាដែលពាក់ព័ន្ធក្នុងច្បាប់កម្ពុជា ឬក៏មានបញ្ហាទាក់ទងទៅនឹងភាពសមស្របគ្នារវាងបទប្បញ្ញត្តិបែបនេះទៅនឹងបទដ្ឋានអន្តរជាតិ គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធី ដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ។

២-អង្គជំនុំជម្រះវិសាមញ្ញត្រូវអនុវត្តយុត្តាធិការរបស់ខ្លួន សមស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និងដំណើរការសមស្របនៃច្បាប់ដូចដែលបានចែងក្នុងមាត្រា ១៤ និង ១៥ នៃអនុសញ្ញាអន្តរជាតិឆ្នាំ ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលកម្ពុជា គឺជាភាគីហត្ថលេខីដែរ។ ក្នុងផលប្រយោជន៍ធានាឲ្យមានសវនាការជាសាធារណៈ ហើយដំណើរការត្រឹមត្រូវនិងទុកចិត្តបាន ត្រូវយល់ថាតំណាងរបស់រដ្ឋសមាជិកនៃអង្គការសហប្រជាជាតិ តំណាងរបស់លោកអគ្គលេខាធិការ តំណាងបណ្តាញពត៌មាន និងតំណាងអង្គការក្រៅរដ្ឋាភិបាលជាតិនិងអន្តរជាតិ នឹងអាចចូលរួមស្តាប់ការជំនុំជម្រះក្តីបានគ្រប់ពេលវេលាទាំងអស់។ ការលើកលែងមិនឲ្យចូលរួមស្តាប់ការជំនុំជម្រះក្តីនេះ តាមមាត្រា១៤ នៃអនុសញ្ញាអាចធ្វើទៅបានតែក្នុងករណីចាំបាច់បំផុត តាមយោបល់របស់អង្គជំនុំជម្រះដែលពាក់ព័ន្ធ ហើយតែនៅពេលណាដែលការផ្សព្វផ្សាយចេញទៅនាំឲ្យប៉ះពាល់ដល់ផលប្រយោជន៍យុត្តិធម៌។

## មាត្រា ១៣

## សិទ្ធិរបស់ជនជាប់ចោទ

១-សិទ្ធិរបស់ជនជាប់ចោទ ដែលមានចែងនៅក្នុងមាត្រា១៤ និង ១៥ នៃអនុសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ត្រូវតែបានគោរពនៅទូទាំងដំណើរការនៃការជំនុំជម្រះក្តី។ សិទ្ធិបែបនេះជាពិសេសរួមមានសិទ្ធិទទួលបាននូវសវនាការមួយត្រឹមត្រូវ និងជាសាធារណៈ សិទ្ធិត្រូវបានចាត់ទុកថា គ្មានទោសពៃរ៍រហូតដល់ពេលរកឃើញថាជាប់ពិរុទ្ធ សិទ្ធិជ្រើសរើសមេធាវីដោយខ្លួនឯង សិទ្ធិមានពេលវេលានិងលក្ខណៈគ្រប់គ្រាន់ដើម្បី ត្រៀមរៀបចំ


រក្សាសិទ្ធិ © 2004 ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

ការពារខ្លួន សិទ្ធិទទួលបាននូវមេធាវីប្រសិនបើជនជាប់ចោទ គ្មានលទ្ធភាពជួលមេធាវីដោយខ្លួនឯង និងសិទ្ធិពិនិត្យ ឬបានពិនិត្យសាក្សីជាក់បន្ទុក។

២-អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាឯកភាពគ្នាថា ប្រការស្ដីពីសិទ្ធិទទួលបានមេធាវីការពារក្ដីនៅក្នុងច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ បានន័យថាជនជាប់ចោទមានសិទ្ធិជ្រើសរើសរកមេធាវីដោយខ្លួនឯង ដូចដែលបានធានានៅក្នុងអនុសញ្ញាអន្តរជាតិ ស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

### មាត្រា ១៤
### អាគារ

រាជរដ្ឋាភិបាលកម្ពុជាត្រូវផ្ដល់និងត្រូវរ៉ាប់រងចំណាយដោយខ្លួនឯង នូវអាគារសម្រាប់សហចៅក្រមស៊ើបអង្កេត ការិយាល័យព្រះរាជអាជ្ញា អង្គជំនុំជម្រះវិសាមញ្ញ អង្គបុរេជំនុំជម្រះ និងការិយាល័យរដ្ឋបាល។ រាជរដ្ឋាភិបាលក៏ត្រូវផ្ដល់ផងដែរនូវសម្ភារៈប្រើប្រាស់ ការជួយសម្រួល និងសេវាកម្មផ្សេងៗទៀតដែលចាំបាច់សម្រាប់ប្រតិបត្តិការរបស់អង្គជំនុំជម្រះ ដែលអាចឯកភាពគ្នាបានតាមរយៈកិច្ចព្រមព្រៀងដោយឡែករវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាល។

### មាត្រា ១៥
### បុគ្គលិកកម្ពុជា

ប្រាក់បៀវត្ស និងប្រាក់បំណាច់របស់ចៅក្រមកម្ពុជា ព្រះរាជអាជ្ញាកម្ពុជា និងបុគ្គលិកកម្ពុជាផ្សេងទៀតជាបន្ទុករបស់រាជរដ្ឋាភិបាលកម្ពុជា។

### មាត្រា ១៦
### បុគ្គលិកអន្តរជាតិ

ប្រាក់បៀវត្ស និងប្រាក់បំណាច់របស់ចៅក្រមអន្តរជាតិ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សហព្រះរាជអាជ្ញាអន្តរជាតិ និងបុគ្គលិកអន្តរជាតិផ្សេងទៀត ដែលជ្រើសរើសដោយអង្គការសហប្រជាជាតិជាបន្ទុករបស់អង្គការសហប្រជាជាតិ។

### មាត្រា ១៧
### ជំនួយហិរញ្ញវត្ថុ និងជំនួយផ្សេងៗទៀតរបស់អង្គការសហប្រជាជាតិ


រក្សាសិទ្ធិ © 2004 ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

អង្គការសហប្រជាជាតិត្រូវទទួលខុសត្រូវដូចតទៅនេះ៖

ក-ប្រាក់បៀវត្សរបស់ចៅក្រមអន្តរជាតិ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សហព្រះរាជអាជ្ញាអន្តរជាតិ អនុប្រធានការិយាល័យរដ្ឋបាល ព្រមទាំងបុគ្គលិកអន្តរជាតិដទៃទៀត។

ខ-ចំណាយសម្រាប់ថ្លៃទឹក ភ្លើង ទូរស័ព្ទ ។ល។ ឬសេវាផ្សេងៗ ដោយមានការព្រមព្រៀងគ្នាដោយឡែក រវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា។

គ-ប្រាក់បៀវត្សសម្រាប់មេធាវីការពារក្តី។

ឃ-ការធ្វើដំណើររបស់សាក្សីក្នុងប្រទេសកម្ពុជា និងមកពីបរទេស។

ង-សុវត្ថិភាពនិងសន្តិសុខដោយមានការព្រមព្រៀងដោយឡែករវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាល។

ច-ជំនួយឧបត្ថម្ភមានកំណត់ដទៃទៀតដែលអាចនឹងចាំបាច់ ដើម្បីធានាដំណើរការរលូនដល់ការស៊ើបអង្កេត ការចោទប្រកាន់ និងអង្គជំនុំជម្រះវិសាមញ្ញ។

មាត្រា ១៨

ភាពមិនអាចរំលោភបំពានបាននៃបណ្ណសារ និងឯកសារ

បណ្ណសាររបស់សហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា អង្គជំនុំជម្រះវិសាមញ្ញ អង្គបុរេជំនុំជម្រះ និងការិយាល័យរដ្ឋបាល ហើយជាទូទៅរាល់ឯកសារ និងសម្ភារៈទាំងអស់ដែលរកបានមកដែលជារបស់ ឬប្រើប្រាស់ដោយអង្គជំនុំជម្រះវិសាមញ្ញ ទោះជានៅកន្លែងណាក៏ដោយក្នុងប្រទេសកម្ពុជា ហើយទោះជារក្សាទុកដោយជនណា ក៏ដោយមិនអាចត្រូវរំលោភបំពានបានឡើយក្នុងរយៈពេលនៃការជំនុំជម្រះក្តី។

មាត្រា ១៩

បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិរបស់ចៅក្រមអន្តរជាតិ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សហព្រះរាជអាជ្ញាអន្តរជាតិ និងអនុប្រធានការិយាល័យរដ្ឋបាល

១-ចៅក្រមអន្តរជាតិ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សហព្រះរាជអាជ្ញាអន្តរជាតិ និងអនុប្រធានការិយាល័យរដ្ឋបាល ព្រមទាំងសមាជិកគ្រួសាររបស់ពួកគេនឹងទទួលបាននូវបុព្វសិទ្ធិ


រក្សាសិទ្ធិ © 2004 ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

និងអភ័យឯកសិទ្ធិ ការលើកលែង និងភាពងាយស្រួល ដូចគ្នានឹងភ្នាក់ងារការទូត យោងតាមអនុសញ្ញាទីក្រុងវីយែនឆ្នាំ ១៩៦១ ស្តីពីទំនាក់ទំនងការទូត។

ជាពិសេសពួកគេនឹងទទួលបាន៖

ក-ភាពជាបុគ្គលមិនអាចរំលោភបំពានបាន រួមមានអភ័យឯកសិទ្ធិលើការចាប់ខ្លួន ឬឃុំខ្លួន។

ខ-អភ័យឯកសិទ្ធិលើយុត្តាធិការព្រហ្មទណ្ឌ រដ្ឋប្បវេណី និងរដ្ឋបាល ស្របតាមអនុសញ្ញាទីក្រុងវីយែន។

គ-ភាពមិនអាចរំលោភបំពានបានចំពោះរាល់ក្រដាសស្នាម និងឯកសារទាំងអស់។

ឃ-ការលើកលែងអំពីការរឹតត្បិតផ្នែកអន្តោប្រវេសន៍ និងការចុះបញ្ជីជនបរទេស។

ង-អភ័យឯកសិទ្ធិ និងការជួយសម្រួលចំពោះអីវ៉ាន់ផ្ទាល់ខ្លួន ដូចគ្នានឹងភ្នាក់ងារការទូត។

២-ចៅក្រមអន្តរជាតិ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សហព្រះរាជអាជ្ញាអន្តរជាតិ និងអនុប្រធានការិយាល័យរដ្ឋបាល នឹងទទួលបាននូវការលើកលែងពីការយកពន្ធ លើប្រាក់បៀវត្សប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗរបស់ពួកគេនៅប្រទេសកម្ពុជា។

## មាត្រា ២០

## បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិរបស់បុគ្គលិកកម្ពុជា និងអន្តរជាតិ

១-ចៅក្រម សហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា និងបុគ្គលិកកម្ពុជាដទៃទៀតទទួលបានអភ័យឯកសិទ្ធិលើដំណើរការច្បាប់ទាក់ទងនឹងពាក្យសំដីនិយាយ ឬសរសេរ និងគ្រប់សកម្មភាពទាំងអស់ដែលពួកគេបានបំពេញក្នុងតួនាទីផ្លូវការរបស់ពួកគេនៅក្រោមកិច្ចព្រមព្រៀងនេះ។ អភ័យឯកសិទ្ធិនេះនៅតែមានជាបន្តក្រោយពី ពួកគេបញ្ចប់ការងារជាមួយសហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា អង្គជំនុំជម្រះវិសាមញ្ញ អង្គបុរេជំនុំជម្រះ និងការិយាល័យរដ្ឋបាល។

២-បុគ្គលិកអន្តរជាតិ នឹងទទួលបាន៖

ក-អភ័យឯកសិទ្ធិលើដំណើរការច្បាប់ទាក់ទងនឹងពាក្យសំដីនិយាយ ឬសរសេរ និងគ្រប់សកម្មភាពដែលពួកគេបានបំពេញនៅក្នុងតួនាទីជាផ្លូវការរបស់ពួកគេនៅក្រោមកិច្ចព្រមព្រៀងនេះ។ អភ័យឯកសិទ្ធិបែបនេះនឹងនៅតែមានជាបន្ត ក្រោយពីពួកគេបញ្ចប់ការងារជាមួយសហចៅក្រម


រក្សាសិទ្ធិ © 2004 ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

ស៊ើបអង្កេត សហព្រះរាជអាជ្ញា អង្គជំនុំជម្រះវិសាមញ្ញ អង្គបុរេជំនុំជម្រះ និងការិយាល័យរដ្ឋបាល។

ខ-អភ័យឯកសិទ្ធិលើការយកពន្ធលើប្រាក់បៀវត្ស ប្រាក់ឧបត្ថម្ភ និងប្រាក់បំណាច់ផ្សេងៗ ដែលផ្តល់ឲ្យពួកគេដោយអង្គការសហប្រជាជាតិ។

គ-អភ័យឯកសិទ្ធិលើការរឹតត្បិតខាងអន្តោប្រវេសន៍។

ឃ-សិទ្ធិនាំចូលដោយឥតបង់ពន្ធនិងអាករផ្សេងៗចំពោះគ្រឿងសង្ហារឹម និងសម្ភារៈផ្ទាល់ខ្លួន លើកលែងតែការទូទាត់ចំពោះសេវា នៅពេលដែលទទួលមុខតំណែងជាផ្លូវការលើកទីមួយនៅកម្ពុជា។

៣-អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាឯកភាពគ្នាថា អភ័យឯកសិទ្ធិដែលផ្តល់ឲ្យដោយច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញទាក់ទងទៅនឹងពាក្យសំដីនិយាយ ឬសរសេរ និងរាល់សកម្មភាពទាំងអស់ដែលពួកគេបានបំពេញនៅក្នុងតួនាទីជាផ្លូវការរបស់ពួកគេនៅក្រោមកិច្ចព្រមព្រៀងនេះនឹងស្ថិតនៅបន្ត ក្រោយពេលពួកគេឈប់បម្រើការងារជាមួយសហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា អង្គជំនុំជម្រះវិសាមញ្ញ អង្គបុរេជំនុំជម្រះ និងការិយាល័យរដ្ឋបាល។

## មាត្រា ២១

## មេធាវី

១-រាជរដ្ឋាភិបាលមិនត្រូវដាក់មេធាវីរបស់ជនសង្ស័យ ឬជនជាប់ចោទ ដែលត្រូវបានទទួលស្គាល់ដោយអង្គជំនុំជម្រះវិសាមញ្ញឲ្យស្ថិតនៅក្រោមវិធានការណាមួយ ដែលអាចប៉ះពាល់ដល់ការបំពេញតួនាទីដោយសេរី និងឯករាជ្យរបស់ពួកគេនៅក្រោមកិច្ចព្រមព្រៀងនេះ។

២-ជាពិសេសមេធាវីនឹងទទួលបាន៖

ក-អភ័យឯកសិទ្ធិលើការចាប់ខ្លួន ឬការឃុំខ្លួន និងការរឹបអូសយកសម្ភារៈផ្ទាល់ខ្លួន។

ខ-ភាពមិនអាចរំលោភបំពានបាន ទៅលើឯកសារទាំងអស់ទាក់ទងនឹងការអនុវត្តមុខងាររបស់ខ្លួនក្នុងនាមជាមេធាវីរបស់ជនសង្ស័យ ឬជនជាប់ចោទ។

គ-អភ័យឯកសិទ្ធិលើយុត្តាធិការព្រហ្មទណ្ឌ ឬរដ្ឋប្បវេណីទាក់ទងនឹងពាក្យសំដីនិយាយ ឬសរសេរ និង សកម្មភាពដែលពួកគេបានបំពេញនៅក្នុងតួនាទីផ្លូវការជាមេធាវី។ អភ័យឯកសិទ្ធិ


រក្សាសិទ្ធិ © 2004 ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

បែបនេះនឹងនៅបន្តផ្តល់ចំពោះពួកគេ ក្រោយពួកគេបានបញ្ចប់មុខងារជាមេធាវីរបស់ជនសង្ស័យ ឬជនជាប់ចោទ។

៣-មេធាវីណាដែលមានសញ្ជាតិខ្មែរឬមិនមែនខ្មែរ ដែលត្រូវជួលឬចាត់តាំងឲ្យធ្វើការជាមួយជនសង្ស័យ ឬ ជនជាប់ចោទក្នុងការការពារក្តីរបស់ខ្លួន ត្រូវអនុវត្តតាមកិច្ចព្រមព្រៀងនេះ ច្បាប់កម្ពុជាស្តីពីលក្ខន្តិកៈមេធាវី បទដ្ឋាននិងសីលធម៌នៃវិជ្ជាជីវៈច្បាប់ដែលគេទទួលស្គាល់។

មាត្រា ២២

សាក្សី និងអ្នកជំនាញការ

សាក្សី និងអ្នកជំនាញការដែលមកបង្ហាញខ្លួន តាមដីកាឬការស្នើសុំរបស់ចៅក្រមសហចៅក្រមស៊ើបអង្កេត ឬសហព្រះរាជអាជ្ញានឹងមិនត្រូវចោទប្រកាន់ឃុំខ្លួន ឬជាកម្មវត្ថុនៃការរឹតត្បិតណាមួយផ្សេងទៀតលើសេរីភាពរបស់ពួកគេដោយអាជ្ញាធរកម្ពុជាឡើយ។ អាជ្ញាធរកម្ពុជាមិនត្រូវដាក់ពួកគេឲ្យនៅក្រោមវិធានការណាមួយ ដែល អាចប៉ះពាល់ដល់ការបំពេញមុខងាររបស់ពួកគេដោយសេរី និងឯករាជ្យ។

មាត្រា ២៣

ការការពារជនរងគ្រោះ និងសាក្សី

សហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា និងអង្គជំនុំជម្រះវិសាមញ្ញ ត្រូវផ្តល់ការការពារដល់ជនរងគ្រោះ និងសាក្សី។ វិធានការការពារបែបនេះរួមមាន ហើយមិនកំណត់ត្រឹមតែការអនុវត្តដំណើការសាកសួរជាសម្ងាត់ និងការការពារអត្តសញ្ញាណរបស់ជនរងគ្រោះ ឬសាក្សីនោះទេ។

មាត្រា ២៤

សន្តិសុខ សុវត្ថិភាព និងការការពារបុគ្គល ដែលមានចែងក្នុងកិច្ចព្រមព្រៀងថ្មីនេះ

រាជរដ្ឋាភិបាលនឹងចាត់វិធានការសមស្រប និងមានប្រសិទ្ធភាព ដែលចាំបាច់ដើម្បីធានានូវសន្តិសុខ សុវត្ថិភាព និងការការពារចំពោះបុគ្គលដែលមានចែងក្នុងកិច្ចព្រមព្រៀងនេះ។ អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលឯកភាពគ្នាថា រដ្ឋាភិបាលទទួលខុសត្រូវលើសុវត្ថិភាពរបស់ជនជាប់ចោទទាំងឡាយ ដោយមិនគិតថាពួកគេ បង្ហាញខ្លួនដោយស្ម័គ្រចិត្តចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ឬមួយក៏ត្រូវចាប់ខ្លួននោះឡើយ។


រក្សាសិទ្ធិ © 2004 ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

មាត្រា ២៥

កាតព្វកិច្ចជួយចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា និងអង្គជំនុំជម្រះវិសាមញ្ញ

រាជរដ្ឋាភិបាលនឹងអនុវត្តដោយគ្មានការពន្យារពេល តាមការស្នើសុំជំនួយរបស់សហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា ឬអង្គជំនុំជម្រះវិសាមញ្ញ ឬក៏បញ្ជារបស់ពួកគេ រួមមាន ប៉ុន្តែមិនមែនត្រឹមតែះ

ក-រកអត្តសញ្ញាណ និងទីកន្លែងរបស់បុគ្គលណាមួយ។

ខ-ផ្តល់ឯកសារ។

គ-ចាប់ខ្លួន ឬឃុំខ្លួនបុគ្គលណាមួយ។

ឃ-បញ្ជូនជនជាប់ចោទមកកាន់អង្គជំនុំជម្រះវិសាមញ្ញ។

មាត្រា ២៦

ភាសា

១-ភាសាដែលប្រើប្រាស់ជាផ្លូវការក្នុងការងាររបស់អង្គជំនុំជម្រះវិសាមញ្ញ និងអង្គបុរេជំនុំជម្រះ គឺ ភាសាខ្មែរ។

២-ភាសាការងារជាផ្លូវការរបស់អង្គជំនុំជម្រះវិសាមញ្ញ និងអង្គបុរេជំនុំជម្រះគឺភាសាខ្មែរ អង់គ្លេស និង បារាំង។

៣-ការបកប្រែឯកសារសាធារណៈ និងការបកប្រែផ្ទាល់មាត់ ពេលសវនាការសាធារណៈ ជាភាសារុស្សីអាចផ្តល់ឲ្យបានអាស្រ័យលើការសម្រេចនិងចំណាយរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងលក្ខខណ្ឌដែលមិនធ្វើឲ្យរំខានដល់ដំណើរការកាត់សេចក្តីនៅមុខអង្គជំនុំជម្រះវិសាមញ្ញ។

មាត្រា ២៧

ការរៀបចំតាមសភាពជាក់ស្តែង

១-ដើម្បីឲ្យមានប្រសិទ្ធភាព និងសន្សំសំចៃផង នៅក្នុងកិច្ចប្រតិបត្តិការរបស់អង្គជំនុំជម្រះវិសាមញ្ញ គេត្រូវរៀបចំបង្កើតអង្គជំនុំជម្រះតាមរបៀបជាដំណាក់ៗទៅតាមលំដាប់លំដោយនីតិវិធី។

២-នៅក្នុងដំណាក់កាលដំបូង នៃប្រតិបត្តិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ចៅក្រម សហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញា នឹងត្រូវបានតែងតាំងរួមជាមួយនឹងបុគ្គលិក


រក្សាសិទ្ធិ © 2004 ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

ដែលត្រូវធ្វើការជាមួយចៅក្រមស៊ើបអង្កេត និងព្រះរាជអាជ្ញា ហើយដំណើរការស៊ើបអង្កេត និងចោទប្រកាន់ត្រូវចាប់ផ្ដើម។

៣-ដំណើរការជំនុំជម្រះក្ដីអ្នកដែលត្រូវបានឃុំឃាំងរួចហើយ ត្រូវដំណើរការទន្ទឹមគ្នានឹងការស៊ើបអង្កេតលើជនដទៃទៀត ដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម ដែលឋិតនៅក្រោមយុត្ដាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ។

៤-នៅពេលបញ្ចប់ការស៊ើបអង្កេតលើជនជាប់សង្ស័យថា បានប្រព្រឹត្តឧក្រិដ្ឋកម្មដែលឋិតនៅក្រោមយុត្ដាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញហើយ ដីកាចាប់ខ្លួននឹងត្រូវបញ្ជូនទៅរាជរដ្ឋាភិបាលដើម្បីអនុវត្តការចាប់ខ្លួន។

៥-នៅពេលដែលរាជរដ្ឋាភិបាលចាប់ខ្លួនជនដែលត្រូវចោទប្រកាន់ដែលស្ថិតនៅក្នុងទឹកដីកម្ពុជា ហើយអង្គជំនុំជម្រះវិសាមញ្ញនឹងត្រូវដំណើរការទាំងស្រុង ហើយចៅក្រមតុលាការកំពូលត្រូវចាប់ផ្ដើមបម្រើការនៅពេលទទួលរឿងក្ដីរបស់ខ្លួនហើយនោះ។ ចៅក្រមនៃអង្គបុរេជំនុំជម្រះត្រូវបម្រើការតែនៅពេលគេត្រូវការសេវារបស់ខ្លួនតែប៉ុណ្ណោះ។

មាត្រា ២៨

ការដកខ្លួនចេញពីកិច្ចសហប្រតិបត្តិការ

ប្រសិនបើរាជរដ្ឋាភិបាលផ្លាស់ប្ដូររចនាសម្ព័ន្ធ ឬការរៀបចំអង្គជំនុំជម្រះវិសាមញ្ញ ឬក៏ធ្វើយ៉ាងណាឲ្យអង្គជំនុំជម្រះដំណើរការតាមរបៀបណាមួយដែលមិនសមស្របជាមួយខ្លឹមសារនៃកិច្ចព្រមព្រៀងនេះ អង្គការសហប្រជាជាតិរក្សាសិទ្ធិផ្អាកជំនួយឧបត្ថមជាហិរញ្ញវត្ថុ ឬជាអ្វីផ្សេងទៀតដែលបានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ។

មាត្រា ២៩

ការដោះស្រាយជម្លោះ

ជម្លោះណាមួយរវាងភាគីទាំងសងខាង ទាក់ទងនឹងការបកស្រាយ ឬអនុវត្តន៍កិច្ចព្រមព្រៀងនេះត្រូវដោះស្រាយតាមការចរចា ឬដំណោះស្រាយណាផ្សេងទៀតដែលឯកភាពគ្នាទៅវិញទៅមក។

មាត្រា ៣០

ការអនុម័ត


រក្សាសិទ្ធិ © 2004 ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

ដើម្បីឲ្យភាគីទាំងពីរមានកាតព្វកិច្ចតាមផ្លូវច្បាប់ កិច្ចព្រមព្រៀងនេះ ត្រូវអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ និងផ្តល់សច្ចាប័នដោយកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជា ត្រូវខិតខំប្រឹងប្រែងឲ្យបានសច្ចាប័ននេះ ក្នុងកាលបរិច្ឆេទដ៏ឆាប់បំផុតដែលអាចធ្វើទៅបាន។

មាត្រា ៣១

ការអនុវត្តនៅក្នុងប្រទេសកម្ពុជា

កិច្ចព្រមព្រៀងនេះត្រូវអនុវត្តដូចជាច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្រោយពីទទួលសច្ចាប័នសមស្របតាមច្បាប់ផ្ទៃក្នុងរបស់ព្រះរាជាណាចក្រកម្ពុជាស្តីពីសមត្ថកិច្ចក្នុងការចុះសន្ធិសញ្ញា។

មាត្រា ៣២

ការចូលជាធរមាន

កិច្ចព្រមព្រៀងនេះ ចូលជាធរមាននៅថ្ងៃបន្ទាប់ពីភាគីទាំងពីរ ជូនដំណឹងប្រាប់គ្នាទៅវិញទៅមកជាលាយលក្ខណ៍អក្សរថា តម្រូវការសម្រាប់ការចូលជាធរមាន តាមផ្លូវច្បាប់ត្រូវបានបំពេញរួចហើយ។

ធ្វើនៅរាជធានីភ្នំពេញ នៅថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ ២០០៣ ជាពីរច្បាប់ជាភាសាអង់គ្លេស។

| | |
|---|---|
| ភាគីរាជរដ្ឋាភិបាលកម្ពុជា | ភាគីអង្គការសហប្រជាជាតិ |
| សុខ អាន | ហាន់ កូរ៉ែល |
| ទេសរដ្ឋមន្ត្រី | អគ្គលេខាធិការរងសំរាប់កិច្ចការច្បាប់ |
| រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ទីប្រឹក្សាច្បាប់ |


រក្សាសិទ្ធិ © 2004 ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល